# តួនាទីរបស់ព្រះសង្ឃ
# ក្នុងសង្គមខ្មែរ



ដោយ
ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ**

ព.ស.២៥៥២ គ.ស.២០០៨
www.hoksavann.org

# មាតិកាអត្ថបទ


១. ប្រទេសកម្ពុជាជាមួយព្រះពុទ្ធសាសនា ១

២. អំពីវត្តនិងព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរ ១៣

៣. ព្រះសង្ឃជាគ្រូអប់រំសីលធម៌ ១៨

៤. អំពីព្រះសង្ឃនិងការបោះឆ្នោត ២១

៥. ធម៌ដែលនាំឲ្យព្រះសង្ឃសាមគ្គីគ្នា ២៧

៦. អត្ថន័យនៃការសូត្រធម៌របស់ព្រះសង្ឃ ២៩

៧. សាសនពិធីខ្លះរបស់ព្រះពុទ្ធសាសនាខ្មែរ ៤៣

៨. ព្រះសង្ឃខ្មែរដែលសិក្សានៅបរទេសគប្បី រក្សានូវ លក្ខណៈជាព្រះសង្ឃខ្មែរ ៤៩

៩. គប្បីសម្លាប់តណ្ហា ពុំមែនសម្លាប់ខ្លួនដើម្បី រំលត់ទុក្ខឡើយ ៥៣

១០. និកាយនៃព្រះពុទ្ធសាសនា ៥៨

១១. លក្ខណៈនៃព្រះពុទ្ធរូប ៦២

១២. ព្រះសង្ឃឈប់ឆាន់បារីជាគំរូដ៏ល្អដល់ពុទ្ធ បរិស័ទខ្មែរ ៦៥

១៣. ពុទ្ធសាសនិកជនខ្មែរគួរតាំងអាសនៈដំកល់ ព្រះពុទ្ធរូបគ្រប់គេហដ្ឋាន ៦៩

១៤. ការធ្វើសក្ការបូជាគួរប្រើទៀននិងផ្កាមិនគួរ ប្រើធូបឡើយ ៧១

១៥. ផលិតផលព្រះពុទ្ធសាសនារបស់ថៃដែលគួរ និងមិនគួរនាំចូលមកប្រទេសកម្ពុជា ៧៧

១៦. អំពីអបីយ៍ជំនឿផ្ទុយពីព្រះពុទ្ធសាសនា ៨៥
១៧. ពាក្យសូមខមាទោស ៩៥
១៨. ទស្សនៈអំពីពាក្យកាព្យ តេជៈខ្ញុំសាង ៩៧

# ១- ប្រទេសកម្ពុជាជាមួយ ព្រះពុទ្ធសាសនា

ប្រទេសកម្ពុជាមានអារ្យធម៌ចាស់ទុំនៅអាស៊ីភាគអគ្នេយ៍ ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង។ ជនជាតិខ្មែរបានទទួលយកព្រះពុទ្ធសាសនាជាសរណៈទីពឹងប្រចាំជីវិតរបស់ខ្លួន ឯសាសនាព្រាហ្មណ៍ដែលផ្សាយចូលមកកម្ពុជាដែរនោះ ពេលក្រោយខ្មែរពុំយកជាសរណៈទីពឹងដូចព្រះពុទ្ធសាសនាឡើយ ទើបសាសនាព្រាហ្មណ៍មកជ្រកនៅតាមទំនៀមទំលាប់ខ្មែរខ្លះ និងតាមរយៈសិល្បៈដូចជារឿងរាមកេរ្តិ៍ជាដើម។ ដូច្នេះមូលដ្ឋានវប្បធម៌ខ្មែរ គឺព្រះពុទ្ធសាសនាជាព្រលឹងអត្តសញ្ញាណរបស់ខ្លួន ខ្មែរជឿកម្មជឿផល ជឿបាបជឿបុណ្យ ដឹងគុណដឹងទោស មានហេតុផលដូចហេតុផលរបស់វិទ្យាសាស្ត្រ។ អ្វីមួយដែលប្រាសចាកហេតុផល ខ្មែរពុំអាចទទួលយកបានឡើយ។ យ៉ាងណាមិញ ខ្មែរជឿព្រះពុទ្ធសាសនា គឺជឿការពិតដែលព្រះពុទ្ធបានសំដែង ដូចពាក្យថាធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប មនុស្សកើតចាស់ឈឺស្លាប់ ដើម្បីរំលត់ទុក្ខត្រូវរំលត់អវិជ្ជា តណ្ហា ជាហេតុនាំឲ្យមានខន្ធ៥ មានរូបខន្ធជាដើម។

ជនជាតិខ្មែរមានភ័ព្វសំណាងដោយបានទទួលកាន់ព្រះពុទ្ធសាសនាថេរវាទ ជាសាសនាមួយមានមាគ៌ាប្រតិបត្តិ

គឺមគ្គប្រកបដោយអង្គ៨ក្នុងដំណើរឆ្ពោះទៅរកការរំដោះទុក្ខ មានជាតិទុក្ខជាដើម។ បច្ចុប្បន្ននេះ ពុទ្ធសាសនាបានចំរើនលូតលាស់យ៉ាងខ្លាំងនៅទ្វីបអឺរ៉ុបនិងនៅសហរដ្ឋអាមេរិកជាដើម។ អ្នកចូលកាន់ព្រះពុទ្ធសាសនានៃបស្ចឹមប្រទេសទាំងនោះ ភាគច្រើនពួកបញ្ញវ័ន្តអ្នកចេះដឹងដូចជាសាស្ត្រាចារ្យមេធាវីជាដើម ដោយពួកនោះមុនចូលព្រះពុទ្ធសាសនា បានអានសៀវភៅព្រះពុទ្ធសាសនាជាច្រើន ស្រាវជ្រាវទៅឃើញថា ព្រះពុទ្ធសាសនាសំដែងអំពីសច្ចធម៌ជាសច្ចសកលគឺការពិតទូទៅបានដល់អរិយសច្ច៤ មានទុក្ខសច្ចជាដើម សំរាប់ប្រតិបត្តិឆ្ពោះទៅរកការរំដោះទុក្ខរបស់មនុស្សសត្វ។ ដរាបណាវិទ្យាសាស្ត្រកាន់តែលូតលាស់ ព្រះពុទ្ធសាសនាកាន់តែលូតលាស់ដែរ ព្រោះព្រះពុទ្ធសាសនាក៏ដូចវិទ្យាសាស្ត្រ និយាយអំពីទំនាក់ទំនងរវាងហេតុនិងផល ដែលគេអាចធ្វើការពិសោធន៍បាន ដូចជាវិទ្យាសាស្ត្រខាងគីមីវិទ្យានិងភូមិវិទ្យាជាដើម ក៏ដូចជាពុទ្ធសាសនា ពោលថាហេតុយ៉ាងណាផលក៏កើតឡើងយ៉ាងនោះដែរ គឺផលកើតឡើងតាមហេតុរបស់វា។ ការត្រាស់ដឹងហេតុផលឬកម្មផលរបស់ព្រះពុទ្ធនេះ ជាការពិតសកលដែលជាអរិយសច្ចៈ (Noble truth) ដែលគេអាចធ្វើការពិសោធបានគ្រប់ពេលវេលានិងគ្រប់ទីកន្លែង។ ពួកបស្ចឹមប្រទេសទាំងនោះមានសទ្ធាជ្រះថ្លាដ៏ខ្លាំងក្លា មានខ្លះចូលបួស ហើយចូលចិត្តចំរើនវិបស្សនា (meditation)។ មាន

ស្រ្តីជាតិអង់គ្លេសម្នាក់ឈ្មោះខេរ៉ុនអាមស្ត្រុង (Karen Armstrong) បានធ្វើដូចជីសាសនាគ្រឹស្តអស់៧ឆ្នាំ នាងត្រឡប់មានសទ្ធានឹងព្រះពុទ្ធសាសនា ដោយឃើញពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធត្រង់មេត្តាករុណា (compassion) ការរាប់អានការអាណិតអាសូរមិនបៀតបៀនគ្នា ជាប្រភពសន្តិភាព និងឃើញធម៌អនត្តា បញ្ញាឃើញថាពុំមែនខ្លួននាំឲ្យមនុស្សដាក់អស្មិមានៈមិនប្រកាន់ខ្លួន ជាប្រភពសន្តិភាពពិភពលោក។

នៅឆ្នាំ១៩៩៩ សមាជិកនៃអង្គការសហប្រជាជាតិ បានអនុម័តជាឯកច្ឆន្ទ ទទួលស្គាល់និងចាត់ទុកបុណ្យពិសាខបូជារបស់ព្រះពុទ្ធសាសនាជាបុណ្យអន្តរជាតិ ដោយមូលហេតុពីរយ៉ាងគឺ ទីមួយបណ្តាសាសនាទាំងអស់ក្នុងសកលលោក ព្រះពុទ្ធសាសនាកើតមុនគេ។ ចំណែក សាសនាព្រាហ្មណ៍ដែលសព្វថ្ងៃហៅថាសាសនាហិណ្ឌូនោះ បានជាគេពុំចាត់ថាកើតមុនព្រះពុទ្ធសាសនា ព្រោះសាសនានេះពុំមានប្រព័ន្ធពាក្យប្រៀនប្រដៅឲ្យបានច្បាស់លាស់និងទៀងទាត់ ម្តងគោរពព្រះឥន្ទ ម្តងគោរពព្រះព្រហ្ម ម្តងគោរពព្រះឥសូរ ម្តងគោរពព្រះវិស្ណុឬព្រះនរាយណ៍ ម្តងរួមព្រះទាំងបីអង្គបញ្ចូលគ្នា ដែលមាននិយាយក្នុងគម្ពីរត្រៃវេទនិងគម្ពីរឧបនិស័ទជាដើម។ ចំណែកព្រះពុទ្ធសាសនាវិញ មានកាលបរិច្ឆេទត្រាស់ដឹងច្បាស់លាស់របស់ព្រះពុទ្ធ មានពាក្យប្រៀនប្រដៅច្បាស់លាស់ ដែលសព្វថ្ងៃមាននិយាយក្នុងគម្ពីរព្រះ

ត្រៃបិដក មានពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថទទួលកាន់ជឿពិតប្រាកដ។ ទីពីរ ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅមួយដ៏សំខាន់ គឺធម៌អហឹង្សា (non violence) ការមិនប្រៀតបៀនដែលដែលជាមូលដ្ឋាននៃសុខសន្តិភាពពិភពលោក (peace in the world)។ ស្របនឹងសេចក្តីថ្លែងការណ៍ជាសកលនៃអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្ស (Human Rights) នៅថ្ងៃទី១០ធ្នូ១៩៤៨ មិនឲ្យមនុស្សបៀតបៀនគ្នារំលោភលើសិទ្ធិគ្នា ហាក់ដូចជាអង្គការសហប្រជាជាតិយកពាក្យព្រះពុទ្ធធ្វើជាមូលដ្ឋានក្នុងការប្រកាសចំនួន៣០មាត្រានេះ។ បើគិតពីពេលវេលានៃការប្រកាសរវាងអង្គការសហប្រជាជាតិនិងព្រះពុទ្ធ គឺអង្គការសហប្រជាជាតិប្រកាសឲ្យមនុស្សគោរពសិទ្ធិមនុស្សនៅឆ្នាំ១៩៤៨ ចំណែកព្រះពុទ្ធវិញប្រកាសឲ្យមនុស្សគោរពសិទ្ធិមនុស្ស រហូតឲ្យគោរពសិទ្ធិសត្វកុំឲ្យបៀតបៀននិងសម្លាប់ ដូចមានក្នុងសិក្ខាបទទីមួយនៃសីល៥ មានជាង២៥០០ឆ្នាំមកហើយ។

ក្នុងប្រវត្តិសាស្រ្តពិភពលោក ពុំឃើញព្រះពុទ្ធសាសនាបង្ហូរឈាមគ្នាកើតឡើងនៅកន្លែងណាមួយ ដោយមូលហេតុសាសនាឡើយ។ ដោយឃើញកត្តាសំខាន់ពីរប្រការនេះហើយ បានជាអង្គការសហប្រជាជាតិចាត់ទុកព្រះពុទ្ធសាសនាជាសាសនាសន្តិភាព អាចយកពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដូចជា ធម៌អហឹង្សា ធម៌ព្រហ្មវិហារ មានមេត្តា

ករុណាជាដើម ធ្វើជារូបមន្តសំរាប់បំបាត់កំហឹង ការបង្ករ ឈាមគ្នា ហើយសាងសុខសន្តិភាពជូនមនុស្សក្នុងលោក។

## ព្រះសង្ឃជាមួយសង្គមខ្មែរ

នៅប្រទេសកម្ពុជា បើមានភូមិកន្លែងណា តែងមានវត្ត ព្រះពុទ្ធសាសនាកន្លែងនោះ។ បានសេចក្តីថា វត្តព្រះពុទ្ធ សាសនាតែងមានគ្រប់ភូមិស្រុកខេត្តក្រុងនៃព្រះរាជាណា ចក្រទាំងមូល។ វត្តជាមជ្ឈមណ្ឌលរបស់ប្រជាជាតិខ្មែរ សំរាប់ សិក្សា និងប្រតិបត្តិព្រះពុទ្ធសាសនា។ តាមទំនៀមទំលាប់ ខ្មែរតាំងពីដើមមក កូនប្រុសជំទង់តែងបញ្ជូនទៅប្រគេន លោកគ្រូចៅអធិការ ដើម្បីឲ្យកូនសិក្សាអក្សរសាស្ត្រជាតិនៅ ទីវត្ត។ បន្ទាប់មក ឲ្យកូនបួសជាសាមណេរ បួសជាភិក្ខុ ដើម្បី សិក្សានិងប្រតិបត្តិព្រះពុទ្ធសាសនា ហើយចាត់ទុកជាការ បួសសងគុណមាតាបិតា។ បើអង្គខ្លះអស់និស្ស័យសឹកមក វិញ គេហៅថាអន្ទិតដែលចេញមកពីពាក្យថា បណ្ឌិត ប្រែថា អ្នកចេះដឹងនិងមានចរិយាល្អ ព្រោះអ្នកបួសបានសិក្សានិង អប់រំចិត្ត បានចេះដឹងមានចិត្តបរិសុទ្ធល្អ។ ពេលនោះ ព្រះសង្ឃ ពុំមែនសិក្សាតែព្រះពុទ្ធសាសនានិងប្រពៃណីទំនៀមទំលាប់ ខ្មែរប៉ុណ្ណោះទេ វិជ្ជាជីវៈផ្សេងៗដូចជាជាងឈើ ជាងដែក វិធី ផ្សំថ្នាំមើលជម្ងឺ របៀបគូរគំនូរជាដើម ក៏លោកសិក្សាដែរ។ ដូច្នេះបញ្ជាក់ថា ព្រះសង្ឃមានចំណេះខាងព្រះពុទ្ធសាសនា

ផ្នែកវប្បធម៌ផង វិជ្ជាជីវៈ ផ្នែកសង្គមកិច្ចផង។ ព្រះសង្ឃជាម្លប់នៃពុទ្ធបរិស័ទពេលមានវិបត្តិផ្លូវចិត្តតែងតែទៅថ្វាយបង្គំព្រះសង្ឃឲ្យជួយដោះស្រាយ។ ព្រះសង្ឃពេលខ្លះបានដើរតួនាទីជាចៅក្រមសំរុះសំរួល ការវិវាទរបស់ប្រជាពលរដ្ឋ ដែលជាជើងវត្តឲ្យស្រុះស្រួលគ្នាតាមវិធីព្រះពុទ្ធសាសនា។ ពេលខ្លះព្រះសង្ឃដើរតួជាគ្រូបង្រៀន ដោយពន្យល់ណែនាំពុទ្ធបរិស័ទចំណុះជើងវត្តរបស់ព្រះអង្គ កុំឲ្យឈ្លោះទាស់ទែងគ្នា កូនចៅឲ្យខំប្រឹងប្រែងរៀនសូត្រ ម្ដាយឪពុកឲ្យខំធ្វើការរកស៊ីប្រកបដោយធម៌ជាដើម។ ពេលខ្លះព្រះសង្ឃដើរតួនាទី ជាអ្នកផ្ដើមគំនិតកសាងសាលារៀន មន្ទីរពេទ្យ លើកដីធ្វើផ្លូវ ជីកស្រះធ្វើអណ្ដូង ជូនប្រជាពលរដ្ឋប្រើប្រាស់។ ពេលខ្លះព្រះសង្ឃដើរតួនាទីជាគ្រូពេទ្យ ដោយជួយព្យាបាលជម្ងឺរបស់ប្រជាពលរដ្ឋ ដោយថ្នាំបូរាណផ្សំនឹងពុទ្ធមន្តលើកកម្លាំងផ្លូវចិត្តផង។ ពេលខ្លះព្រសង្ឃដើរតួនាទីជាចិត្តវិទូ ដោយជួយណែនាំពន្យល់ពុទ្ធបរិស័ទដែលមានវិបត្តិផ្លូវចិត្ត ឬខូចផ្លូវចិត្ត ឲ្យជាសះស្បើយដោយឱសថគឺព្រះធម៌។ ព្រះសង្ឃខ្លះមានសមត្ថភាពបានបបួលញាតិញោមប្រមូលបច្ច័យនិងសម្ភារៈយកទៅជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរដែលរងគ្រោះដោយគ្រោះធម្មជាតិ ដូចជាទឹកជំនន់ ខ្យល់ព្យុះខូចខាតទ្រព្យសម្បត្តិ និងរាំងភ្លៀង ធ្វើឲ្យខូចខាតផលដំណាំជាដើម។ នៅតាមវត្តអារាមស្រុកស្រែចំការ ព្រះសង្ឃចិញ្ចឹមកូនប្រជាពលរដ្ឋក្រីក្រ

និងកុមារកំព្រាខ្លះ ឲ្យសំណាក់ក្នុងវត្តដើម្បីសិក្សារៀនសូត្រ។ ជាពិសេសវត្តនៅទីក្រុង មានក្រុងភ្នំពេញជាដើម ដូចជាវត្តឧណ្ណាលោម វត្តលង្កា វត្តបុទុមជាដើម មាននិស្សិតស្នាក់នៅរាប់រយនាក់ក្នុងវត្តនីមួយៗ ដើម្បីសិក្សារៀនសូត្រនៅវិទ្យាល័យនិងមហាវិទ្យាល័យ ព្រោះរដ្ឋពុំបានសង់អាគារឲ្យបានគ្រប់គ្រាន់ សំរាប់ឲ្យនិស្សិតស្នាក់នៅឡើយ ដូច្នេះហើយបានជាកូនចៅក្រីក្រទាំងនោះ មកសំណាក់នៅក្នុងវត្តដោយពុំមានលទ្ធភាពជួលផ្ទះ។ ដូច្នេះបញ្ជាក់ថា វត្តព្រះពុទ្ធសាសនាមានប្រយោជន៍សំខាន់ណាស់សំរាប់ជួយសំរួលជីវភាពការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ។

## ព្រះពុទ្ធសាសនានិងវិបត្តិនយោបាយ

អ្នកសិក្សាព្រះពុទ្ធសាសនាបានដឹងហើយថា ពាក្យប្រៀនប្រដៅដ៏សំខាន់របស់ព្រះពុទ្ធ គឺ**ធម៌អហឹង្សា** ការពុំបៀតបៀន ដែលជាមូលដ្ឋាននៃសន្តិភាពសកលលោក។ ប្រទេសកម្ពុជាបានឆ្លងកាត់វិបត្តិនយោបាយជាច្រើនប្រភេទ រហូតមានការសម្លាប់រង្គាលដូចជារាលពិឃាតខ្មែរក្រហម និងការឈ្លានពានពីបរទេស។ អំពើអមនុស្សធម៌ទាំងនេះផ្ទុយនឹងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដូច្នេះអំពើអាក្រក់នេះពុំទាក់ទងនឹងព្រះពុទ្ធសាសនាឡើយ។ ព្រះពុទ្ធពុំដែលបង្រៀនឲ្យមនុស្សទាស់ទែងគ្នា កាប់សម្លាប់គ្នា បែកសាមគ្គី

គ្នាឡើយ។ មិនថាតែមនុស្សទេដែលព្រះអង្គហាមមិនឲ្យបៀតបៀនមិនឲ្យសម្លាប់ គឺសត្វមានជីវិតទាំងអស់ ព្រះអង្គហាមមិនឲ្យសម្លាប់ដូចគ្នា។ អ្នកដែលសម្លាប់ប្រជាពលរដ្ឋខ្មែរសម័យវាលពិឃាតខ្មែរក្រហម ពុំមែនជាអ្នកព្រះពុទ្ធសាសនាឡើយ គឺជាអ្នកដើរតាមមាគ៌ាកុម្មុយនិស្ត ដែលមានបរទេសកុម្មុយនិស្តនៅពីក្រោយ។ តាមន័យនេះ គេពុំអាចចោទថាការសម្លាប់គ្នានេះ ដោយសារកាន់ព្រះពុទ្ធសាសនាឡើយ។ តាមពិតវិញ ពុទ្ធសាសនិកខ្មែរទាំងគ្រហស្ថទាំងបព្វជិត ត្រូវទទួលរងគ្រោះដោយសារពួកនេះ គឺព្រះសង្ឃត្រូវគេធ្វើគតចាប់ផ្សឹក ព្រះពុទ្ធរូប វត្តអារាម គម្ពីរក្បួនច្បាប់ ត្រូវគេបំផ្លាញចោល។ បើគេដើរតាមមាគ៌ាព្រះពុទ្ធវិញ ពិតជាការសម្លាប់គ្នាពុំកើតមានឡើយ។ ដូច្នេះ ការសម្លាប់គ្នានេះ ដោយសារការពុំដើរតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធវិញទេ។

ចំពោះប្រទេសកម្ពុជាដែលក្រីក្រវិញ ក៏គេពុំអាចបន្ទោសព្រះពុទ្ធសាសនាឡើយ ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះអង្គស្ទើរតែគ្រប់ទំព័រ បង្រៀនមនុស្សឲ្យខំប្រឹងសិក្សារៀនសូត្រនិងធ្វើការងារប្រកបដោយធម៌ ដូចប្រយោជន៍បច្ចុប្បន្ន ៤យ៉ាងគឺឧបដ្ឋានសម្បទាប្រែថាប្រកបព្រមដោយការប្រឹងប្រែងធ្វើការងារពុំខ្ជិលច្រអូសជាដើម។ មានពាក្យបាលីជាច្រើនដែលមានន័យឲ្យខំប្រឹងប្រែងដូចពាក្យថា វាយាមៈ វីរិយៈ ជាដើម។ ជិតបរិនិព្វាន ព្រះពុទ្ធប្រទានឱវាទជាចុង

ក្រោយដាស់តឿនមិនឲ្យមនុស្សប្រមាទធ្វេសប្រហែស គប្បីបំពេញសេចក្តីល្អឲ្យបានសំរេច ព្រោះសង្ខារពុំទៀងទេ។ ដូច្នេះបញ្ជាក់ថា ទោះបីព្រះអង្គជិតបរិនិព្វានមានព្រះអាពាធដ៏ធ្ងន់ក៏ដោយ ក៏ព្រះអង្គនៅតែព្យាយាមរំលឹកបន្ថែមទៀតកុំឲ្យភ្លេចស្មារតី កើតមកត្រូវតែធ្វើការងារល្អ ដើម្បីប្រយោជន៍ខ្លួននិងប្រយោជន៍សង្គម កុំឲ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍ ព្រោះពេលកន្លងទៅ អាយុក៏កន្លងទៅជាមួយដែរ ដោយសេចក្តីប្រមាទធ្វេសប្រហែសជាផ្លូវនៃមច្ចុ សេចក្តីមិនប្រមាទជាផ្លូវនៃអមតៈ។ ពាក្យថាអមតៈប្រែថាមិនស្លាប់ បានសំរេចដល់ព្រះនិព្វាន ជាអសង្ខតធម៌ជាធម៌មិនស្លាប់ គឺបុគ្គលព្យាយាមមិនប្រមាទពិចារណាសង្ខារការកើតរលត់រហូត ឃើញទោសក្នុងខ្លួន៥ មានរូបខន្ធជាដើម រមែងសំរេចព្រះនិព្វាន លែងកើតចាស់ឈឺស្លាប់។ ព្រេងនិងប្រឹងជាគូនឹងគ្នា គឺបុគ្គលបើទោះបីដឹងថា មានព្រេងវាសនាពីមុនមកហើយក៏ដោយ ក៏ត្រូវតែខំប្រឹងប្រែងព្យាយាមក្នុងបច្ចុប្បន្នទៀត ទើបសំណាងដែលបានកសាងនោះបញ្ចេញជាផលបាន។ ដូចប្រេងទៅក្នុងដូងទុំ ដើម្បីបានប្រេងគេត្រូវយកដូងទៅកោសរួចយកទៅរំងាស់ទើបចេញជាប្រេងបាន។ ប្រៀបមួយទៀតដូចបុគ្គលមានគ្រាប់ពូជមួយគ្រាប់ ដើម្បីឲ្យគ្រាប់ពូជនោះដុះជាដើមបែកមែកបញ្ចេញជាផ្លែផ្កា គេត្រូវយកគ្រាប់ពូជនោះទៅដាំលើដីដែលមានជីរជាតិ ថែទាំស្រោចទឹក កុំឲ្យសត្វវាស៊ី

ទើបសំរេចផលបាន។ ដូច្នេះ គ្រប់ពាក្យទូន្មានរបស់ព្រះពុទ្ធ គ្មានកន្លែងណាមួយដែលព្រះអង្គបង្រៀនឲ្យមនុស្សសត្វខ្ជិលច្រអូសដេកចាំសំណាងអុជធូបបន់ស្រន់ឲ្យសេចក្ដីប្រាថ្នារបស់ខ្លួនផ្ដល់ផលឲ្យខ្លួនឡើយ។ ពាក្យមួយទៀតថា សេចក្ដីសុខចំរើនគ្រប់យ៉ាងពុំមែនកើតពីមនោរថ គឺកើតពីការនឹកគិតឡើយ តែកើតពីការព្យាយាមធ្វើ ហើយក៏ពុំមែនកើតមកពីព្រះជាម្ចាស់ណាប្រទានឲ្យឡើយ គឺកើតមកអំពីអំពើល្អរបស់ខ្លួន។ ចំពោះព្រះពុទ្ធវិញ ព្រះអង្គសំដែងថា តថាគតគ្រាន់តែប្រាប់បង្ហាញផ្លូវប៉ុណ្ណោះ អ្នករាល់គ្នាត្រូវដើរដោយខ្លួនឯង។ បានសេចក្ដីថា ព្រះអង្គបង្ហាញផ្លូវល្អផ្លូវអាក្រក់ នរក សួគ៌និព្វាន មនុស្សសត្វត្រូវជ្រើសរើសផ្លូវដើរដោយខ្លួនឯង។ បើចង់ចេះត្រូវខំរៀន បើចង់បានទ្រព្យសម្បត្តិត្រូវប្រឹងប្រែងរកស៊ីប្រកបដោយធម៌ បើចង់បានសួគ៌និព្វានត្រូវខំប្រតិបត្តិធម៌ នេះជាសច្ចធម៌ ជាហេតុផលពិតដែលគេពុំអាចកែប្រែបាន ពុំមែនកើតពីអំណាចខាងក្រៅ មានកើតពីឥទ្ធិពលព្រះជាម្ចាស់ជាដើមឡើយ។ ពុទ្ធសាសនិកជនខ្មែរពុំមែនជឿព្រះពុទ្ធសាសនាដោយធ្មេចភ្នែកឡើយ គឺជឿដោយបើកភ្នែក គឺសទ្ធាការជឿដោយមានបញ្ញា ការពិចារណារកហេតុផលនៅជាមួយ។ បានសេចក្ដីថា ជឿព្រះពុទ្ធសាសនាគឺជឿការពិតដែលព្រះអង្គសំដែង ពុំមែនជឿរបៀបយល់សប្តិ របៀបនិទានរឿងដែលពុំអាចបញ្ជាក់ការពិតបាននោះឡើយ។

ដូចបានទាញយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធខ្លះមកបញ្ជាក់រួចហើយ គឺព្រះពុទ្ធបានប្រៀនប្រដៅកុំឲ្យមនុស្សខ្ជិលច្រអូស ផ្ទុយទៅវិញឲ្យខំប្រឹងប្រែងធ្វើកិច្ចការប្រកបដោយធម៌ ដើម្បីប្រយោជន៍ខ្លួននិងប្រយោជន៍សង្គម។ ប្រជាពលរដ្ឋនៃប្រទេសកម្ពុជា ធ្លាក់ខ្លួនក្រីក្រលំបាកតោកយ៉ាកនោះដោយសារវិបត្តិនយោបាយនិងអ្នកដឹកនាំរដ្ឋ ពុំបានរៀបចំក្បួនសេដ្ឋកិច្ច តាមលក្ខណៈបច្ចេកទេសឲ្យបានជាក់លាក់ព្រមទាំងបានប្រព្រឹត្តអំពើពុករលួយផង បានធ្វើឲ្យកម្ពុជាមាតុភូមិធ្លាក់ខ្លួនដុនដាបដូចសព្វថ្ងៃនេះ។ បើប្រៀបធៀបនឹងប្រទេសពីរដែលគោរពព្រះពុទ្ធសាសនា គឺប្រទេសកម្ពុជាគោរពព្រះពុទ្ធសាសនាមានភាពក្រីក្រ ចំណែកប្រទេសជប៉ុន ប្រទេសថៃ គោរពព្រះពុទ្ធសាសនាដែរ ទៅជាអ្នកមានស្តុកស្តម្ភសេដ្ឋកិច្ចលូតលាស់ តើបណ្តាលមកពីអ្វី? ភាពខុសគ្នានេះ គឺពិតជាបណ្តាលមកពីប្រទេសថៃនិងប្រទេសជប៉ុនអ្នកដឹកនាំគេចេះដឹកនាំបានល្អទាំងផ្លូវនយោបាយនិងផ្លូវសេដ្ឋកិច្ច ជាពិសេសគេចេះដកស្រង់យកព្រះគំនិតដ៏ល្អៗរបស់ព្រះពុទ្ធមកអនុវត្ត ទើបធ្វើឲ្យប្រទេសគេលូតលាស់ចំរើន។ ចំណែកអ្នកដឹកនាំខ្មែរអនុវត្តព្រះពុទ្ធសាសនាមានលក្ខណៈប្រជាភិថុតិ ជាផ្លូវនយោបាយ ពុំបានដកស្រង់យកគំនិតល្អៗរបស់ព្រះពុទ្ធមកអនុវត្តឡើយ។ របស់ល្អមានតម្លៃប៉ុន្តែគេពុំបានយកមកប្រើដើម្បីជាប្រយោជន៍ទេ របស់មាន

តម្លៃនោះក៏ពុំបានផ្តល់ផលដល់អ្នកនោះឡើយ។ យ៉ាងណាមិញ ប្រទេសកម្ពុជាគោរពព្រះពុទ្ធសាសនា ប៉ុន្តែអ្នកដឹកនាំខ្មែរពុំបានយកពាក្យព្រះពុទ្ធមកអនុវត្ត ក៏មានន័យដូចនេះដែរ។ ស្របន័យនេះដែរ ប្រទេសកម្ពុជាកើតវិបត្តិនយោបាយរហូតបង្ហូរឈាមគ្នានេះ ដោយសារអ្នកដឹកនាំខ្មែរពុំគោរពតាមធម៌ព្រះពុទ្ធ គឺព្រះពុទ្ធបានបង្រៀនមនុស្សមិនឲ្យបៀតបៀនគ្នាកាប់សម្លាប់គ្នា តែត្រូវស្រឡាញ់រាប់អានគ្នាប្រកបដោយចិត្តមេត្តានិងករុណា។ ប្រវត្តិព្រះពុទ្ធសាសនាពុំដែលធ្វើចម្បាំងឈ្លានពានគេឡើយ មានតែគេឈ្លានពានមកខ្លួនវិញ។ ចំណែក សាសនាដទៃក្រៅពីពុទ្ធសាសនាវិញ បានធ្វើចម្បាំងហើយរហូតមកដល់ពេលនេះក៏នៅតែធ្វើចម្បាំងបង្ហូរឈាមគ្នាដោយមូលហេតុសាសនារៀងៗខ្លួន។

## ២- អំពីវត្តនិងព្រះសង្ឃ ព្រះពុទ្ធសាសនាខ្មែរ

ពាក្យថា**វត្ត**ជាភាសាខ្មែរ ដែលចេញមកពីភាសាបាលីថា **វត្ថុ** ប្រែថា ទីកន្លែងសំរាក់គោរពបូជា ជាកន្លែងសំរាប់ព្រះសង្ឃគង់នៅ។ សេចក្តីថា ព្រះសង្ឃពុំអាចរស់នៅជាមួយគ្រហស្ថបានទេ គឺត្រូវរស់នៅកន្លែងមួយដាច់ដោយឡែកដែលហៅថាវត្តនេះឯង។ ក្នុងភាសាបាលីមានប្រើពាក្យមួយទៀតថា **អារាម** ប្រែថាជាទីរីករាយចិត្ត គឺបើគេមានទុក្ខកង្វល់ផ្លូវចិត្ត ពេលណាគេចូលវត្តបានទាញអារម្មណ៍គេឲ្យរីករាយផ្លូវចិត្តក្នុងភាពស្ងប់ ព្រោះវត្តជាទីរម្ងាប់នូវអំពើបាបនិងការកង្វល់ផ្លូវចិត្ត។ ក្រៅពីព្រះសង្ឃ វត្តមាវត្ថុជាទីគោរពសក្ការៈដូចជាព្រះពុទ្ធរូប គម្ពីរព្រះត្រៃបិដកជាដើម។ គេសង្កេតឃើញ នៅប្រទេសកម្ពុជា បើមានភូមិនៅកន្លែងណា តែងតែមានវត្តព្រះពុទ្ធសាសនានៅកន្លែងនោះ និងនៅតាមទីក្រុងក៏មានវត្តដូចគ្នា។ ពុទ្ធសាសនិកជនខ្មែរ ទុកវត្តអារាមជាទីគោរពបូជារួមគ្នាក្នុងការបំពេញបុណ្យទាន និងការរម្ងាប់អំពើបាប។

ពាក្យថា **ព្រះសង្ឃ** ប្រែថា ក្រុមឬពួក ដែលចេញមកអំពីភាសាបាលីថា **សង្ឃោ** បានដល់ក្រុមឬពួករបស់បព្វជិត ឬ អ្នកបួស គឺភិក្ខុនិងសាមណេរ ដែលជាអ្នកលះបង់ពីភេទជាគ្រហស្ថមកបួសជាឧត្តមភេទកាន់ព្រះពុទ្ធសាសនាមានកំ

រិតខ្ពស់ ព្រោះឃើញភ័យក្នុងវដ្តសង្សារពីការកើតចាស់ឈឺស្លាប់ ហើយរស់នៅក្រោមធម៌វិន័យរបស់ព្រះពុទ្ធ។ ព្រះសង្ឃព្រះពុទ្ធសាសនាមានភារកិច្ចពីរយ៉ាងគឺ សិក្សាធម៌វិន័យរបស់ព្រះពុទ្ធឲ្យបានយល់ច្បាស់ និងប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ។ ក្រៅពីនោះ ព្រះសង្ឃមានតួនាទីមួយទៀត គឺការយកធម៌វិន័យរបស់ព្រះពុទ្ធ មកពន្យល់ណែនាំពុទ្ធបរិស័ទ ឲ្យបានយល់ច្បាស់ និងប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ។ ដូច្នេះ ព្រះសង្ឃជាភេទពិសេស ជាភេទបរិសុទ្ធ អាចមានឱកាសប្រតិបត្តិធម៌សីលសមាធិបញ្ញា និងផ្សព្វផ្សាយ ព្រមទាំងរក្សាការពារព្រះពុទ្ធសាសនាបានច្រើនជាងគ្រហស្ថ។ ព្រះសង្ឃស្ថិតនៅក្នុងបាវចនាទាំងបីនៃព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដែលពុទ្ធបរិស័ទខ្មែរ យកជាទីពឹងទីរំលឹកស្មើដោយជីវិតរបស់ខ្លួន ដូចបាលីសូត្រនមស្សការថា នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ ធម្មោ សង្ឃោ មេ សរណំ វរំ ប្រែថា វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាពុំមានឡើយ មានតែព្រះពុទ្ធព្រះធម៌និងព្រះសង្ឃជាទីពឹងទីរំលឹកស្មើដោយជីវិតរបស់ខ្ញុំព្រះករុណា។ ដូច្នេះ ព្រះសង្ឃជាទីគោរព ត្រូវប្រើពាក្យហៅព្រះសង្ឃ ក៏ឲ្យបានសមរម្យដែរ គឺត្រូវប្រើពាក្យថា «**ព្រះសង្ឃ**» កុំប្រើពាក្យថា «**លោកសង្ឃ**»ដូច្នេះឡើយ ព្រោះពាក្យថា លោក គេមានប្រើសំរាប់ហៅគួរសមជាមួយគ្រហស្ថ ដូចហៅឈ្មោះលោកនេះលោកនោះជាដើម។ ការហៅដោយមិនប្រើ

ពាក្យ«**ព្រះ**» នៅខាងដើម ជាពាក្យហៅខ្វះការគោរពចំពោះព្រះសង្ឃ។ ព្រះសង្ឃជាឧត្តមភេទ មានគុណធម៌មានសីលគុណជាដើម ជាអ្នកលះបង់អំពើអាក្រក់អស់ហើយ បានដល់អរិយសង្ឃ និងព្រះសង្ឃកំពុងព្យាយាមលះបង់បានដល់សម្មតិសង្ឃ។

វត្តអារាមព្រះពុទ្ធសាសនាខ្មែរ ពុំមែនត្រឹមតែជាមជ្ឈបណ្ឌល សំរាប់គោរពប្រតិបត្តិព្រះពុទ្ធសាសនាប៉ុណ្ណោះទេ លើសពីនេះ ជាមជ្ឈមណ្ឌលសំរាប់រក្សានូវវប្បធម៌ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ប្រពៃណីទំនៀមទំលាប់គ្រប់ផ្នែករបស់ខ្មែរ។ ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ តែងតែស្តាប់ឱវាទព្រះសង្ឃថៅអធិការ អំពីកិច្ចការព្រះពុទ្ធសាសនា ក៏ដូចជាជីវភាពប្រចាំថ្ងៃ ដូចជាការរំលឹកដាស់តឿន ឲ្យខំប្រឹងប្រកបការងារដោយសុចរិត ដោយមិនដេកចាំសំណាង កុំទាស់ទែងខ្វែងគំនិតគ្នារវាងប្តីប្រពន្ធ និងអ្នកជិតខាងជាដើម។ ប្រជាពលរដ្ឋពុទ្ធបរិស័ទខ្មែរ ទុកព្រះសង្ឃជាគ្រូរបស់ខ្លួន ដែលខ្លួនគប្បីស្តាប់ឱវាទ។ កូនចៅប្រុសជំទង់ខ្មែរខ្លះ ត្រូវបានម្តាយឪពុកយកទៅទុកក្នុងវត្តដើម្បីសុំព្រះសង្ឃជួយអប់រំខាងសីលធម៌ ហើយឲ្យបួសជាសាមណេរជាភិក្ខុ បើសឹកមកវិញ គេហៅថាអន្ទិត ដែលក្លាយមកពីពាក្យបណ្ឌិត ដែលប្រែថាអ្នកចេះដឹង។ កូនចៅខ្មែរអ្នកស្រែចំការដែលក្រីក្រ បានមកសំណាក់នៅក្នុងវត្ត ជាពិសេសវត្តនៅទីក្រុង ដើម្បីបន្តការសិក្សានៅអនុវិទ្យាល័យ និងមហា

វិទ្យាល័យរបស់រដ្ឋ ព្រោះរដ្ឋពុំបានរៀបចំឲ្យមានផ្ទះសំរាប់និស្សិតស្នាក់នៅឡើយ។ ក្រៅពីនោះ ព្រះសង្ឃបានជួយកិច្ចការខាងសង្គមកិច្ចជាច្រើនទៀត ដូចជាធ្វើជាអ្នកដឹកនាំកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ជាដើម។

ពុទ្ធសាសនិកជនខ្មែរចាត់ទុកវត្តអារាមនិងព្រះសង្ឃជាទីកន្លែងនិងបុគ្គលដែលខ្លួនគប្បីគោរពបូជា។ ដូច្នេះហើយបានជាពេលចូលវត្ត បើមានពាក់មួកតែងដោះមួក ពេលចូលវិហារ និងកន្លែងមានព្រះពុទ្ធរូប បើពាក់ទ្រនាប់ជើង តែងតែដោះចេញ ហើយថ្វាយបង្គំដោយសេចក្តីគោរព។ កាលជំនាន់ដើម បើមានមនុស្សមានការភិតភ័យអំពីបញ្ហាអ្វីមួយរត់ចូលវត្ត ប៉ូលិសមិនហ៊ានចូលលុកលុយចាប់មនុស្សក្នុងវត្តឡើយ ដោយការគោរពទីវត្ត និងគោរពព្រះសង្ឃ ព្រោះអ្នករត់ចូលវត្តគឺរត់រកទីពឹងពីការគំរាមកំហែងបែបណាមួយ។ ប្រៀបដូចមនុស្សរត់ទៅក្រៅប្រទេស ឬរត់ចូលស្ថានទូតណាមួយ ដើម្បីគេចពីការគំរាមគំហែងដល់ជីវិតពីរដ្ឋាភិបាលផ្តាច់ការ ដែលអង្គការសហប្រជាជាតិមានច្បាប់សំរាប់ការពារជនមានលក្ខណៈបែបនេះ។ សម័យពុទ្ធកាល ក្នុងបិដកខ្មែរភាគទី៦ក៏មាននិយាយថា ព្រះបាទពិម្ពិសារបានអនុញ្ញាតដល់ជនដែលមានទោសហើយរត់មកបួសមិនឲ្យបុគ្គលណាមួយធ្វើទោសដល់ជននោះឡើយ ដោយព្រះរាជឱង្ការថា ជនទាំងឡាយណាដែលបួស ក្នុងសំណាក់សមណសក្យបុត្រ ជនដទៃធ្វើទោស

អ្វីមួយដល់ពួកនេះមិនបានឡើយ ព្រោះថាធម៌ព្រះដ៏មានព្រះភាគទ្រង់សំដែងល្អហើយ ជននោះចូរខំប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ ត្រង់ចំណុចនេះ គួរពិចារណាព្រះវិន័យ ត្រង់បញ្ញាខន្ធថា ព្រះពុទ្ធមិនអនុញ្ញាតឲ្យបុគ្គល ដែលជំពាក់បំណុលគេ បុគ្គលមានទោសបួសឡើយ ព្រោះដើម្បីកុំឲ្យមានរឿងរ៉ាវក្នុងសហគមន៍ព្រះសង្ឃ។

ពោលដោយសង្ខេប វត្តនិងព្រះសង្ឃជាមូលដ្ឋាននៃវប្បធម៌ខ្មែរ ឬជាព្រលឹងអត្តសញ្ញាណខ្មែរ ស្ថិតនៅក្នុងចិត្តគំនិតខ្មែរជានិច្ច ដែលពុំអាចបំបែកបាន។ ភ័ស្តុតាង ខ្មែរក្រហមបានបំផ្លាញព្រះពុទ្ធសាសនាដល់ឫសគល់ តែវាត្រូវបរាជ័យខ្លួនឯង ចំណែកព្រះពុទ្ធសាសនាស្ថិតនៅក្នុងចិត្តគំនិតខ្មែរដដែល។ ឥឡូវនេះ សាសនាដទៃកំពុងវាយលុក បំផ្លាញព្រះពុទ្ធសាសនាជំនួសខ្មែរក្រហម សូមពុទ្ធសាសនិកជនខ្មែរប្រុងប្រយ័ត្ន។

## ៣- ព្រះសង្ឃជាគ្រូអប់រំសីលធម៌

សម័យមុន សាលារៀនស្ទើរតែទាំងអស់ផ្នែកបឋមសិក្សានៃក្រសួងអប់រំស្ថិតនៅក្នុងវត្ត។ ព្រះសង្ឃជាអ្នកបង្រៀនខាងអក្សរសាស្ត្រខ្មែរផងអប់រំសីលធម៌ផងដល់កុមារាកុមារីខ្មែរ។ មានយុវជនខ្លះបានចូលបួសជាសាមណេរជាភិក្ខុ ដើម្បីអប់រំបន្ទុំចិត្តក្នុងព្រះធម៌ព្រះពុទ្ធសាសនាដើម្បីមគ្គផលនិព្វានជាការចេញចាកទុក្ខមានជាតិទុក្ខជាដើម។ បើលោកអស់និស្ស័យសឹកមកវិញ ក៏បានជាពលរដ្ឋខ្មែរដ៏ល្អរបស់ប្រទេសដែរ។ ទំនៀមបួសនេះ ដោយខ្មែរយល់ថា បើកូនឬចៅបានបួសជាសាមណេរទុកជាសងគុណម្តាយ បើបានបួសជាភិក្ខុទុកជាសងគុណឪពុក។ ឥឡូវនេះសាលារៀនបានចាកចេញពីវត្តដោយការលូតលាស់របស់ប្រទេស សូម្បីគ្រូបង្រៀនក៏មានភេទជាគ្រហស្ថដែរ។

ឥឡូវនេះ ការអប់រំសីលធម៌បានវិលត្រឡប់ទៅរកសម័យដើមវិញខ្លះហើយ ដោយអាជ្ញាធរខ្មែរអនុញ្ញាតឲ្យព្រះសង្ឃទៅអប់រំសីលធម៌ដល់សិស្សទាំងឡាយនៅក្នុងថ្នាក់រៀនតែម្តង មានកន្លែងខ្លះ ព្រះសង្ឃបានធ្វើកម្មវិធីអប់រំសិស្សជាក្រុមនៅតាមអនុវិទ្យាល័យនិងមហាវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា។ ប៉ុន្តែការអប់រំនៅតាមថ្នាក់រៀនក្តី អប់រំជាក្រុមក្តីពុំទាន់មានលទ្ធភាពអនុវត្តបានទូទៅនៅឡើយ ដោយ

ខ្វះព្រះសង្ឃជាគ្រូអប់រំផង ខ្វះថវិកាសំរាប់ឧបត្ថម្ភព្រះសង្ឃទៅអប់រំផង។ មួយទៀត ព្រះសង្ឃនៅទន់ខ្សោយមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទៅអប់រំដូចជាមុននឹងចេញទៅអប់រំត្រូវរៀនវិជ្ជាគរុកោសល្យជាដើម។ កង្វះសម្ភារៈចាំបាច់មួយទៀត គឺអត្ថបទយកទៅអប់រំស្របតាមកម្រឹតថ្នាក់រៀនផង។ ដូច្នេះ ព្រះសង្ឃគួររកមធ្យោបាយដោះស្រាយកង្វះខាតទាំងនោះ ដើម្បីឲ្យការអនុវត្តប្រព្រឹត្តទៅបានគ្រប់ភូមិសិក្សាទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ព្រោះការអប់រំសីលធម៌ជាការចាំបាច់ណាស់ ដោយប្រទេសកម្ពុជាមានសីលធម៌ធ្លាក់ចុះ ទើបកើតមានអំពើហឹង្សាគ្រប់យ៉ាង បន្ទាប់ពីកើតមានសង្គ្រាមពីរបីទសវត្សរ៍មក។

ក្រសួងអប់រំនិងសប្បុរសជនគប្បីជួយកសាងអាសនៈនិងព្រះពុទ្ធរូបមួយព្រះអង្គៗតាំងនៅគ្រប់អនុវិទ្យាល័យ សកលវិទ្យាល័យនៃព្រះរាជាណាចក្រទាំងមូល ទុកជានិមិត្តរូបនៃព្រះពុទ្ធសាសនា និងដើម្បីឲ្យសិស្សនិងនិស្សិតទាំងនោះពេលថ្វាយបង្គំមានអារម្មណ៍មូលទៅរកព្រះពុទ្ធរូបនោះ។ ប្រទេសថៃនិងប្រទេសស្រីលង្កាក៏មានតាំងព្រះពុទ្ធរូបនៅក្នុងព្រះស្តូបនៅមុខអាគារសិក្សាទាំងអស់ដូចនេះដែ។

មួយទៀត ព្រះសង្ឃចៅអធិការគួរអប់រំជាចាំបាច់ចំពោះកូនសិស្សទាំងឡាយ ដែលសំណាក់នៅក្នុងវត្តនៃរាជធានីភ្នំពេញ និងទីក្រុងនានាតាមខេត្ត ក៏ដូចជាសំណាក់នៅតាម

វត្តស្រុកស្រែចំការ ឲ្យកូនសិស្សទាំងនោះមានសុជីវធម៌ និងមានសីលធម៌តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដូចជាឲ្យមានសីល៥ កុំប្រព្រឹត្តធ្វើអំពើអបាយមុខ ខំប្រឹងសិក្សារៀនសូត្រ គោរពមាតាបិតា គោរពអ្នកមានសីល គោរពចាស់ព្រឹទ្ធាចារ្យ ជាដើម។ សិស្សដែលនៅជិតខ្លួនមិនបានអប់រំ ទុកដូចនៅឆ្ងាយពីខ្លួន នឹងមិនដឹងរសជាតិនៃព្រះធម៌ឡើយ ប្រៀបដូចវែកនៅក្នុងសម្លរមែងមិនដឹងរសជាតិនៃសម្លដូច្នោះដែរ។ បើសិស្សជាយុវជនទាំងនោះបានយល់ព្រះពុទ្ធសាសនាច្បាស់លាស់តាមរយៈការអប់រំ ហើយបានអនុវត្តជាទម្លាប់តាំងពីបឋមវ័យមក ព្រះពុទ្ធសាសនានឹងបានចំរើនរុងរឿងស្ថិតនៅរឹងមាំ ដោយសារយុវជនជាធនធានមនុស្សបានគោ-រពតាមបន្តពីបុព្វបុរសរបស់ខ្លួន។

## ៤- អំពីព្រះសង្ឃនិងការបោះឆ្នោត

ព្រះសង្ឃព្រះពុទ្ធសាសនាថេរវាទ ជាពិសេសព្រះសង្ឃខ្មែរមានវិន័យតឹងជាងព្រះសង្ឃពុទ្ធសានាមហាយាន។ ក្នុងបណ្តាព្រះសង្ឃថេរវាទទៀតសោត ព្រះសង្ឃខ្មែរមានវិន័យតឹងជាងព្រះសង្ឃថេរវាទប្រទេសដទៃទៀត។ ព្រះសង្ឃពុទ្ធសាសនាថេរវាទរស់នៅបានដោយអាស្រ័យសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ។ នៅក្នុងព្រះវិន័យ មិនឃើញមានចែងថាព្រះពុទ្ធបានអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឡើយ។ សូម្បីរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាឆ្នាំ ១៩៧០ ដែលចាត់ទុកព្រះសង្ឃជាពលរដ្ឋដូចជាគ្រហស្ថដែរនោះ ក៏មិនឃើញតម្រូវឲ្យព្រះសង្ឃបោះឆ្នោតដែរ។ ចំណែកព្រះសង្ឃថេរវាទនៃប្រទេសដទៃទៀត ដូចជាព្រះសង្ឃប្រទេសថៃ ប្រទេសភូមាជាដើម ក៏មិនឃើញគេតម្រូវឲ្យបោះឆ្នោតដែរ វៀរលែងតែប្រទេសស្រីលង្កា ដែលក្នុងពេលថ្មីៗនេះ មិនត្រឹមតែអនុញ្ញាតឲ្យបោះឆ្នោតទេ ថែមទាំងព្រះសង្ឃបង្កើតជាគណបក្សនយោបាយថែមទៀត។

កាលពីឆ្នាំ១៩៩៣ មានការបោះឆ្នោតអាណត្តិទី១ ជ្រើសរើសតំណាងរាស្ត្រខ្មែរក្រោមកិច្ចចាត់ចែងរបស់អង្គការសហប្រជាជាតិ គេអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោត។ នៅឆ្នាំ ១៩៩៨ ក៏អនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោតក្នុងអាណត្តិទី២

លុះដល់អាណត្តិទី៣ឆ្នាំ២០០៣ ព្រះសង្ឃរាជគណៈមហានិកាយបានចេញសារាចរហាមមិនឲ្យព្រះសង្ឃបោះឆ្នោត។ ស្រាប់តែនៅឆ្នាំ២០០៦នេះ សម្តេចព្រះសង្ឃរាជគណៈមហានិកាយបានចេញសារាចរបើកឲ្យព្រះសង្ឃបោះឆ្នោតវិញ សំរាប់ឆ្នាំ២០០៨ក្នុងអណាត្តិទី៤ឯសារាចរដែលចេញមុនមិនឲ្យព្រះសង្ឃបោះឆ្នោតនោះទុកជាមោឃៈ។ ម្តងបើកម្តងបិទនេះជាលក្ខណៈនយោបាយ ពុំមែនធ្វើតាមព្រះវិន័យឡើយ។

គ្រប់គណបក្សនយោបាយបំណងចង់ឲ្យព្រះសង្ឃបោះឆ្នោត ព្រោះគណបក្សនីមួយៗយល់ថា ព្រះសង្ឃនឹងបោះឆ្នោតឲ្យគណបក្សរបស់ខ្លួន ប៉ុន្តែគេមិនបានគិតឲ្យម៉ត់ចត់ថា បើឲ្យព្រះសង្ឃបោះឆ្នោតបែបនេះ តើនាំឲ្យព្រះពុទ្ធសាសនាមានផលវិបាកអាក្រក់បែបណាទេ គឺបំណងទាញយកផលប្រយោជន៍ពីព្រះសង្ឃ តាមរយៈការបោះឆ្នោតតែប៉ុណ្ណោះ។ គេចាត់ទុកព្រះសង្ឃមានសិទ្ធិស្មើគ្នា ដូចជាប្រជាពលរដ្ឋជាគ្រហស្ថ ប៉ុន្តែគេពុំបានគិតអំពីឋានៈនិងគុណធម៌ផ្សេងគ្នាទេ។

ផ្នែកវិជ្ជមាន បើព្រះសង្ឃបោះឆ្នោត គេចាត់ទុកថាព្រះសង្ឃ បានបំពេញកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋកម្ពុជាក្នុងការចូលរួមក្នុងសង្គម ជាមួយពុទ្ធបរិស័ទជាគ្រហស្ថ ក្នុងកិច្ចបញ្ចេញមតិយោបល់ជ្រើសរើសអ្នកដឹកនាំរដ្ឋបានល្អ។ ផ្នែកអវិជ្ជមាន បើព្រះសង្ឃសំរេចបោះឆ្នោត ឈ្មោះថាព្រះសង្ឃ

បានប្រឡូកចូលធ្វើនយោបាយជាមួយគ្រហស្ថមួយផ្នែក ដែលធ្វើឲ្យគុណធម៌របស់ព្រះសង្ឃ ដែលធ្លាប់គេគោរព បានធ្លាក់ចុះមានកំរិតស្មើនឹងគ្រហស្ថ។ ព្រះសង្ឃនិងព្រះសង្ឃបែកបាក់គ្នា ដោយសារគាំទ្រគណបក្សផ្សេងគ្នា។ វត្តនីមួយៗត្រូវបែងចែក ដោយសារការគាំទ្រគណបក្សផ្សេងៗគ្នា គឺវត្តនេះរបស់គណបក្សឈ្មោះនេះ វត្តនោះរបស់គណបក្សឈ្មោះនោះ។ ព្រះសង្ឃមានទស្សនៈផ្សេងគ្នាដែលអាចមានការវិវាទរវាងព្រះសង្ឃគ្នាឯង ហើយអាចបង្កើតសត្រូវជាមួយគណបក្សណា ដែលព្រះសង្ឃមិនបានគាំទ្រថែមទៀត។ ដូច្នេះ ព្រះសង្ឃអស់ភាពជាកណ្តាល ដោយសារការប្រកាន់គណបក្សរៀងៗខ្លួននេះឯង។

តើគេអាចសង្ឃឹមថា ការបោះឆ្នោតអាណត្តិទី៤ ឆ្នាំ២០០៨នេះ មិនដូចអាណត្តិមុនៗទេ? តើអ្នកនយោបាយមានភាពចាស់ទុំហើយឬនៅ? ព្រះសង្ឃអាចបោះឆ្នោតបានដោយសេរី និងយុត្តិធម៌ ទោះបីបោះឆ្នោតឲ្យគណបក្សណាមួយតាមឆន្ទៈរបស់លោក គ្មានការគំរាមកំហែងដូចមុនទៀតទេ? នយោបាយមានភាពប្រាកដនិយម ពុំមែនធ្វើដោយការនឹកស្មានដូចយល់សប្តិឡើយ។

ដើម្បីសក្ខីភាពសំរាប់ការពិចារណា សូមលើកយកឧទាហរណ៍ពីរបី។ នៅប្រទេសឥណ្ឌា សតវត្សរ៍ទី១៥ ព្រះពុទ្ធសាសនាបានត្រូវរលាយនៅក្នុងប្រទេសកំណើតរបស់ខ្លួន

ក្រៅពីសាសនាឥស្លាមមកបំផ្លាញព្រះពុទ្ធសាសនា មានដុត ពុទ្ធិកសកលវិទ្យាល័យនាលន្ទាជាដើម ព្រះសង្ឃខ្លួនឯងក៏ បានបន្ធូរបន្ថយវិន័យ ប្រព្រឹត្តធម៌តាមគ្រហស្ថ ដែលបន្ថែម ទម្ងន់ឲ្យការវិនាសនោះប្រព្រឹត្តទៅកាន់តែរហ័សថែមទៀត។ ព្រះសង្ឃស្រីលង្កាដែលបង្កើតគណបក្សនយោបាយ រហូត ប្រណាំងប្រជែងឲ្យគេបោះឆ្នោត ដែលលទ្ធផលបានទទួល តំណាងរាស្ត្រ៦, ៧នាក់។ ពេលជជែកគ្នានៅក្នុងសភាជាតិ មានការប្រើសំដីវាយប្រហារគ្នា ប៉ះទង្គិចដល់ព្រះសង្ឃរហូត ប្រើហឹង្សាតាមផ្លូវកាយទៀតផង។ នៅកម្ពុជាក្រោម វៀតណាម បានបង្ខំឲ្យព្រះសង្ឃខ្មែរធ្វើស្រែ ឲ្យចិញ្ចឹមសត្វពាហនៈដូចជា គ្រហស្ថ គឺធ្វើតាមរបៀបព្រះសង្ឃពុទ្ធសាសនាមហាយាន ក្នុងបំណងបន្ថយតម្លៃព្រះពុទ្ធសាសនាថេរវាទ យូរទៅពុទ្ធ បរិស័ទខ្មែរនឹងឈប់គោរពបូជា ពុទ្ធសាសនានឹងត្រូវលោយ ព្រោះព្រះសង្ឃពុទ្ធសាសនាថេរវាទរស់នៅដោយបច្ច័យ៤ របស់ពុទ្ធបរិស័ទបូជា។ ពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លាដោយ សារព្រះសង្ឃលះបង់អកុសលនិងលះបង់កិច្ចកង្វល់មាន កម្រឹតខ្ពស់។

ដូចនេះ ព្រះសង្ឃដែលមានស្ថាប័នរបស់ខ្លួន ត្រូវតែ ស្ថិតនៅឯករាជ្យ កុំធ្វើតាមការអូសទាញរបស់អ្នកនយោបាយ ត្រូវរក្សាតម្លៃនិងផលប្រយោជន៍របស់ខ្លួន។ បានសេចក្តីថា ត្រូវពង្រឹងព្រះពុទ្ធសាសនាឲ្យរឹងមាំនិងល្អូតលាស់ថែមទៀត។

សំណើដែលទាក់ទងនឹងព្រះពុទ្ធសាសនារបស់រដ្ឋាភិបាល ដូចជាសំណើឲ្យព្រះសង្ឃបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រជាដើម ត្រូវតែប្រជុំព្រះសង្ឃបញ្ញវ័ន្តពិចារណាឲ្យបានល្អិតល្អន់ តើការអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោត នាំឲ្យខូចតម្លៃព្រះពុទ្ធសាសនាឬយ៉ាងណា? សូមកុំគិតថា ចង់ឲ្យព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរបោះឆ្នោតព្រោះសាសនាដទៃនៅកម្ពុជាគេឲ្យអ្នកបួសគេបោះឆ្នោត ដើម្បីកុំឲ្យចាញ់ប្រៀបគេ។ សូមក្រឡេកមើលឲ្យច្បាស់ អ្នកបួសគេគ្មានវិន័យតឹងរ៉ឹងទេ គេអាចធ្វើអ្វីបាន ដូចជារឿងនយោបាយ ការធ្វើជំនួញជួញដូរគ្រប់យ៉ាងបាន គេរស់នៅដោយខ្លួនគេបាន។ ចំណែកអ្នកបួសពុទ្ធសាសនាថេរវាទខ្មែរវិញមានវិន័យតឹងរ៉ឹង ពុំអាចធ្វើការរកស៊ីដូចជាគ្រហស្ថបានទេ រស់នៅដោយសទ្ធាពុទ្ធបរិស័ទ បើធ្វើឲ្យខូចសទ្ធាពុទ្ធបរិស័ទ ព្រះសង្ឃពុំអាចរស់នៅបានឡើយ។ វិន័យខ្លះ ព្រះពុទ្ធបញ្ញត្តិហាមដោយមានការរិះគន់ពីពុទ្ធបរិស័ទ។ ឥឡូវនេះ ព្រះពុទ្ធបរិនិព្វានបាត់ទៅហើយ ពុំអាចទូលសួរព្រះអង្គថា តើអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោត ឬពុំអនុញ្ញាតទេ។ ដូច្នេះ មានតែព្រះសង្ឃឈរលើជំហរខ្លួនឯងដោយពិចារណាមើលឲ្យគ្រប់ជ្រុងជ្រោយ ស្របតាមកាលៈទេសៈដោយគិតពីផលប្រយោជន៍និងពីតម្លៃព្រះពុទ្ធសាសនា។

ល្អបំផុត ព្រះសង្ឃត្រូវស្ថិតនៅជាកណ្តាលរវាងគណបក្សទាំងអស់ ដោយយកគណបក្សទាំងអស់ជាមិត្ត។ ធ្វើដូច្នេះ

អាចមានឥទ្ធិពលណែនាំគ្រប់គណបក្សទាំងអស់ ឲ្យស្ថិតនៅក្នុងធម៌សុចរិតប្រកបដោយសាមគ្គីធម៌។ អាចណែនាំឲ្យបោះឆ្នោតប្រកបដោយសេរីនិងយុត្តិធម៌។ បើលំអៀងទៅម្ខាង អ្នកម្ខាងទៀតគេពុំស្តាប់ការណែនាំនោះទេ។ ព្រះសង្ឃគួរតាំងខ្លួនជាតំណាងយុត្តិធម៌ បើទៅប្រឡូកជាមួយគេ តំណាងយុត្តិធម៌របស់ព្រះសង្ឃត្រូវបាត់បង់។ គ្រប់គណបក្សទាំងអស់សុទ្ធតែជាពុទ្ធសាសនិកជន តែងតែគោរពព្រះសង្ឃ គួរតែគណបក្សនយោបាយពិចារណាអំពីបញ្ហាព្រះសង្ឃបោះឆ្នោតនេះឲ្យបានម៉ត់ចត់ កុំឲ្យតម្លៃស្ថាប័នព្រះពុទ្ធសាសនារបស់ជាតិ ដែលជាសាសនារបស់រដ្ឋសៅហ្មងឡើយ។ តាមការសង្កេតមើលឃើញថា ប្រជាធិបតេយ្យ ដែលមានការគោរពសិទ្ធិមនុស្សជាមូលដ្ឋាននៅកម្ពុជា នៅក្មេងខ្ចីណាស់ ពុំទាន់ចាស់ទុំនៅឡើយទេ។ នៅប្រទេសដែលជឿនលឿនខាងលទ្ធិប្រជាធិបតេយ្យ គេឲ្យសិទ្ធិដល់ប្រជាពលរដ្ឋពេញបរិបូណ៌ ដូចការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនេះ ទោះប្រជាពលរដ្ឋណាបោះឲ្យគណបក្សណា គេចាត់ទុកថាជារឿងធម្មតា គេគ្មានរវល់យកចិត្តទុកដាក់តាមដានអ្នកបោះឆ្នោតឡើយ។ ទោះបីមិនបោះឲ្យគេ ក៏គេនៅតែរាប់អានគ្នាដូចធម្មតា។ នេះជាអនុសាសន៍សំរាប់ព្រះសង្ឃនិងគណបក្សនយោបាយយកទៅពិចារណាមុននឹងសំរេចបញ្ហាព្រះសង្ឃបោះឆ្នោតនេះ ដើម្បីរក្សាការពារព្រះពុទ្ធសាសនាឲ្យបានគង់វង់។

## ៥- ធម៌ដែលនាំឲ្យព្រះសង្ឃសាមគ្គីគ្នា

ពុទ្ធភាសិតថា សាមគ្គី សាមគ្គានំ តបោ សុខោ ប្រែថា ការព្រមព្រៀងគ្នារបស់អ្នកព្រមព្រៀងគ្នាទាំងឡាយជាតបធម៌នាំឲ្យបានសេចក្ដីសុខ។ មានអត្ថន័យថា សង្គមណាក៏ដោយ បើមានការព្រមព្រៀងគ្នាដោយកាយវាចាចិត្តហើយ សង្គមនោះរមែងបាននូវសេចក្ដីសុខ។ មូលហេតុដែលនាំឲ្យកើតសាមគ្គី សូមលើកយកតែធម៌មួយជាចំបង គឺបើព្រះសង្ឃគោរពព្រះវិន័យ បើគ្រហស្ថគោរពច្បាប់ជាតិនិងច្បាប់អន្តរជាតិ នោះសាមគ្គីរមែងកើតមាន។

ចំពោះព្រះសង្ឃព្រះពុទ្ធសាសនា ព្រះពុទ្ធបានបញ្ញត្តិព្រះវិន័យទុកជាក្បួនខ្នាតសំរាប់ព្រះសង្ឃគ្រប់ព្រះអង្គប្រតិបត្តិតាមដើម្បីសេចក្ដីបរិសុទ្ធក្នុងសង្គមរបស់ព្រះសង្ឃ បើព្រះសង្ឃបរិសុទ្ធគ្រប់អង្គហើយសាមគ្គីរមែងកើតមាន កាលណាបើមានសាមគ្គីហើយ សេចក្ដីសុខរមែងកើតមាន។ ផ្ទុយទៅវិញ ព្រះសង្ឃបរិសុទ្ធនឹងមិនសាមគ្គីជាមួយព្រះសង្ឃមិនបរិសុទ្ធដែលមិនគោរពព្រះវិន័យ មានមិនធ្វើសង្ឃកម្មជាមួយជាដើម។ បើព្រះសង្ឃគ្រប់វត្តក្នុងប្រទេសកម្ពុជាគោរពព្រះវិន័យ នោះសាមគ្គីរបស់ព្រះសង្ឃរមែងកើតមានទូទាំងប្រទេសដែរ ព្រោះព្រះវិន័យទុកជាបន្ទាត់សំរាប់ព្រះសង្ឃគ្រប់ព្រះអង្គគោរពទាំងអស់គ្នា។

បើព្រះសង្ឃអង្គណាមានកំហុសត្រូវអនុវត្តតាមព្រះវិន័យ។ ព្រះសង្ឃបរិសុទ្ធពុំអាចធ្វើសង្ឃកម្មជាមួយព្រះសង្ឃមានកំហុស ឬមានកំហុសហើយពុំបានសំអាតឲ្យបរិសុទ្ធ។ ដូច្នេះបញ្ជាក់ថា សាមគ្គីធ្វើសង្ឃកម្មជាមួយគ្នារបស់ព្រះសង្ឃ កើតឡើងដោយព្រះសង្ឃគោរពព្រះវិន័យដូចគ្នា។ កិច្ចការរបស់ព្រះសង្ឃដែលហៅថាសង្ឃកម្មមានច្រើនដែលព្រះសង្ឃក្នុងព្រះពុទ្ធសាសនាត្រូវព្រមព្រៀងគ្នាធ្វើ ដូចជាធ្វើឧបោសថសំដែងបាតិមោក្ខ ធ្វើកឋិនកម្ម បវារណាកម្មជាដើម។ ពេលមានកិច្ចប្រជុំត្រូវព្រមព្រៀងគ្នាប្រជុំ និងព្រមព្រៀងគ្នាក្រោកចាកការប្រជុំជាដើម។ ដូច្នេះ បើព្រះសង្ឃទាំងអស់អង្គគោរពព្រះវិន័យ សាមគ្គីរមែងកើតឡើង។

# ៦- អត្ថន័យនៃការសូត្រធម៌ របស់ព្រះសង្ឃ

មុខងាររបស់ព្រះសង្ឃពុទ្ធសាសនាថេរវាទ ជាពិសេស ព្រះសង្ឃខ្មែរមានមុខងារពីរយ៉ាង គឺការសិក្សាឲ្យយល់ពាក្យ ប្រៀនប្រដៅរបស់ព្រះពុទ្ធ និងប្រតិបត្តិឲ្យបានល្អត្រឹមត្រូវ តាមធម៌វិន័យ។ តួនាទីជាចាំបាច់មួយទៀត គឺការពន្យល់ពុទ្ធបរិស័ទខ្មែរ ឲ្យយល់តម្លៃពុទ្ធសាសនាកាន់តែច្បាស់លាស់ឡើង។ ឱកាសដែលអាចពន្យល់នោះ គឺពេលបុណ្យទានផ្សេងៗ ព្រោះពុទ្ធបរិស័ទពុំអាចមានឱកាស មកសិក្សាធម៌វិន័យឲ្យដូចជាព្រះសង្ឃបានទេ ដោយមានកិច្ចការរវល់ក្នុងការចិញ្ចឹមជីវិតរបស់ខ្លួននិងក្រុមគ្រួសារ។ ដើម្បីបំពេញកិច្ចនេះបាន ព្រះសង្ឃដែលធ្វើជាគ្រូរបស់ពុទ្ធបរិស័ទ ត្រូវសិក្សាក្បួនគរុកោសល្យ របៀបពន្យល់ ដើម្បីឲ្យពុទ្ធបរិស័ទងាយយល់។ ការសូត្រធម៌គ្រាន់តែជាពិធីកម្មរបស់សាសនា ការសំខាន់របស់ព្រះពុទ្ធសាសនា គឺស្តាប់ធម៌បានហើយយកទៅប្រតិបត្តិតាម។

ការអភិវឌ្ឍន៍ព្រះពុទ្ធសាសនាឲ្យលូតលាស់ចំរើននិងរឹងមាំ គឺការពន្យល់ឲ្យយល់ កាលណាមនុស្សយល់ចូលចិត្តហើយ មនុស្សនឹងប្រតិបត្តិតាម កាលណាប្រតិបត្តិតាម ព្រះពុទ្ធសាសនានឹងស្ថិតនៅគង់វង់ នេះដោយសារព្រះសង្ឃបាន

បំពេញកាតព្វកិច្ចចំពោះពុទ្ធបរិស័ទ គឺការពន្យល់ដោយការធ្វើធម្មកថា ឲ្យឱវាទ និងទេសនា ពុំមែនត្រឹមតែសូត្រធម៌នោះទេ។ ការសូត្រធម៌របស់ព្រះភិក្ខុសង្ឃ ដែលជាពិធីកម្មរបស់ព្រះពុទ្ធសាសនាមានអត្ថន័យដូចតទៅ៖

## ការសូត្រធម៌ថ្វាយបង្គំ

ការសូត្រធម៌ថ្វាយបង្គំដែលហៅថា នមស្សការព្រះរតនត្រ័យ មានន័យត្រឹមតែសរសើរគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ ការសរសើរគុណដោយវាចា ការក្រាបសំពះដោយកាយ និងបង្អោនទៅដោយចិត្ត ជាកិច្ចមួយហើយរបស់ព្រះសង្ឃនិងពុទ្ធបរិស័ទ ប៉ុន្តែកិច្ចមួយទៀត ដែលជាកិច្ចសំខាន់ចាំបាច់ គឺការប្រតិបត្តិតាមធម៌វិន័យរបស់ព្រះពុទ្ធ។ បើគ្រាន់តែសូត្រសរសើរ ប៉ុន្តែមិនបានអនុវត្តតាម ឬអនុវត្តតាមមិនបានត្រឹមត្រូវ មិនឈ្មោះថា ជាពុទ្ធសាសនិកជនពេញលក្ខណៈឡើយ។

## ការនិមន្តព្រះសង្ឃសូត្រមន្ត

ការសូត្រមន្ត ឬចំរើនព្រះបរិត្ត ជាពាក្យពីរដែលគេធ្លាប់ប្រើ។ ពាក្យទាំងពីរនេះ គេប្រើផ្លាស់ប្តូរគ្នា ហើយគេអាចស្តាប់ពាក្យនេះបាន។ ពាក្យថា «បរិត្ត» តាមន័យដែលអាចារ្យសូត្រអារាធនាព្រះសង្ឃឲ្យសូត្រមន្តគឺការការពារបញ្ចៀសនូវទុក្ខសោករោគភ័យកុំឲ្យកើតមាន។ ឯពាក្យថា «មន្ត» ប្រែថាជាគ្រឿង

ប្រកបឲ្យបានសុខ។ តើការដែលព្រះសង្ឃសូត្រមន្តឬចំរើនព្រះបរិត្តនេះត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធសាសនាឬទេ? តាមការសង្កេត ការសូត្រមន្តឬចំរើនព្រះបរិត្តមានពីរប្រភេទ គឺ ប្រភេទទីមួយ ការចំរើនព្រះបរិត្តធម្មតាក្នុងឱកាសបុណ្យទានផ្សេងៗ ដូចជាការសូត្រមង្គលសូត្រ គឺជាសូត្រមួយដែលនិយាយអំពីមង្គល៣៨ប្រការជាដើម ហាក់ដូចជាពន្យល់ធម៌។ ការចំរើនព្រះបរិត្តបែបនេះ ជាការគួរមិនទាស់ខុសអ្វីឡើយ។ ប៉ុន្តែការចំរើនព្រះបរិត្តប្រភេទទីពីរមានការយល់ជ្រុលហួសអំពីអត្ថន័យរបស់ព្រះពុទ្ធសាសនា ហើយមានអង្គខ្លះសូត្រពាក្យខ្លះមិនមាននៅក្នុងព្រះពុទ្ធសាសនា គឺជាពាក្យមន្តអាគមគាថាបែបសាសនាព្រាហ្មណ៍ថែមទៀត។ ការសូត្រចំរើនព្រះបរិត្តបែបនេះ គេហៅថាសូត្រលើករាសី និងសូត្ររំដោះគ្រោះ។

## ការសូត្រលើករាសី

ការសូត្រមន្តលើករាសីនេះ បើតាមជំនឿរបស់ខ្មែរខ្លះ ហើយព្រះសង្ឃខ្លះជាអ្នកសូត្រក៏យល់ស្របតាមផង គឺគេនិមន្តព្រះសង្ឃសូត្រមន្ត នៅពេលដែលគេយល់ថាខ្លួនគេមានរាសីធ្លាក់ចុះ ដោយធ្វើការអ្វីពុំបានសំរេចចង់បានអ្វីពុំបានសំរេចដូចប្រាថ្នា។ គេយល់ថា បើនិមន្តលោកសូត្រមន្តរាសីគេនឹងឡើង ហើយធ្វើការអ្វីនឹងបានសំរេចដូចប្រាថ្នា។ ការយល់

បែបនេះ ផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ព្រះពុទ្ធសំដែងថា ចង់បានសេចក្ដីសុខចំរើនត្រូវកសាងល្អ គឺប្រព្រឹត្តអំពើជាកុសល។ ដូច្នេះរាសីឡើង តាមន័យរបស់ព្រះពុទ្ធសាសនា គឺការសាងល្អដោយកាយ វាចា និង ចិត្ត។ ថ្ងៃណាខែណាឆ្នាំណាគេសាងល្អ ថ្ងៃខែឆ្នាំនោះ ជាមង្គលមានសិរីសួស្ដីហើយ រាសីគេឡើងនៅពេលនោះឯង។ អត្ថន័យរបស់ព្រះពុទ្ធសាសនាថា ដើម្បីឲ្យប្រឡងជាប់ រកស៊ីមានបាន ត្រូវព្យាយាមប្រើបញ្ញា សិក្សាឲ្យមានជំនាញតាមមុខវិជ្ជាជីវៈនីមួយៗនោះនឹងបានសំរេចតាមបំណងពុំខាន។ ដូច្នេះ បើតាមន័យនេះ បើនិមន្តលោកសូត្រមន្ត ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌដូចពោលមកហើយទេ រាសីមិនឡើង នៅតែចុះដដែល។ ដូច្នេះ ព្រះសង្ឃដែលទទួលនិមន្តគួរតែអាណិតអាសូរដល់គ្រហស្ថ គួរជួយពន្យល់ពុទ្ធបរិស័ទខ្មែរ ដែលយល់ព្រះពុទ្ធសាសនាពុំច្បាស់លាស់ ឲ្យយល់ច្បាស់លាស់ឡើងវិញ កុំគិតតែសូត្រធម៌ដើម្បីលាភសក្ការៈឡើយ។ គួរសង្វេគមួយទៀតខ្មែរនៅបរទេសដូចជានៅសហរដ្ឋអាមេរិក បារាំង អូស្ត្រាលីជាដើម ឃើញព្រះសង្ឃពីប្រទេសកម្ពុជាដែលចេះសូត្រមន្តស្រោចទឹក (តាមពិតព្រះសង្ឃណាក៏ចេះសូត្រធម៌នេះដែរ ប៉ុន្តែឃើញឃ្លៀងឃ្លាតពីពុទ្ធសាសនាខ្លាំងពេក លោកពុំធ្វើ) នាំគ្នាឈូឆនិមន្តទៅសូត្រមន្ត ស្រោចទឹក ជាពិសេសថៅកែហាង ថៅកែភោជនីយដ្ឋាន និងអ្នកលក់ដូរផ្សេងៗ ដោយ

យល់ថា សកម្មភាពនេះធ្វើឲ្យខ្លួនរកស៊ីមានបាន ម្ល៉ោះហើយខំចំណាយប្រាក់កាសជាច្រើន ដោយសារជំនឿភ័ន្តច្រឡំនេះ។ ព្រះសង្ឃដែលតាំងខ្លួនជាគ្រូសូត្រមន្ត ស្រោចទឹក ទស្សន៍ទាយនោះ ក្នុងមួយថ្ងៃៗត្រូវគេនិមន្តវាល់ល្ងាចបួនដប់ផ្ទះស្ទើរគ្មានពេលសំរាក។ ផ្ទុយទៅវិញ ចំពោះព្រះសង្ឃអង្គណាដែលចេះធម៌អាថ៌ រហូតចេះធម៌ដែលធ្វើឲ្យមនុស្សបានសុខធ្វើមនុស្សឲ្យរៀនឆាប់ចេះដឹង ធ្វើមនុស្សឲ្យ រកស៊ីមានបាន គ្មានឃើញខ្មែរទាំងនោះនិមន្តឲ្យជួយពន្យល់ណែនាំឡើយ។ ត្រង់នេះ យើងពុំបដិសេធទាំងស្រុងថា ការសូត្រមន្តនេះគ្មានប្រយោជន៍សោះទេ បានខ្លះដែរ ត្រង់ការលើកទឹកចិត្តធ្វើឲ្យមនុស្សមានសង្ឃឹម។ ប៉ុន្តែសង្ឃឹមខ្លះ ធ្វើឲ្យមនុស្សធ្វេសប្រហែស មិនបំពេញការងារឲ្យបានម៉ត់ចត់ នាំឲ្យខូចប្រយោជន៍វិញក៏មាន។ តាមព្រះពុទ្ធសាសនា ផលសំរេចគ្រប់យ៉ាងកើតពីការព្យាយាមធ្វើ ពុំមែនកើតឡើងក្រៅពីនេះឡើយ។ សូម្បីព្រះពុទ្ធ ក៏ព្រះអង្គមិនដែលសំដែងថា តថាគតជួយអ្នកឲ្យប្រឡងជាប់ ឲ្យអ្នករកស៊ីមានបានដូច្នេះឡើយ។ ប៉ុន្តែព្រះអង្គគ្រាន់តែប្រាប់មធ្យោបាយ បង្ហាញវិធីឲ្យរៀនសូត្រចេះចាំប្រឡងជាប់ រកស៊ីមានបានប៉ុណ្ណោះ ហើយទុកឲ្យគេជឿឬមិនជឿ អនុវត្តតាមឬមិនអនុវត្តតាមដោយខ្លួនគេ។ អស្ចារ្យមួយទៀត នៅភ្នំពេញប្រទេសកម្ពុជា មានវត្តខ្លះដោយមនុស្សអ្នកសុំស្រោចទឹកច្រើនពេក ព្រះសង្ឃដែលធ្លាប់ស្រោចទឹកឲ្យគេ

បើករ៉ូប៊ីណេបន្តបំពង់ទឹកស្រោចតែម្តង។ មានព្រះសង្ឃខ្លះ នៅក្នុងនិងក្រៅប្រទេសកម្ពុជា ស្រោចទឹកឲ្យស្ត្រីនៅក្នុងទីស្ងាត់ទីកំបាំងតែពីរនាក់។ អំពើនេះខុសនឹងព្រះវិន័យធ្ងន់ណាស់ ព្រះសង្ឃត្រូវតែជៀសវាង។ បើជៀសពុំរួច គ្រាន់តែឲ្យទឹកមន្ត ហើយឲ្យគេយកទៅងូតដោយខ្លួនគេទៅ។ ទឹកពុំអាចជួយអ្វីបានឡើយ ទឹកដែលព្រះសង្ឃរលាស់ទៅកាន់ពុទ្ធបរិស័ទនោះ គ្រាន់តែជានិមិត្តរូប ជាមួយការផ្សាយមេត្តាចិត្ត ចង់ឲ្យពុទ្ធបរិស័ទបានសុខចំរើនប៉ុណ្ណោះ។ ដូច្នេះ ព្រះសង្ឃអាចទទួលការនិមន្ត ដើម្បីរក្សាប្រពៃណីនេះចុះ ប៉ុន្តែកុំឲ្យបង្គាប់គេឲ្យធ្វើអ្វីដែលផ្ទុយពីព្រះពុទ្ធសាសនា ដូចជាបង្គាប់គេឲ្យធ្វើពៃសែនខ្មោចព្រាយបិសាចជាដើម និងកុំអះអាងថាការសូត្រមន្តនេះមានភាពស័ក្តិសិទ្ធិ ក្រៅពីអំពើល្អរបស់ខ្លួនឡើយ។

## ការសូត្រមន្តរំដោះគ្រោះ

មានជំនឿមួយទៀត គឺនិមន្តព្រះសង្ឃរំដោះគ្រោះ គឺនៅពេលដែលមានទុក្ខមានជម្ងឺដម្កាត់បៀតបៀន មានបាត់បង់ទ្រព្យសម្បត្តិជាដើម។ កាលពីសម័យបូរាណ មុននឹងសូត្រមន្ត មានរៀបចំរណ្តាប់ច្រើនណាស់ ប៉ុន្តែមិនរៀបរាប់ក្នុងទីនេះទេ ព្រោះការរៀបរាប់នោះទាក់ទងនឹងជំនឿលើខ្មោចបិសាច សូមអធិប្បាយតែទៅលើសំនួរថា តើការសូត្រ

មន្តនេះអាចរំដោះទុក្ខបានឬទេប៉ុណ្ណោះ។

ព្រះពុទ្ធសំដែងថា សេចក្តីទុក្ខបែបណាមួយកើតមាន ព្រោះអំពើបាបកម្មដែលខ្លួនបានកសាង។ បើចង់មិនឲ្យមាន ទុក្ខ ត្រូវឈប់សាងអំពើបាបតទៅទៀត ហើយសាងអំពើល្អ មានកាន់សីលប្រាំជាដើម។ ជាឱកាសល្អ ព្រះសង្ឃត្រូវពន្យល់ ពុទ្ធបរិស័ទឲ្យយល់ចូលចិត្ត អំពីការរំដោះទុក្ខតាមន័យរបស់ ព្រះពុទ្ធសាសនា ពុំមែនសូត្រធម៌ឲ្យគេអស់ទុក្ខនោះឡើយ។ ព្រះសង្ឃត្រូវតែសាកសួរអំពីសេចក្តីទុក្ខ ហើយជួយដោះ ស្រាយសេចក្តីទុក្ខនោះ។ ជួនកាលសេចក្តីទុក្ខកើតពីការ ព្រួយចិត្តពីរឿងអ្វីមួយ ត្រូវជួយដោះស្រាយនូវហេតុដែលនាំ ឲ្យកើតទុក្ខ សេចក្តីទុក្ខត្រូវរំលត់ ដូចព្រះពុទ្ធបានសំដែង ធម៌ចំពោះនាងបដាចាដែលកើតទុក្ខព្រោះកូននិងប្តីស្លាប់។ ព្រះពុទ្ធពន្យល់ឲ្យដកចិត្តចេញពីជនទាំងនោះ ព្រោះពួកគេ ស្លាប់ហើយ។ នាងយល់ព្រះធម៌ បានដកចិត្តតាមការណែនាំ របស់ព្រះពុទ្ធ សេចក្តីទុក្ខត្រូវរលត់ ព្រោះសេចក្តីទុក្ខរបស់ នាង កើតអំពីសេចក្តីស្រឡាញ់។ បើមានវិបត្តិផ្លូវចិត្តបែប ណាមួយ ក៏ត្រូវប្រាប់មធ្យោបាយដោះស្រាយតាមយថាហេតុ។ បើមានជម្ងឺតាមផ្លូវកាយ ត្រូវដោះស្រាយឲ្យទៅមន្ទីរពេទ្យដើ ម្បីព្យាបាលរោគ។ ការសូត្រធម៌នោះ គ្រាន់តែលើកកម្លាំងផ្លូវ ចិត្តប៉ុណ្ណោះ។ យើងក៏ធ្លាក់គេនិមន្តឲ្យសូត្រធម៌លើករាសី សូត្រធម៌រំដោះគ្រោះដែរ បានទទួលទៅសូត្រធម៌ ប៉ុន្តែតែង

តែពន្យល់ណែនាំតាមន័យដូចពោលមកហើយ។

## ខ្សែកថានិងកន្សែងយ័ន្ត

ជំនឿខ្មែរខ្លះជំនាន់ដើម ឥឡូវនេះនៅមានខ្លះថា កថានិងកន្សែងយ័ន្ត អាចផ្ដល់សេចក្ដីសុខឲ្យគេ ជាពិសេសការពារកុំឲ្យសត្រូវបៀតបៀន ដូចជាខ្មោចបិសាចបៀតបៀនមិនបាន គេធ្វើអំពើមិនត្រូវ បើធ្វើទាហានវិញ អាចបញ្ចៀសគ្រាប់រហូតជឿថាគេបាញ់មិនត្រូវ ឬបាញ់មិនមុត។ តាមការសង្កេតការបង្កើតឲ្យមានកថានិងកន្សែងយ័ន្ត ជាពិធីសាស្ត្រមួយរបស់ចាស់បូរាណខ្មែរ ឲ្យមនុស្សធ្វើល្អ ព្រោះពេលដែលបានប្រគល់ខ្សែកថានិងកន្សែងយ័ន្តបាននិយាយថា ដើម្បីឲ្យខ្សែកថានិងកន្សែងយន្តនេះពូកែស័ក្តិសិទ្ធិត្រូវកាន់ត្រៃណាម្យកុំប្រមាទមើលងាយគេ កុំរំលោភកូនប្រពន្ធអ្នកដទៃ ជាពិសេសឲ្យកាន់សីលប្រាំ។ ដោយចង់ឲ្យខ្សែកថានិងកន្សែងយ័ន្តពូកែស័ក្តិសិទ្ធិ ក៏កាន់ត្រៃណាម្យទាំងនោះ ក៏បានសេចក្ដីសុខ។តាមពិត សេចក្ដីសុខដែលគេបានទទួលនោះ កើតឡើងពីការកាន់ត្រៃណាម្យ ពុំមែនដោយសារខ្សែកថានិងកន្សែងយ័ន្តនោះឡើយ។ នេះជាពិធីសាស្ត្រមួយផ្នែក ដែលនាំឲ្យមនុស្សធ្វើល្អ។ បានសេចក្ដីថា បើមិនកាន់ត្រៃណាម្យនោះទេ ក៏ពុំបានសេចក្ដីសុខដែរ ព្រោះបើមិនរំលោភកូនប្រពន្ធអ្នកដទៃ មិនបានលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃជាដើមទេ អ្នកដទៃឬច្បាប់រដ្ឋពុំមាន

សិទ្ធិចាប់ចងធ្វើទោសមនុស្សនោះឡើយ។ នេះជាន័យពិតរបស់ព្រះពុទ្ធសាសនាដែលពោលថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ពុំមែនបណ្ដាលមកពីខ្សែកថានិងកន្សែងយ័ន្តនោះឡើយ។ ព្រះសង្ឃអ្នកបួសក្នុងព្រះពុទ្ធសាសនាថេរវាទ ជាពិសេសព្រះសង្ឃខ្មែរ ពុំគួរអនុវត្តជំនឿនេះទេ ហើយពុទ្ធបរិស័ទខ្មែរពុំគួរជឿជំនឿនេះដែរ។ ផ្ទុយពីនេះ ត្រូវនាំគ្នាសិក្សារៀនសូត្រធម៌វិន័យ ឲ្យយល់ច្បាស់លាស់ ហើយប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ។

## ជំនឿស្នេហ៍មុខ

ស្នេហ៍មុខជាជំនឿមួយដែលគេយល់ថា បើដាក់ទៅអាចឲ្យគេស្រឡាញ់ ឲ្យគេចូលចិត្ត។ មនុស្សដែលចង់ឲ្យគេស្រឡាញ់ចូលចិត្តភាគច្រើន គឺអ្នករកស៊ីលក់ដូរ និងអ្នកដែលចង់បានគូស្រករប្រុសស្រី ដែលហៅថាដាក់ស្នេហ៍។ ជំនឿនេះក៏មានមកតាំងពីបូរាណ ឥឡូវនេះក៏នៅមានខ្លះ។ អ្នកដែលដែលតាំងខ្លួនថាចេះវិជ្ជាផ្នែកនេះ មានជាគ្រហស្ថនិងមានជាព្រះសង្ឃខ្លះ។ វិជ្ជានេះ ទាក់ទងនឹងសាសនាព្រាហ្មណ៍ មិនមែនជារបស់ព្រះពុទ្ធសាសនាឡើយ។ បើនិយាយតាមព្រះពុទ្ធសាសនាវិញ ស្នេហ៍មុខដែលនាំឲ្យគេស្រឡាញ់ចូលចិត្ត គឺសំដីទន់ភ្លន់ ចរិយាសុភាពរាបសារ ទឹកមុខញញឹមជានិច្ចជាមួយនឹងទឹកចិត្តប្រកបដោយមេត្តា ករុណា មានចិត្តល្អ

ចេះជួយទុក្ខធុរៈអ្នកដទៃ។ មិនថាតែមនុស្សទេដែលស្រឡាញ់ចូលចិត្ត សូម្បីសត្វតិរច្ឆាន ក៏ចូលមកជិតយកមនុស្សនោះជាមិត្តដែរ។ បើគ្រូដាក់ក្រមួនស្នេហ៍នៅមុខនៅមាត់ ហើយមានទឹកមុខក្រងូវ ដើរឈ្លោះគេឯង កំណាញ់ស្វិតស្វាញ ក្រមួនជួយពុំឈ្នះឡើយ ពិតជាគេស្អប់ គេចាត់ថាជាមនុស្សគ្មានអំណោយទាន។ ដូច្នេះ ព្រះពុទ្ធសាសនាបានបញ្ជាក់យ៉ាងច្បាស់ហើយថា មនុស្សដែលគេស្រឡាញ់និងស្អប់មកអំពីអំពើរបស់ខ្លួនឯងវិញទេ។ ព្រះសង្ឃមិនត្រូវអនុវត្តជំនឿបែបនេះទេ ព្រោះផ្ទុយនឹងបញ្ញត្តិរបស់ព្រះពុទ្ធ ចាត់ជាតិរច្ឆានវិជ្ជា។ ពិសេសទៅទៀត ក្នុងព្រះវិន័យនិយាយថា បើភិក្ខុណែនាំបុរសស្ត្រី ដែលគេឥតស្រឡាញ់គ្នាសោះ ឲ្យបានគ្នាជាប្តីប្រពន្ធឬជាសង្សារ ភិក្ខុនោះត្រូវអាបត្តិមួយយ៉ាងធ្ងន់។ ក៏ដូចគ្នានឹងភិក្ខុនិយាយបំបែកបំបាក់បុរសស្ត្រី ដែលគេកំពុងស្រឡាញ់គ្នាឲ្យបែកបាក់គ្នា ក៏ត្រូវអាបត្តិមួយយ៉ាងធ្ងន់ដែរ។ សមនឹងសព្វថ្ងៃនេះ នៅប្រទេសកម្ពុជា បុរសខ្លះមានប្រពន្ធច្រើនម្ល៉ោះហើយប្រពន្ធដើមប្រពន្ធចុងរកវិធីកំចាត់គ្នា ឬរកវិធីឲ្យប្តីស្រឡាញ់ខ្លួនជាងស្ត្រីមួយទៀត ហៅថារកគ្រូស្នេហ៍ ឬក៏បុរសឬស្ត្រីស្រឡាញ់អ្នកណាម្នាក់ ក៏រកគ្រូដាក់ស្នេហ៍។ បើព្រះសង្ឃអង្គណាលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់គ្រួសារគេ ដែលហៅថាដឹកញីប្រសុីឈ្មោលបែបនេះ ព្រះសង្ឃនោះពុំមែនជាសមណសក្យបុត្តឡើយ។

# ការទស្សន៍ទាយ

ការទស្សន៍ទាយនេះ មានក្បួនសំរាប់ទស្សន៍ទាយ ដែលហៅថាព្រហ្មជាតិ។ គ្រាន់តែឃើញពាក្យថាព្រហ្មជាតិ យើងឃើញថាពុំមែនជាព្រះពុទ្ធសាសនាទៅហើយ គឺចេញមកពីសាសនាព្រាហ្មណ៍ ដែលខ្មែរពីដើមធ្លាប់គោរពសាសនាព្រាហ្មណ៍ ដែលសព្វថ្ងៃហៅថាសាសនាហិណ្ឌូ នៅមានសេសសល់ជំនឿខ្លះក្នុងវប្បធម៌ខ្មែរ។ តាមការសង្កេត ការទស្សន៍ទាយក្នុងព្រហ្មជាតិនោះ គឺការទាយទៅតាមថ្ងៃខែឆ្នាំកំណើតរបស់បុគ្គលមួយរូបៗ។ ការទាយនេះ ជាការពិនិត្យសង្កេត ជាមួយនិងការប៉ាន់ស្មាន នូវថ្ងៃខែឆ្នាំដែលកើត មានត្រូវខ្លះខុសខ្លះ អាចថាត្រូវច្រើនជាងខុស ដែលមានលក្ខណៈខុសគ្នាពីព្រះពុទ្ធគឺព្រះអង្គមានញាណ ជ្រាបអំពើបុព្វចរិយារបស់មនុស្ស។ ការទស្សន៍ទាយនេះ ព្រះពុទ្ធបានហាមភិក្ខុសង្ឃមិនឲ្យអនុវត្តការទាយនេះឡើយ ព្រោះការទាយនេះចាត់ចូលជាតិរច្ឆានវិជ្ជា ទោះបីទាយដោយវិធីផ្សេងពីនេះ មានការទាយមើលក្រយៅនិងអញ្ចាញដៃក៏ដោយ ហើយបរិក្ខារឬបច្ច័យ ដែលបានមកពីការទាយនេះ ជាការបានមកមិនប្រកបដោយធម៌ឡើយ។ ពាក្យខ្មែរថា ពាក្យសត្យពាក្យសង្ឃ។ ពាក្យថាសត្យ ជាពាក្យសំស្រ្កឹត បាលីថាសច្ចៈប្រែថាពិត។ គឺព្រះសង្ឃត្រូវនិយាយពាក្យពិត។ ចំណែកការទាយ ពុំមែនពាក្យពិតទាំងអស់ឡើយ កន្លែងខ្លះផ្សំនិយាយតម្រូវចិត្តអ្នក

មកឲ្យទាយ ដើម្បីលាភសក្ការៈ។ បើគេអនុវត្តខុសខូចប្រយោជន៍គេ ដោយជឿការទាយ ព្រះសង្ឃអ្នកទាយត្រូវមានទោសដោយប្រាប់គេពាក្យពុំពិត គេយកទៅធ្វើតាមខូចប្រយោជន៍គេ។ ឧទាហរណ៍ ការទាយថា បើតាមជើងលេខ បុរសនិងស្ត្រីនេះមានជើងលេខល្អ អាចរៀបការជាប្ដីប្រពន្ធបាន។ ក្រោយពេលរៀបការហើយ ស្រាប់តែទាស់ទែងខ្វែងគំនិតគ្នាបាក់បែកគ្នា រស់នៅជាមួយគ្នាមិនកើត ដោយជឿការទស្សន៍ទាយនេះឯង។ បើព្រះសង្ឃជាអ្នកទាយត្រូវមានទោសពីរយ៉ាង គឺទីមួយត្រូវអាបត្តិមួយយ៉ាងធ្ងន់ គឺអាបត្តិសង្ឃាទិសេសដោយការទស្សន៍ទាយឲ្យគេបានគ្នាជាប្ដីប្រពន្ធ។ ទីពីរ ត្រូវមានទោសព្រោះនាំឲ្យគេទាស់ទែងគ្នាដោយការជឿការទាយរបស់ខ្លួន។ បើទាស់គ្នាមានអំពើហឹង្សាផង ព្រះសង្ឃអ្នកទាយមានទោសធ្ងន់ជាងនេះទៅទៀត។

ចំពោះការរើសគូស្រករនេះ បើការទស្សន៍ទាយតាមផ្លូវព្រះពុទ្ធសាសនាវិញ គឺត្រូវពិនិត្យមើលចរិយាមារយាទ កំរឹតវិជ្ជាចេះដឹង កាយសម្បទា ពូជអំបូរ ដោយខ្លួនឯងផ្ទាល់ តើបុរសនេះឬស្ត្រីនេះ យកមកជាគូស្រករបានល្អឬទេ។ ពាក្យខ្មែរក៏បាននិយាយថា ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្ដាន។ បានជាសម័យដើមគេឲ្យកូនប្រុសមកបំរើខាងស្រីមួយឆ្នាំពីរឆ្នាំ ក្នុងគោលបំណងខាងស្រីពិនិត្យមើលទឹកចិត្តនិងចរិយាខាងប្រុស។ ជូនកាលគេផ្ដាច់ចោល

បើខាងស្រីមិនពេញចិត្ត។ ជួនកាលគេរើសកូនប្រសារតែក្នុងភូមិជាមួយគ្នា ព្រោះធ្លាប់ស្គាល់ចិត្តគ្នា។ បើពិនិត្យមើលខ្លួនឯងហើយនៅតែខុសទៀត គេអស់ចិត្តមិនសូវស្តាយក្រោយ បើជឿទាយហើយខុសវិញ គេនឹកស្តាយខ្លាំងណាស់។ ដូច្នេះគួរទស្សន៍ទាយតាមបែបព្រះពុទ្ធសាសនា គឺពិនិត្យមើលខ្លួនឯងច្បាស់លាស់ មុននឹងសំរេចបែបណាមួយ។ នេះគ្រាន់តែជាឧទាហរណ៍រឿងមួយ។

## សេចក្តីសន្និដ្ឋាន

ដូចបានរៀបរាប់មកហើយ ពុទ្ធសាសនិកជនខ្មែរបានចាត់ទុកព្រះសង្ឃជាគ្រូ ជាទីគោរពសក្ការៈរបស់ខ្លួន។ ដូច្នេះព្រះសង្ឃគប្បីបំពេញកាតព្វកិច្ចរបស់ខ្លួនដោយពន្យល់ណែនាំពុទ្ធបរិស័ទឲ្យដើរតាមគន្លងធម៌ កុំធ្វើតាមជំនឿខ្លះដែលផ្ទុយនឹងព្រះពុទ្ធសាសនា ដូចបានពន្យល់ខ្លះមកហើយ។ ការនិមន្តសូត្រមន្តការកូន សូត្រមន្តឡើងផ្ទះ និងនិមន្តសូត្រមន្តក្នុងបុណ្យទានផ្សេងៗ ព្រះសង្ឃត្រូវនិមន្តតាមធម្មតា គ្រាន់តែធ្វើសំណូមពរថា សូមឆ្លៀតពន្យល់ធម៌អាថ៌ស្របតាមបុណ្យទាន មុននឹងចាប់ផ្តើមសូត្រធម៌។ បើពុទ្ធបរិស័ទនិមន្តដោយប្រើពាក្យថា សូមនិមន្តសូត្រមន្តលើករាសី និមន្តសូត្ររំដោះគ្រោះ ក៏គួរទទួលនិមន្ត ប៉ុន្តែមុននឹងសូត្រ សូមពន្យល់ពុទ្ធបរិស័ទឲ្យប្រើចិត្តឲ្យបានត្រឹមត្រូវតាមន័យរបស់ព្រះពុទ្ធ

សាសនា ព្រោះពុទ្ធមន្តគឺមន្តរបស់ព្រះពុទ្ធបានដល់ការយកធម៌របស់ព្រះអង្គមកប្រតិបត្តិ ទើបរាសីឡើងនិងរំដោះគ្រោះបាន។

# ៧- សាសនពិធីខ្លះ របស់ព្រះពុទ្ធសាសនាខ្មែរ

យើងបានឃើញមន្ត្រីសង្ឃចាប់ពីសម្តេចសង្ឃរាជរហូតមកដល់មន្ត្រីសង្ឃនៅទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា បានលើកព្រះហស្ត(ដៃ)សំពះគ្រហស្ថ នៅពេលដែលព្រះមហាក្សត្របូមន្ត្រីរាជការលើកព្រះហស្តនិងលើកដៃថ្វាយបង្គំ។ មន្ត្រីសង្ឃទាំងនោះ លើកព្រះហស្តសំពះតបវិញនៅក្នុងពិធីផ្សេងៗ មានពិធីនៅក្នុងព្រះរាជវាំងជាដើម។ តាមព្រះវិន័យរបស់ព្រះពុទ្ធសាសនា ពុំអនុញ្ញាតឲ្យព្រះសង្ឃអនុវត្តដូច្នេះឡើយ។ គ្រហស្ថ បានដល់ព្រះមហាក្សត្រក្តី មន្ត្រីរាជការក្តី អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភក្តី ចាត់ជាហីនភេទ ជាភេទទន់ទាប មានគុណធម៌តិច ព្រោះចិត្តជាប់ក្នុងកាមគុណ ៥គឺរូប សម្លេង ក្លិន រស សម្ផស្ស នៅគ្រប់គ្រងផ្ទះទាក់ទងនឹងប្រពន្ធកូនចៅ។ ចំណែក ព្រះសង្ឃវិញ លោកហៅថាឧត្តមភេទ ជាភេទប្រសើរខ្ពង់ខ្ពស់ឧត្តុងឧត្តម ព្រោះលោកលះបង់កាមគុណទាំង៥មិនមានប្រពន្ធកូនចៅផ្ទះសម្បែង រស់នៅទីមួយដែលហៅថាវត្ត ហើយមុខងារគឺការសិក្សាធម៌វិន័យព្រះពុទ្ធសាសនាហើយប្រតិបត្តិតាម។ ក្រៅពីនេះ ព្រះសង្ឃទេសនាធម៌វិន័យពន្យល់ពុទ្ធបរិស័ទបង្ហាញផ្លូវប្រតិបត្តិទៅកាន់សេចក្តីសុខ។ នេះជាគុណសម្បត្តិរបស់ព្រះសង្ឃដែលគ្រហស្ថ

ពុំមាន។ ដូច្នេះ ព្រះមហាក្សត្រក្តី មន្ត្រីរាជការអ្នកមានបណ្ដាស័ក្តិក្តី ទៅថ្វាយបង្គំ ព្រះសង្ឃមិនត្រូវលើកព្រះហស្តសំពះតបវិញឡើយ គ្រាន់តែគង់សង្រួមឲ្យសមរម្យតាមភេទជាសមណៈអ្នកស្ងប់រម្ងាប់បានហើយ។ ព្រសង្ឃព្រះពុទ្ធសាសនាថេរវាទនៃប្រទេសដទៃទៀត ក៏ពុំលើកព្រះហស្តសំពះគ្រហស្ថឡើយ។ ចំណែក ព្រះសង្ឃពុទ្ធសាសនាមហាយានមានលើកដៃសំពះ រហូតដល់ថ្វាយបង្គំគ្រហស្ថទៀតផង។ បើយោងតាមព្រះវិន័យព្រះពុទ្ធសាសនាផង និងយោងតាមទំនៀមទម្លាប់ខ្មែរផង មិនតម្រូវឲ្យព្រះសង្ឃលើកព្រះហស្តសំពះគ្រហស្ថឡើយ។ សូម្បីព្រះសង្ឃដូចគ្នា ពេលដែលព្រះសង្ឃខ្ចីវស្សាថ្វាយបង្គំព្រះសង្ឃដែលចាស់វស្សាមិនត្រូវលើកព្រះហស្តសំពះតបវិញឡើយ។

តាមការសង្កេត ព្រះសង្ឃដែលលើកដៃសំពះគ្រហស្ថ មិនទាន់មានអនុវត្តទូទៅនៅឡើយទេ ឃើញមានអនុវត្តតែមន្ត្រីសង្ឃនិងព្រះសង្ឃខ្លះៗប៉ុណ្ណោះ។ ព្រះសង្ឃដែលអនុវត្តបែបនេះ ដោយសារមិនចេះព្រះវិន័យ ដោយសេចក្តីខ្លាចអ្នកមានអំណាច ឬដោយរណោបរណបគួរសមចង់បានបុណ្យស័ក្តិ និងលាភសក្ការៈ។ បើមានគំនិតដូច្នេះ ពុំគួរដល់បព្វជិតទេ ចាត់ចូលក្នុងការស្វែងរកលាភឬរកបុណ្យស័ក្តិ ពុំគួរដល់សមណៈ ដែលហៅថាអនេសនៈ គឺបច្ច័យ៤បានមកមិនប្រកបដោយធម៌។ ព្រះសង្ឃសំដែងការទន់ភ្លន់សំដីសំ

ដៅរាក់ទាក់ហួសហេតុរហូតលើកព្រះហស្តសំពះគ្រហស្ថ ដោយបំណងចង់ឲ្យគេស្រឡាញ់ចូលចិត្ត ដើម្បីបានបច្ច័យ៤ មានចីវរបច្ច័យជាដើម ចាត់ជាការស្វែងរកពុំគួរដល់សមណសក្យបុត្រ។ គ្រហស្ថអ្នកចេះដឹងព្រះពុទ្ធសាសនាបានយល់រឿងនេះ ប៉ុន្តែគ្រហស្ថចេះដឹងព្រះពុទ្ធសាសនាតិចតួច មិនយល់រឿងនេះទេ ថែមទាំងចូលចិត្តឲ្យព្រះសង្ឃធ្វើថែមទៀត។ មួយទៀត គ្រហស្ថខ្លះចូលចិត្តព្រះសង្ឃដែលនិយាយកំប្លុកកំប្លែងសើចលេងឥតមានប្រយោជន៍ មិនសូវចូលចិត្តព្រះសង្ឃនឹងធឹង មិនសូវមាត់ក បើនិយាយស្ដីវិញ និយាយតែតាមធម៌វិន័យ។

គ្រហស្ថពេលឃើញព្រះសង្ឃអង្គណាមួយលើកដៃសំពះខ្លួន គួរហាមឃាត់ថា លោកម្ចាស់មិនគួរលើកព្រះហស្តសំពះខ្ញុំព្រះករុណាជាគ្រហស្ថជាហីនភេទដូច្នេះឡើយ បើមិនបានហាមឃាត់ទេ គ្រហស្ថនោះនឹងត្រូវមានទោសដោយខ្លួនពេញចិត្តទទួលការសំពះពីអ្នកមានសីល។ ប៉ុន្តែគ្រហស្ថខ្លះ ដូចជាព្រះមហាក្សត្រនិងមន្ត្រីរាជការខ្លះ ឃើញព្រះសង្ឃលើកដៃសំពះមិនឃើញមានការហាមឃាត់ឡើយ។ បើឥស្សរជនទាំងនោះ មិនបានហាមឃាត់ ថែមទាំងតាំងព្រះទ័យនិងតាំងចិត្តត្រេកអរទៀតនោះ ជាការពុំគួរដល់គ្រហស្ថដែលជាអ្នកគោរពព្រះពុទ្ធសាសនាឡើយ។ មន្ត្រីសង្ឃគួរគោរពតាមព្រះវិន័យ និងតាមទំនៀមទម្លាប់ខ្មែរ មិនគួរ

លើកព្រះហស្តសំពះមកគ្រហស្ថវិញឡើយ ដើម្បីរក្សាតម្លៃព្រះពុទ្ធសាសនាខ្មែរផង និងដើម្បីបានជាគំរូដល់ព្រះសង្ឃថ្នាក់ក្រោមផង។

បញ្ហាមួយទៀត ចំពោះព្រះសង្ឃខ្មែរតាំងពីបុរាណមក ពេលសូត្រធម៌ជូនពរគ្រហស្ថនៅគ្រប់ពិធីបុណ្យទានតូចធំជាផ្លូវការក្នុងអង្គការរដ្ឋក្តី មិនផ្លូវការជាឯកជនក្តី មិនលើកព្រះហស្តសំពះទេ។ ឥឡូវនេះ យើងឃើញមន្ត្រីសង្ឃតាំងពីថ្នាក់លើសម្តេចព្រះសង្ឃរាជចុះមកមន្ត្រីសង្ឃប្រទេសកម្ពុជាបច្ចុប្បន្ននេះ សូត្រមន្តសូត្រធម៌ជូនពរលើកព្រះហស្តសំពះ។ នេះជាការអនុវត្តខុសពីទំនៀមទម្លាប់ផ្នែកសាសនពិធីនៃពុទ្ធសាសនាខ្មែរ គឺជាវប្បធម៌ថៃនិងលាវ។ ដូច្នេះ ដើម្បីរក្សាសាសនពិធីខ្មែរឲ្យគង់វង់ ហើយមិនធ្វើតាមវប្បធម៌ថៃ គួរឈប់លើកព្រះហស្តសំពះនៅគ្រប់ពិធីសូត្រធម៌ទាំងអស់ វៀរលែងតែសំដែងធម៌ទេសនាតាំង**នមោ**បីបទខាងដើម ដើម្បីរក្សាសាសនពិធីរបៀបខ្មែរឲ្យបានគង់វង់ កុំឲ្យវប្បធម៌ថៃនិងលាវហូរចូលបាន។

បញ្ហាមួយទៀត គ្រប់ពិធីកម្មក្នុងសាសនពិធីនៃពុទ្ធសាសនាខ្មែរ មិនកាន់ខ្សែអំបោះទេ ឥឡូវនេះ ឃើញមន្ត្រីសង្ឃនៅប្រទេសកម្ពុជា ក្នុងពេលសូត្រធម៌បង្សុកូលឧទ្ទិសកុសល អភិសេកព្រះពុទ្ធរូបជាដើម មានកាន់ខ្សែអំបោះ។ ការសូត្រធម៌កាន់ខ្សែអំបោះនេះ ក៏ជាទំនៀមទម្លាប់ថៃនិង

លាវ ចំណែកព្រះសង្ឃខ្មែរតាំងពីបូរាណមកមិនដែលអនុវត្ត ដូច្នេះឡើយ។ ព្រះសង្ឃខ្មែរដែលមិនកាន់ខ្សែអំបោះក្នុង ពេលសូត្រធម៌ឧទ្ទិសកុសលដូចប្រទេសទាំងពីរនោះ ព្រោះ យល់ឃើញតាមពាក្យប្រៀប្រដៅរបស់ព្រះពុទ្ធថា ការឧទ្ទិស កុសលដល់អ្នកចែកស្ថានទៅសម្រេចនៅលើផ្លូវចិត្តរបស់ ក្រុមគ្រួសារ ពុំមែនស្ថិតនៅលើខ្សែអំបោះនោះឡើយ។ ដូច្នេះ ព្រះសង្ឃអង្គណាអនុវត្តផ្ទុយពីទំនៀមទម្លាប់ខ្មែរ គួរ ត្រឡប់ធ្វើឲ្យត្រឹមត្រូវតាមទំនៀមទម្លាប់ខ្មែរវិញ។

បញ្ហាមួយទៀត តាមទំនៀមទម្លាប់ថៃ ព្រះសង្ឃថៃ មុនចាប់ឆាន់ចង្ហាន់តែងលើកព្រះហស្តសំពះហើយសូត្រ អជ្ជៈត្រង់បដិសង្ខា ដែលព្រះសង្ឃត្រូវពិចារណាថា អាត្មា អញឆាន់ចង្ហាន់នេះពុំមែនដើម្បីផូរផង់សម្បុរដូចស្ត្រីក្នុងបុរី គឺស្ត្រីផ្កាមាសក៏ទេ ដូចអ្នកប្រដាល់ក៏ទេ តែឆាន់ចង្ហាន់នេះ ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ គឺឲ្យជីវិតរស់ដើម្បីប្រព្រឹត្ត សីលសមាធិបញ្ញាឲ្យល្អ ដូចផ្ទះត្រូវការដោយចន្ទល់ គឺសសរ ទើបតួផ្ទះស្ថិតនៅបាន។នេះជាសីល១ក្នុងបណ្តាសីលទាំង៤ របស់ភិក្ខុ គឺបច្ចយសន្និស្សិតសីល ប្រែថា សេចក្តីបរិសុទ្ធ ដោយការពិចារណានូវបច្ច័យ៤។ ដូច្នេះ ព្រះសង្ឃត្រូវពិចារ–ណាតាមផ្លូវចិត្តក្នុងពេលប្រើប្រាស់និងបរិភោគបច្ច័យ៤ ពុំ មែនបរិសុទ្ធដោយការសូត្រទេ។ ការសូត្រមិនអាចរំដោះពី តណ្ហា និងមិនអាចរួចបំណុលដែលហៅថាឥណបរិភោគ

បានឡើយ។ ការសូត្រនេះ ជាទម្លាប់ព្រះសង្ឃថៃ ឯព្រះសង្ឃខ្មែរមិនសូត្រទេ គឺពិចារណាដូចពោលមកហើយ។ មានព្រះសង្ឃខ្មែរខ្លះដែលរស់នៅថៃយូរឆ្នាំបានសូត្រដូចថៃ គួរឈប់ហើយចាប់ពិចារណាដូចទម្លាប់ខ្មែរវិញ ទើបត្រឹមត្រូវតាមព្រះវិន័យត្រង់បរិសុទ្ធដោយការពិចារណា។

## ៨- ព្រះសង្ឃខ្មែរដែលសិក្សានៅបរទេស គប្បីរក្សានូវលក្ខណៈជាព្រះសង្ឃខ្មែរ

ព្រះពុទ្ធសាសនាថេរវាទមានធម៌វិន័យបរិសុទ្ធមិនកែប្រែ គឺបន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅ ព្រះអរហន្តទាំងឡាយបានធ្វើសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទើបសរសេរជាលាយលក្ខណ៍អក្សរក្នុងគម្ពីរព្រះត្រៃបិដក ដែលពុទ្ធបរិស័ទលើកយកមកសិក្សានិងប្រតិបត្តិតាមសព្វថ្ងៃនេះ។ ប្រទេសដែលគោរពព្រះពុទ្ធសាសនាថេរ-វាទ មានប្រទេសកម្ពុជា ថៃ លាវ ភូមា ស្រីលង្កា និងជនជាតិខ្លះទៀតនៅទ្វីបអាស៊ីនិងទ្វីបអឺរ៉ុប។ ពាក្យថា ថេរវាទ ប្រែថាពាក្យរបស់ព្រះថេរៈជាព្រះអរហន្តដែលបានធ្វើសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យតាមពាក្យរបស់ព្រះពុទ្ធមិនកែប្រែ គឺព្រះពុទ្ធសំដែងយ៉ាងណា រក្សាទុកយ៉ាងនោះ។ ដូច្នេះ ប្រទេសដែលគោរពព្រះពុទ្ធសាសនាថេរវាទមានធម៌វិន័យរបស់ព្រះពុទ្ធដូចគ្នា ខុសគ្នាតែត្រង់លើកយកមកប្រតិបត្តិនិងទំនៀមទម្លាប់ពិធីកម្មនៃប្រទេសនីមួយៗផ្សេងគ្នាប៉ុណ្ណោះ។

សូមអំពាវនាវចំពោះព្រះសង្ឃខ្មែរដែលនិមន្តទៅសិក្សាព្រះពុទ្ធសាសនានៅបរទេសដែលកាន់ព្រះពុទ្ធសាសនាថេរ-វាទគប្បីរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ ព្រោះបើទោះបីកាន់ព្រះពុទ្ធសាសនាថេរវាទដូចគ្នា ប៉ុន្តែមានប្រពៃណីទំនៀម

ទម្លាប់ផ្សេងគ្នា។ ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ ដែលព្រះសង្ឃខ្មែរទៅសិក្សា គឺប្រទេសថៃ ប្រទេសស្រីលង្កា ប្រទេសភូមា និងប្រទេសឥណ្ឌា។ ចំណែក ព្រះសង្ឃខ្មែរទៅសិក្សានៅប្រទេសចិនតៃវ៉ាន់ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនាមហាយាន មានការកែប្រែធម៌វិន័យខុសគ្នាពីព្រះពុទ្ធសានាថេរវាទ។ ព្រះសង្ឃខ្មែរដែលទៅសិក្សានៅប្រទេសនោះ សូមកុំធ្វើតាមលក្ខណៈព្រះសង្ឃមហាយាន គប្បីធ្វើតាមតែលក្ខណៈព្រះសង្ឃថេរវាទជាលក្ខណៈខ្មែរ។ បានសេចក្ដីថា នាំគ្នាទៅសិក្សាយកចំណេះវិជ្ជាពីប្រទេសគេ ប៉ុន្តែត្រូវរក្សាលក្ខណៈនិងតម្លៃជាព្រះសង្ឃខ្មែរ។ មួយទៀត បើបានចំណេះវិជ្ជាហើយត្រឡប់មកមាតុប្រទេសវិញ កុំចម្លងយកទំនៀមទម្លាប់នៃប្រទេសទាំងនោះមកអនុវត្តក្នុងប្រទេសរបស់ខ្លួន ដែលនាំឲ្យបាត់បង់នូវអត្តសញ្ញាណនៃព្រះពុទ្ធសាសនាខ្មែរ។ ប្រទេសកម្ពុជាសព្វថ្ងៃនេះ មានឯកភាពល្អណាស់ក្នុងការអនុវត្តព្រះពុទ្ធសាសនា បើយកទំនៀមទម្លាប់ប្រពៃណីពីបរទេសមកអនុវត្តផ្ទុយពីទំនៀមទម្លាប់របស់ខ្លួន នាំឲ្យបែកគណៈនិកាយផ្សេងទៀត ដែលជាហេតុនាំឲ្យបង្កើតជម្លោះបែកសាមគ្គីគ្នា។

តាមការសង្កេត ព្រះសង្ឃខ្មែរកម្ពុជាក្រោមនៅតែរក្សាលក្ខណៈជាព្រះសង្ឃខ្មែរ ទោះនៅកម្ពុជាក្រោមក្តី ចូលមកគង់នៅកម្ពុជាកណ្តាលក្តី មករស់នៅបរទេសក្តី។ ចំណែកព្រះ

សង្ឃខ្មែរដែលទៅគង់នៅប្រទេសថៃអស់ពេលយូរ ត្រូវពុទ្ធបរិស័ទខ្មែរផានាមកគង់នៅសហរដ្ឋអាមេរិក កាណាដា បារាំង អូស្ត្រាលី មានព្រះសង្ឃភាគច្រើននៅមានលក្ខណៈជាព្រះសង្ឃខ្មែរ ប៉ុន្តែមានព្រះសង្ឃមួយភាគតូចបានចម្លងយកសាសនពិធីរបៀបថៃមកអនុវត្តក្នុងសង្គមខ្មែរ។ របៀបខុសគ្នានៃសាសនពិធីខ្មែរនិងថៃខុសគ្នា គឺពេលសូត្រធម៌ជូនពរពុទ្ធបរិស័ទដែលប្រគេនបច្ច័យ៤ ព្រះសង្ឃខ្មែរពុំលើកព្រះហស្តសំពះទេ ចំណែកព្រះសង្ឃថៃលើកព្រះហស្តសំពះទៅរកគ្រហស្ថ។ ព្រះសង្ឃថៃ ពេលសូត្រធម៌បង្សុកូលកាន់ខ្សែអំបោះដែលបន្តពីសពឬពីធាតុឬពីរូបថតអ្នកស្លាប់ ចំណែកព្រះសង្ឃខ្មែរមិនកាន់ខ្សែអំបោះដូច្នេះទេ ព្រោះយល់ថា ការបង្សុកូលគឺជាការសូត្រធម៌ធម្មសំវេគសំរាប់ពិចារណា ឯការឧទ្ទិសកុសល គឺសម្រេចលើគ្រូសារសពដែលផ្សាយតាមផ្លូវមនោទ្វារគឺផ្លូវចិត្ត ពុំមែនផ្សាយតាមខ្សែអំបោះទេ។ ព្រះសង្ឃថៃមុនឆាន់ចង្ហាន់តែងសូត្រអជ្ជៈ ចំណែកព្រះសង្ឃខ្មែរមិនសូត្រទេ ព្រោះយល់ថា ធម៌អជ្ជៈជាតួបច្ចវេក្ខណញ្ញាណ គឺឲ្យព្រះសង្ឃពិចារណានៅពេលទទួលឬពេលបរិភាគនិងប្រើប្រាស់បច្ច័យ៤ កុំឲ្យជាប់តណ្ហាក្នុងការប្រើប្រាស់និងការបរិភោគ ដូចក្នុងសីល៤របស់ភិក្ខុសង្ឃក្នុងខមួយថែងថា ព្រះសង្ឃទទួលប្រើប្រាស់បច្ច័យ៤ បរិសុទ្ធដោយការពិចារណា ពុំមែនបរិសុទ្ធដោយការសូត្រទេ។ ព្រះសង្ឃអាចសូត្របាន

ដើម្បីឲ្យចាំ សូត្រពេលថ្វាយបង្គំព្រះរតនត្រ័យជាដើម។ ចម្លែកមួយទៀត សូត្រធម៌ជូនពរដែលឥតមានអ្នកស្ដាប់នៅពេលនោះ នេះជាការឆ្គង ព្រោះការសូត្រធម៌ជូនពរក្នុងបាលីថា បត្តានុមោទនា គឺត្រេកអរចំពោះអ្នកធ្វើកុសល ជាការលើកទឹកចិត្ត ចុះបើគ្មានអ្នកស្ដាប់នៅទីនោះទេ តើសូត្រដើម្បីអ្វី? ដើម្បីឲ្យរួចចាកទោសកុំឲ្យឥណបរិភោគ (បរិភោគជាបំណុល) ត្រូវពិចារណាជាបច្ចវេក្ខណញ្ញាណ ក្នុងការប្រើប្រាស់បច្ច័យ៤។

## ៩- គប្បីសម្លាប់តណ្ហាពុំមែនសម្លាប់ខ្លួនដើម្បីរលត់ទុក្ខឡើយ

កាលពីព្រឹកថ្ងៃ៥កញ្ញា២០០៧ មានព្រះសង្ឃខ្មែរមួយព្រះអង្គនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ព្រះនាមហេង ប៊ុនឆោម ព្រះជន្ម២៤ឆ្នាំបានធ្វើអត្តឃាតដោយដុតខ្លួននៅក្នុងព្រះវិហារក្នុងអាការៈគង់ធ្វើសមាធិ។ តាមអ្នករាយការណ៍ពត៌មានថា គេរកឃើញលិខិតមួយនៅក្នុងបន្ទប់សឹងរបស់លោកក្នុងលិខិតនោះសរសេរថា អាត្មាបានដុតខ្លួនបូជាព្រះធម៌សូមញាតិញោមអនុមោទនាផងចុះ។ តាមថេរដីការបស់ព្រះសង្ឃដែលគង់នៅក្នុងវត្តថា ព្រះភិក្ខុហេង ប៊ុនឆោម មុននឹងដុតព្រះកាយតែងតែពោលអំពីព្រះធម៌និងសេចក្ដីស្លាប់ ហើយមានខ្សែអាត់ទេសនារបស់លោកប៊ុត សាវង្សជាប់នឹងខ្លួនលោក។ ការដុតខ្លួននេះ ទំនងធ្វើសមាធិបែកឆ្វេង គឺប្រតិបត្តិខុសផ្លូវព្រះធម៌។

ដើម្បីយល់អំពីការសម្លាប់ខ្លួនបូជាធម៌ ជាការត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធសាសនា ឬពុំត្រឹមត្រូវនោះ សូមយល់អំពីកិច្ចក្នុងអរិយសច្ច៤ដែលព្រះអរិយបុគ្គលទាំង៤ពួកគឺព្រះសោតា ព្រះសកិទាគាមី ព្រះអនាគាមី និងព្រះអរហន្តបានកំណត់ក្នុងព្រះទ័យដោយលោកុត្តរបញ្ញា គឺទុក្ខសច្ចៈប្រែថា សេចក្ដីពិតគឺទុក្ខ បានដល់ការកើតឡើងនៃខន្ធ៥មានរូប

ខន្ធជាដើមជាតួទុក្ខ។ បានសេចក្ដីថា ការកើតឡើងនៃរូបរាង
កាយចិត្តវិញ្ញាណរបស់មនុស្សសត្វជាទុក្ខ បាលីថា បញ្ចុប្បា
ទានក្ខន្ធា ទុក្ខា ប្រែថា សេចក្ដីទុក្ខកើតមានព្រោះការកើត
ឡើងនៃខន្ធ៥ឬការមានជាតិ។ សេចក្ដីទុក្ខគឺខន្ធ៥នេះ ត្រូវកំ
ណត់ថាខន្ធ៥ជាតួទុក្ខ បាលីថា បរិញ្ញេយ្យកិច្ច គឺកិច្ចគប្បីកំ
ណត់ដឹង ពុំមែនសម្លាប់ខ្លួនឬលះបង់ខ្លួនដើម្បីសម្រេចធម៌ ឬ
ដើម្បីនិព្វាននោះឡើយ នេះជាអរិយសច្ចទីមួយ។ អរិយសច្ច
ទីពីរ គឺសមុទយសច្ចប្រែថា សេចក្ដីពិតគឺហេតុដែលនាំឲ្យ
កើតទុក្ខ ឬហេតុដែលនាំឲ្យកើតទុក្ខជាសេចក្ដីពិត បានដល់
តណ្ហាជាហេតុនាំឲ្យមានទុក្ខឬតណ្ហាសេចក្ដីប្រាថ្នាជាហេតុ
នាំឲ្យមានខន្ធ៥ដែលជាតួទុក្ខ។ តណ្ហាជាហេតុនាំឲ្យកើតទុក្ខ
ជាបហាតព្វកិច្ចគឺកិច្ចដែលត្រូវលះបង់ឬត្រូវសម្លាប់ គឺ
សម្លាប់តណ្ហាដែលស្ថិតនៅក្នុងចិត្តពុំមែនសម្លាប់រូបរាងកាយ
ឡើយ។ កាលណាសម្លាប់តណ្ហាដែលជាហេតុ ខន្ធ៥ដែលជា
ផល ក៏ពុំកើតមានឡើយ។អរិយសច្ចទីបីគឺ និរោធសច្ច ប្រែថា
ការរលត់ទុក្ខជាសេចក្ដីពិត។ និរោធសច្ច ជាសច្ឆិកាតព្វកិច្ច
ជាកិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់គឺធ្វើឲ្យកើតឡើងនូវការ
រលត់ទុក្ខ។ អរិយសច្ចទីបួនគឺ មគ្គសច្ច ប្រែថា ផ្លូវប្រតិបត្តិដើ
ម្បីរំលត់ទុក្ខជាសេចក្ដីពិត បានដល់មគ្គប្រកបដោយអង្គ៨
មានសម្មាទិដ្ឋិ ប្រែថា ការយល់ត្រូវជាដើម។ មគ្គសច្ចនេះជា
ភាវេតព្វកិច្ច គឺជាកិច្ចត្រូវចំរើនឲ្យកើតឡើង គឺត្រូវប្រតិបត្តិ

តាមមគ្គទាំង៨ដែលរួមមកបានដល់សីលសមាធិនិងបញ្ញា។ ដូចបានពោលមកហើយ ទុក្ខសច្ច ត្រូវកំណត់ដឹង ពុំត្រូវលះបង់ឬសម្លាប់ឡើយ ឯធម្មជាតិដែលត្រូវសម្លាប់គឺតណ្ហាដែលស្ថិតនៅក្នុងចិត្ត ទើបពុំមានជាតិដែលនាំឲ្យមានព្យាធិនិងមរណៈតទៅទៀត។ ដូច្នេះ ព្រះភិក្ខុហេង ប៊ុនឆោមដែលធ្វើអត្តឃាតដុតខ្លួននោះ ពុំត្រឹមត្រូវតាមធម៌វិន័យឡើយ។ ក្នុងព្រះវិន័យនិយាយថា ភិក្ខុសម្លាប់មនុស្សត្រូវអាបត្តិបារាជិក សម្លាប់ខ្លួនឯងត្រូវអាបត្តិទុក្កដ។ ពិតមែនតែការសម្លាប់ខ្លួនត្រូវអាបត្តិទុក្កដជាអាបត្តិមានទោសស្រាល ក៏ព្រះពុទ្ធហាមមិនឲ្យសម្លាប់ខ្លួនដែរ។ ក្នុងសម័យពុទ្ធកាល មានភិក្ខុជាច្រើនអង្គបានចំរើនកាយគតាសតិ គឺពិចារណានូវរូបរាងកាយ មានកេសាសក់ លោមារោម នខាក្រចកជាដើម ថាជារបស់មិនស្អាត គួរខ្ពើមរអើម ក៏កើតធម៌នេះឡើង មានការនឿយណាយក៏ធ្វើអត្តឃាតខ្លួនឯងខ្លះឲ្យគេសម្លាប់ខ្លះ។ លុះជ្រាបដល់ព្រះពុទ្ធ ទើបព្រះអង្គត្រាស់ឲ្យគេហៅភិក្ខុដែលសេសសល់ពីសុគតមកទូន្មានថា ម្នាលភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តធ្វើដូច្នេះជាការប្រព្រឹត្តខុស អ្នកមិនត្រូវសម្លាប់ខ្លួនឡើយ តែត្រូវសម្លាប់រាគៈការត្រេកអរស្រេឡាញ់ជាប់ចិត្តនូវរូបរាងកាយដែលជារបស់មិនស្អាតនេះវិញទេ។ សូម្បីព្រះអរហន្តដែលលោកបានសម្រេចជាព្រះអរហត្តកំចាត់កិលេសតណ្ហាអស់ហើយ ទោះបីលោកមានការធុញទ្រាន់នឹងខន្ធ៥ ក៏លោកមិនធ្វើគត់ខ្លួន

លោកឡើយ  គឺទុកឲ្យខន្ធ៥នេះត្រូវរលត់គឺត្រូវស្លាប់ដោយខ្លួនឯង។

ពាក្យថា ធ្វើសមាធិបែកឆ្វេងបានជាយល់ខុសធ្វើអត្តឃាតខ្លួនឯង បានសេចក្តីថា ប្រតិបត្តិខុសបំណងរបស់សមាធិនិងវិបស្សនា។ ត្រង់នេះហើយបានជាព្រះពុទ្ធសាសនាបានពោលថា ធុរៈឬកិច្ចដែលពុទ្ធសាសនិកជនត្រូវអនុវត្តមានពីរប្រការ  គឺគន្ថធុរៈការសិក្សាឲ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ  បើសមាធិនិងវិបស្សនាត្រូវសិក្សាឲ្យយល់របៀបចំរើន។ ធុរៈទីពីរ គឺវិបស្សនាធុរៈ ត្រូវប្រតិបត្តិតាមរហូតឃើញសេចក្តីពិតថា ខន្ធ៥ជាអនិច្ចំ ទុក្ខំ និងអនត្តា។ បើពុំបានសិក្សាឲ្យយល់ច្បាស់លាស់ អាចប្រតិបត្តិខុសនិងប្រើចិត្តខុសឃ្លាតពីព្រះធម៌។ សមាធិប្រែថា ភាពរបស់ចិត្តនិងចេតសិកជាកុសលដែលដំកល់ស្មើល្អក្នុងអារម្មណ៍តែមួយ។ ចិត្តធម្មតាដែលមិនទាន់កើតសមាធិ  មានអកុសល៥យ៉ាងស្ថិតនៅក្នុងចិត្តបិទបាំងរាំងដែលហៅថានីវរណធម៌ គឺកាមច្ឆន្ទ ការនឹកគិតទៅរកកាមមានរូបជាដើម ព្យាបាទៈចិត្តចងគំនុំអ្នកដទៃ ថីនមិទ្ធៈចិត្តរួញរា ឧទ្ធច្ចកុក្កុច្ចៈចិត្តរាយមាយ និងវិចិកិច្ឆាចិត្តសង្ស័យ។ កាលណាសមាធិចិត្តកើតឡើង នីវរណធម៌ទាំង៥នេះត្រូវស្ងប់។ ការចំរើនឲ្យកើតសមាធិចិត្ត គឺដើម្បីធ្វើចិត្តឲ្យស្ងប់ពីនីវរណធម៌នេះឯង។ បំណងរបស់សមាធិកម្មដ្ឋាន គឺចេតោវិមុត្តិ  ប្រែថា  ការរួចចាកនីវរណធម៌ទាំង៥ដោយអំណាច

សមាធិ។ ឯវិបស្សនា ប្រែថា ការឃើញច្បាស់នូវខន្ធ៥ មានរូបខន្ធជាដើមមិនទៀងជាទុក្ខនិងជាអនត្តា។ សីលសមាធិនិងបញ្ញាមានទំនាក់ទំនងគ្នាដែលចេញមកពីមគ្គប្រកបដោយអង្គ៨មានសម្មាទិដ្ឋិការយល់ត្រូវជាដើម ជាផ្លូវប្រតិបត្តិដើម្បីទៅកាន់ការរំលត់ទុក្ខ។ ផ្លូវប្រតិបត្តិនេះហើយដែលអាចឆ្លុះបញ្ចាំងឃើញខន្ធ៥របស់មនុស្សសត្វជាតួទុក្ខដែលនាំឲ្យចិត្តនឿយណាយ ទើបឃើញគុណសម្បត្តិរបស់ព្រះនិព្វានជាគុណជាតិចេញចាកទុក្ខ។ នេះជាបំណងពិតរបស់សមាធិនិង វិបស្សនា ប្រតិបត្តិដើម្បីដកចិត្តចេញពីសង្ខារធម៌មានខន្ធ៥ជាដើម។ព្រះធម៌របស់ព្រះពុទ្ធសាសនា ប្រតិបត្តិដើម្បីលះបង់លោភៈទោសៈមោហៈអវិជ្ជាជាដើម។ ការប្រតិបត្តិនាំឲ្យជាប់ចិត្តនឹងអ្វីមួយដែលជាចំណីតណ្ហា ជាការប្រតិបត្តិពុំត្រឹមតាមព្រះធម៌របស់ព្រះពុទ្ធសាសនាឡើយ ព្រោះធ្វើហេតុនាំឲ្យមានទុក្ខ(តណ្ហាជាហេតុការកើតឡើងនៃខន្ធ៥ជាទុក្ខ)។ ព្រះភិក្ខុហេង ប៊ុនឆោមដែលធ្វើអត្តឃាតខ្លួនឯង ទំនងប្រតិ-បត្តិខុសដោយមានចំណេះខាងព្រះពុទ្ធសាសនាតិចតួចយល់ពុំច្បាស់លាស់ផ្លូវប្រតិបត្តិ បានជាមានគំនិតខុសដែលហៅថាបែកឆ្វេងរហូតធ្វើអត្តឃាតខ្លួនឯង។

## ១០- និកាយនៃព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាមាននិកាយពីរ គឺព្រះពុទ្ធសាសនាថេរវាទឬហីនយាន និងព្រះពុទ្ធសាសនាអាចរិយវាទឬមហាយាន។

ព្រះពុទ្ធសាសនាថេរវាទ= រក្សាទុកនូវធម៌វិន័យរបស់ព្រះពុទ្ធមិនកែប្រែ ដែលសព្វថ្ងៃហៅថា ព្រះត្រៃបិដក។ ប្រទេសដែលកាន់ព្រះពុទ្ធសាសនាថេរវាទ មានប្រទេសកម្ពុជា ប្រទេសលាវ ប្រទេសស្រីលង្កា និងប្រទេសភូមាជាដើម។

ព្រះពុទ្ធសាសនាមហាយានៈ បានកែប្រែធម៌វិន័យរបស់ព្រះពុទ្ធគោរពព្រះពោធិសត្វ ដូចជាព្រះពោធិសត្វ អវលោកេតេស្វរៈ មញ្ជុស្រី មេត្រេយ ប្រាជ្ញាបារមិតាជាដើម។ ប្រទេសដែលកាន់សាសនាមហាយានមានប្រទេសចិន ប្រទេសទីបេត៍ ប្រទេសជប៉ុន និងប្រទេសកូរេជាដើម។

## ភាពខុសគ្នានៃព្រះពុទ្ធសាសនាទាំងពីរនិកាយនេះ
## និកាយថេរវាទ (ហីនយាន)

១. បង្រៀនឲ្យអ្នកប្រតិបត្តិសំឡឹងយកអរហន្តដើម្បីរួចចាក ទុក្ខ ដោយសង្កត់ធ្ងន់លើអរិយសច្ចបួន។

២. លើកកំពស់គុណភាពអភិវឌ្ឍន៍ខាងសតិបញ្ញាសាសនិក របស់ខ្លួនតាមឧត្តមគតិសាសនា។

៣. បង្រៀនអ្នកប្រតិបត្តិឲ្យយល់ច្បាស់ក្នុងធម៌វិន័យរបស់ព្រះ ពុទ្ធ។

៤. មិនយកពិធីកម្មសាសនាជាធំ។

៥. គោរពប្រតិបត្តិតាមពាក្យព្រះសម្មាសម្ពុទ្ធជាធំ។

៦. មានការបដិរូប(កែប្រែ)ទ្រឹស្ដីខ្លះៗ តែតិចតួចបំផុតហើយ ប្រកាន់យកពុទ្ធវចនៈ។

៧. ជាសាសនា អទេវនិយម(មិនមែនទេវតា) គោរពប្រតិបត្តិ ព្រះពុទ្ធតែមួយព្រះអង្គ

៨. ចង្អុលបង្ហាញឲ្យជឿខ្លួនឯងជាធំ ហើយជឿកម្មនិងផល របស់កម្ម។

៩. ព្រះនិព្វាន ជាការរំលត់ទុក្ខ មិនត្រលប់មកកើតទៀត ឡើយ។

១០. ព្រះត្រៃបិដកចារឹកក្នុងសាស្ត្រាស្លឹករិតជាភាសាបាលី។

## និកាយអាចរិយវាទ (មហាយាន)

១. បង្រៀនឲ្យសាសនិក មានជំនឿលើព្រះពោធិសត្វ និងធ្វើកិច្ចការអ្វីៗដើម្បីព្រះពោធិសត្វ។

២. បង្រៀនឲ្យមានជំនឿ ជឿស៊ប់ មុនពេលពង្រឹងស្មារតីនឹងគុណភាព

៣. បង្រៀនឲ្យឃើញប្រយោជន៍និកាយខ្លួនជាធំ ទោះបីមានការប្រព្រឹត្តខុសអំពីធម្មវិន័យក៏ដោយ។

៤. មានការផ្លាស់ប្តូរពិធីកម្មជាលំដាប់តាមប្រទេសនិងកន្លែងនីមួយៗ

៥. មានការអធិប្បាយបន្ថែម បន្ថយ ពុទ្ធវចនៈជាច្រើន

៦. មានតែងព្រះសូត្រថ្មីៗ និងកាត់បន្ថយព្រះសូត្រចាស់ជាច្រើន មិនប្រកាន់ភ្ជាប់នូវពុទ្ធវចនៈ។

៧. ជាសាសនាទេវនិយម គោរពប្រតិបត្តិព្រះពុទ្ធជាម្ចាស់ច្រើនអង្គ។

៨. ឲ្យតម្លៃទៅលើការបន់ស្រន់និងចិត្តស្មោះចំពោះព្រះពុទ្ធ។

៩. និព្វានរបស់ព្រះសម្មាសម្ពុទ្ធមិនមែនជាការរលត់សូន្យទាំងស្រុងទេ គឺគ្រាន់តែបរិនិព្វានក្នុងស្ថានមនុស្សលោកទៅកើតក្នុងស្ថានសួគ៌ទេវលោក។ ពេលណាមនុស្សកើតកោឡាហល នឹងចុះមកកើតជាមនុស្សដើម្បីចង្អុលផ្លូវរំលត់ទុក្ខដល់សត្វលោកម្តងទៀត។

១០. ព្រះត្រៃបិដកចារឹកលើក្រាំងមាសជាភាសាសំស្រ្កឹត។

តាមការរៀបរាប់មកនេះបញ្ជាក់ថា ពុទ្ធសាសនាមហាយានបានកែប្រែធម៌វិន័យរបស់ព្រះពុទ្ធ បានចាត់ទុកព្រះពុទ្ធជាអាទិទេពដូចសាសនាព្រាហ្មណ៍ ព្រោះព្រះអង្គបរិនិព្វាននៅស្ថានមនុស្ស តែបានទៅកើតនៅស្ថានសួគ៌រង់ចាំជួយមនុស្សសត្វ។ ត្រង់នេះផ្ទុយពីសាសនាហីនយាន ដែលពោលថា ព្រះពុទ្ធបរិនិព្វានបាត់ហើយមិនត្រឡប់វិញឡើយ ទុកតែធម៌វិន័យឲ្យសត្វប្រតិបត្តិតាម។

## គណៈមហានិកាយ និងធម្មយុត្តនៅកម្ពុជា

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាគឺ **ព្រះពុទ្ធសាសនាថេរវាទ** មាននិកាយពីរគឺ **មហានិកាយ** មានអ្នកកាន់ដ៏ច្រើនលើសលប់ និង **ធម្មយុត្តិកនិកាយ** មានអ្នកកាន់តិចតួចដែលនៅក្នុងពុទ្ធសាសនាថេរវាទជាមួយគ្នា។ ប្រទេសស្រីលង្កា ប្រទេសភូមា ប្រទេសនេប៉ាល់ និងប្រទេសកាន់ពុទ្ធសាសនាថេរវាទដទៃទៀត គ្មាននិកាយធម្មយុត្តទេ។ ចំណែកខ្មែរចំឡងយកធម្មយុត្តពីប្រទេសថៃ សូម្បីលាវដែលយកធម្មយុត្តពីប្រទេសថៃដែរ ឥឡូវនេះ គេបំបាត់និកាយនេះចោលហើយ នៅមានតែនិកាយមួយគឺមហានិកាយ។

## ១១- លក្ខណៈនៃព្រះពុទ្ធរូប

បន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅ ពុទ្ធបរិស័ទគ្រប់ប្រទេស ជាពិសេសពុទ្ធសាសនិកជនខ្មែរ បានកសាងព្រះពុទ្ធរូបគោរពបូជា ស្របតាមពុទ្ធប្បវត្តិនិងស្របតាមរចនាបថរបស់ជាតិខ្លួន។ តាមការស្រាវជ្រាវ ព្រះពុទ្ធរូបទើបតែកើតមានឡើងក្នុងកាលជាខាងក្រោយ ក្នុងពុទ្ធសករាជកន្លងទៅបានជាង ៤០០ឆ្នាំ ពុំមែនកើតឡើងក្នុងកាលព្រះពុទ្ធគង់ព្រះជន្មនៅឡើយទេ។ ចំពោះព្រះពុទ្ធរូបក្នុងរចនាបថខ្មែរ សម័យនគរភ្នំ សម័យចេនឡា និងសម័យមហានគរមានលក្ខណៈស្រដៀងគ្នា ជាពិសេសត្រង់ព្រះកេសគេធ្វើជារង្វង់មូលតូចៗដូចគួចខ្ចងហើយកំពូលលើព្រះកេសខ្លីមិនធ្វើវែងដូចព្រះពុទ្ធរូបថៃទេ សម័យនគរភ្នំនិងសម័យចេនឡាដូចគ្នា សម័យមហានគរបានច្នៃប្លែកពីនេះបន្តិច។ ព្រះកេសនៃព្រះពុទ្ធរូបតាមរចនាបថខ្មែរ គេមិនធ្វើព្រះកេស(សក់)ទេ គឺធ្វើដូចគួចខ្ចង ដូចពោលមកហើយ ឯសម័យនេះត្រង់ព្រះកេសព្រះពុទ្ធធ្វើសក់នៅលើព្រះកេសនោះជារចនាបថថៃសម័យក្រោយ។

ដើម្បីឲ្យមានឯកភាពខាងការកសាងព្រះពុទ្ធរូបតាមរចនាបថខ្មែរ គប្បីក្រសួងវប្បធម៌ ក្រសួងធម្មការ ក្រសួងសង្ឃរាជនិងវិស្វករខ្មែរប្រជុំពិភាក្សាធ្វើជាក្បួន ហើយផ្សាយជាសាធារណៈដើម្បីឲ្យអ្នកកសាងព្រះពុទ្ធរូបធ្វើតាមក្បួន

នោះ។ ដើម្បីឲ្យមានពន្លឺក្នុងការពិភាក្សានេះ ត្រូវសិក្សាស្រាវជ្រាវឲ្យដឹងលក្ខណៈគ្រឿងសំគាល់នៃព្រះពុទ្ធរូបនីមួយៗ ដែលមានប្រភេទផ្សេងៗគ្នា ដែលហៅថា«មុទ្រា» ជាពាក្យសំស្រ្កឹត បាលីថា«មុទ្ធា» ប្រែថា គ្រឿងសំគាល់ បែបយ៉ាង អាការៈ កាយវិការ ត្រាសញ្ញា។

## ប្រទេសកម្ពុជាមានព្រះពុទ្ធរូប៨បែប

១. ព្រះពុទ្ធរូបសមាធិ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំផ្ងាលើព្រះហស្តឆ្វេង តម្រួតលើព្រះភ្នែន ហៅថា វិតក៌មុទ្រា។

២. ព្រះពុទ្ធរូបមារវិជ័យ (កាលផ្ចាញ់មារ) គង់ពត់ព្រះភ្នែនដូចព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះហស្តស្តាំផ្កាប់លើព្រះខរុ(ភ្លៅ) បង្អុលចុះទៅផែនដី ព្រះហស្តឆ្វេងផ្ងាដាក់លើព្រះខរុ ហៅថា ភូមិស្បសិមុទ្រា។ ព្រះពុទ្ធរូបបែបនេះ កាលបើគេគូរនៅជញ្ជាំងវិហារ ឬលើផ្ទាំងសំពត់ ឃើញសុទ្ធតែមានរូបពួកពលមារាធិរាជ កាន់អាវុធគ្រប់ដៃ។

៣. ព្រះពុទ្ធរូបសំដែងធម្មចក្រ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំក្ដោបម្រាមធ្វើជាវង់មូលដូចជារូបកង់រទេះ ព្រះហស្តឆ្វេងធ្វើអាការដូចព្រះហស្តស្តាំក៏មាន ដាក់លើព្រះខរុក៏មាន ហៅថា ធម្មចក្រមុទ្រា។ ព្រះពុទ្ធរូបបែបនេះ កាលបើគេគូរ តែងតែមានរូបបញ្ចវគ្គិយភិក្ខុ កំពុងអង្គុយគោរពស្តាប់

ធម្មចក្កប្បវនសូត្រ ដែលជាបឋមទេសនា។

៤. ព្រះពុទ្ធរូបប្រទានអភ័យ ជាតំណាងកាលដែលព្រះអង្គសំដែងធម៌ប្រោសសត្វក្នុងទីណាមួយ មានព្រះកាយឈរក៏មាន គង់ពត់ព្រះភ្នែនក៏មាន ព្រះហស្តស្តាំវាចេញទៅមុខ ព្រះហស្តឆ្វេងសំយុងចុះ ហៅថា អភយមុទ្រា។

៥. ព្រះពុទ្ធរូបប្រទានពរ មានព្រះហស្តទាំងពីរសំយុងចុះ បែរបាតព្រះហស្តទៅខាងមុខ ទ្រង់គង់ពត់ព្រះភ្នែនក៏មាន ទ្រង់ឈរក៏មាន ជាដំណាងកាលបរិស័ទណាមួយចូលមកថ្វាយបង្គំដោយត្រូវការចង់ជួបចង់ឃើញក្តី ក្រាបទូលសួរធម៌អាថ៌ចំពោះព្រះអង្គក្តី ហៅថា វរមុទ្រា។

៦. ព្រះពុទ្ធរូបទ្រង់ឈរឱបបាត្រ ជាតំណាងកាលដែលព្រះអង្គទ្រង់និមន្តបិណ្ឌបាត ហៅថា បាត្រាទានមុទ្រា។

៧. ព្រះពុទ្ធរូបទ្រង់ផ្ទំ ជាតំណាងកាលដែលព្រះអង្គផ្ទំផ្អៀងព្រះកាយទៅខាងស្តាំ ព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំដោយទ្រង់ផ្ទំធម្មតាក្តី ផ្ទំលើអាសនៈបរិនិព្វានក្តី ហៅថា សយនមុទ្រា។

៨. ព្រះពុទ្ធរូបប្រក់នាគ ជាតំណាងកាលព្រះអង្គគង់នៅមាត់ស្រះមុច្ចលិន្ទ។

មានរូបមួយបែបទៀតដែលអ្នកស្រុកហៅថា ព្រះពុទ្ធរូបទ្រង់គ្រឿង ប៉ុន្តែតាមពិតរូបនេះ ពុំមែនជាព្រះពុទ្ធរូបទេ គឺជារូបស្តេចចក្រ ឬជារូបព្រះមេត្តេយ្យពោធិសត្វ។

# ១២- ព្រះសង្ឃឈប់ឆាន់បារី ជាគំរូដ៏ល្អដល់ពុទ្ធបរិស័ទខ្មែរ

ពុទ្ធសាសនិកជនខ្មែរបានទុកព្រះសង្ឃជាទីគោរពសក្ការៈរបស់ខ្លួន។ បើព្រះសង្ឃអង្គណាដែលឆាន់បារី ពុំមែនគ្រោះថ្នាក់តែចំពោះខ្លួនលោកទេ គឺវានាំឲ្យគ្រោះថ្នាក់ដល់ពុទ្ធបរិស័ទ ដែលទៅធ្វើបុណ្យទាន ដោយសារតែការស្រូបយកផ្សែងបារីដែលព្រះសង្ឃឆាន់ ហើយជាគំរូមិនល្អដល់ពុទ្ធបរិស័ទផង។ បារីអាចចាត់ចូលក្នុងប្រភេទសុរានៃសីល៥ ដែលជាខហាម ព្រោះជាប្រភេទគ្រឿងពុលដូចគ្នា។ ពុទ្ធសាសនាតែងតែសំដែងអំពីគុណនិងទោស គឺគុណត្រូវអនុវត្ត ឯទោសត្រូវលះបង់។ យ៉ាងណាមិញ បារីចាត់ជាទោសដល់អ្នកជក់ ព្រោះនាំឲ្យកើតរោគ មិនតែប៉ុណ្ណោះនាំឲ្យគ្រោះថ្នាក់ដល់អ្នកនៅជុំវិញ ដែលស្រូបផ្សែងបារីពីអ្នកជក់ផង។

តាមផ្លូវវេជ្ជសាស្ត្រ ដែលរកឃើញជាតិពុលនៅក្នុងបារីថ្នាំជក់ ជាពិសេសអង្គការសុខភាពពិភពលោកបានរកឃើញថា នៅក្នុងបារីមានជាតិម៉្យាងហៅថា Nicotine ដែលជាជាតិពុល មានសភាពដូចជាតិកំបោរហៅថា Alcaloide កាលណាវាផ្សំគ្នាច្រើន បង្កើតបានជា Insecticide ដែលគេយកជាតិនេះសំរាប់សម្លាប់សត្វល្អិត។

ជាតិ Nicotine នេះ បណ្ដាលឲ្យគ្រោះថ្នាក់ដល់អ្នកជក់សំខាន់ៗគឺ៖

១. កើតរោគមហារីកក្នុងសួត។

២. កើតជម្ងឺសរសៃនិងជម្ងឺបេះដូង(Maladie Cardio Vasculaire)

៣. ធ្វើឲ្យសរសៃប្រសាទនិងខួរក្បាលរលាកទៅជាល្ងីល្ងើ (Toxicité neurologique)។

៤. បើស្ត្រីមានផ្ទៃពោះ ទារកដែលកើតមកទៅជាស្គាំងស្គមខុសប្រក្រតីដោយសារការស្រូបជាតិពុលពីម្ដាយដែលជក់បារី ។ល។

ដោយឃើញទោសទាំងនេះហើយ បានជាប្រទេសដែលជឿនលឿនក្នុងលោក គេពុំអនុញ្ញាតឲ្យផ្សាយពាណិជ្ជកម្មបារីនៅក្នុងវិទ្យុនិងទូរទស្សន៍ និងសារពត៌មានឡើយ ហើយកន្លែងសាធារណៈគេហាមជាដាច់ខាតមិនឲ្យជក់បារី។ មានប្រទេសខ្លះហាមធ្វើពាណិជ្ជកម្មបារីទាំងស្រុងតែម្ដង។

## សំណូមពរ

១. សូមធ្វើសំណូមពរចំពោះព្រះសង្ឃដែលឆាន់បារីគួរឈប់ឆាន់ ដើម្បីជាសុខភាពផ្ទាល់ខ្លួនព្រះអង្គផង ហើយជាពិសេសទៅទៀត បានជាគំរូដ៏ល្អសំរាប់ពុទ្ធបរិស័ទខ្មែរយកតម្រាប់តាម។

២. ចំណែកពុទ្ធបរិស័ទខ្មែរសូមឈប់ប្រគេនបារីលោក

ព្រោះទានបារីនេះពុំបានបុណ្យទេ តែត្រូវបានបាបទៅវិញ ព្រោះប្រគេនគ្រឿងពុលដល់លោក ធ្វើឲ្យលោកកើតរោគ។

ពិពភលោកបានដាក់ថ្ងៃ៣១ឧសភា ជាថ្ងៃពិភពលោកគ្មានថ្នាំជក់។ ក្រឡេកមកមើលរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលខ្មែរ មិនត្រឹមតែមិនទប់ស្កាត់ពាណិជ្ជកម្មបារីទេ ថែមទាំងបើកដោយចំហ ព្រមទាំងបើកឲ្យផ្សាយតាមវិទ្យុ និងទូរទស្សន៍ ព្រមទាំងតាមសារពត៌មានយ៉ាងទូលំទំលាយផង។ច្បាប់ស្តីអំពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ២៩ឧសភាឆ្នាំ ២០០០ ហើយច្បាប់នេះបានត្រូវព្រះមហាក្សត្រឡាយព្រះហត្ថលេខាកាលពីថ្ងៃ២១មិថុនាឆ្នាំដដែលនោះ ពុំឃើញរាជរដ្ឋាភិបាលអនុវត្តតាមឡើយ ដោយបណ្តោយឲ្យនាំចូលស្រាបារី ដែលជាជាតិពុលគ្រប់ធុនគ្រប់ម៉ាកមកកម្ពុជា។ ដូច្នេះបានន័យថា ក្រសួងសុខាភិបាលនិងរាជរដ្ឋាភិបាលខ្មែរសុខចិត្តយកជីវិតប្រជាពលរដ្ឋទៅប្តូរយកប្រាក់ពន្ធបន្តិចបន្តួចពីពាណិជ្ជកម្មបារីនេះ។ ប៉ុន្តែក្រសួងសុខាភិបាលខ្មែរបានធ្វើការស្រាវជ្រាវប៉ាន់ប្រមាណជូនទៅរាជរដ្ឋាភិបាលដើម្បីពិចារណា ដោយគិត១០ឆ្នាំ ពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០៧ ប្រាក់ចំណូលពីថ្នាំជក់បាន៦៥៩លានដុល្លារ ប៉ុន្តែប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ដោយការចំណាយក្នុងការព្យាបាលអស់ ១០៧៩លានដុល្លារ ដូច្នេះរដ្ឋពុំចំណេញឡើយថែមទាំងខាត

បង់អស់៩១០លានដុល្លារ និងធ្វើឲ្យខូចសុខភាពប្រជាពលរដ្ឋដែលជាធនធានមនុស្សថែមទៀត។ ដោយឃើញផលវិបាកអាក្រក់បែបនេះដល់ប្រទេស គួររដ្ឋាភិបាលធ្វើច្បាប់លុបបំបាត់ពាណិជ្ជកម្មបារីនេះទាំងស្រុងតែម្តង ដូចជាប្រទេសខ្លះគេបានធ្វើរួចមកហើយ។

## ១៣- ពុទ្ធសាសនិកជនខ្មែរគួរតាំងអាសនៈ ដំកល់ព្រះពុទ្ធរូបគ្រប់គេហដ្ឋាន

ដោយយោលទៅតាមពុទ្ធសាសនិកជនខ្មែរគោរពព្រះពុទ្ធសាសនាទុកជាសរណៈទីពឹងរបស់ខ្លួនស្មើដោយជីវិត។ ដូច្នេះ នៅតាមគេហដ្ឋាននីមួយៗ គួររៀបចំតាំងអាសនៈដំកល់ព្រះពុទ្ធរូប ទុកជាទីគោរពធ្វើសក្ការៈបូជា។ ការធ្វើសក្ការៈបូជាគួរប្រើផ្កាឬទៀន មិនគួរប្រើធូបទេព្រោះនាំហុយខ្មៅផ្ទះ និងខូចសុខភាពដោយស្រូបផ្សែងធូប។ បើនមស្សការមិនថ្វាយគ្រឿងសក្ការៈទាំងនេះ ក៏មិនទាស់អ្វីឡើយ គឺគោរពបូជាតាមផ្លូវចិត្តហើយ។ ការតាំងអាសនៈព្រះពុទ្ធរូបក្នុងគេហដ្ឋាន មានប្រយោជន៍នាំកូនចៅទៅថ្វាយបង្គំ ដើម្បីជាទម្លាប់ឲ្យកូនចៅគោរពព្រះពុទ្ធសាសនាតាំងពីតូចៗទៅ។

អាសនៈសំរាប់ដំកល់ព្រះពុទ្ធរូប គួរក្រុមវិស្វករខ្មែរពិភាក្សាគ្នាអំពីរបៀបធ្វើអាសនៈនោះឲ្យជាអាសនៈសមរម្យសំរាប់ដំកល់ព្រះពុទ្ធរូបជាទីគោរព ហើយស្របតាមក្បូរក្បាច់ខ្មែរផង។ ក្រុមជាងអ្នកធ្វើអាចលក់ដូរសំរាប់ឲ្យពុទ្ធសាសនិកជនខ្មែរជាវយកទៅតាំងនៅតាមគេហដ្ឋានដំកល់ព្រះពុទ្ធរូប ដើម្បីកុំឲ្យជាវពីថៃ ព្រោះថៃគេបានធ្វើអាសនៈតូចៗសំរាប់ដំកល់ព្រះពុទ្ធរូបជាយូរហើយ មានខ្មែរខ្លះបានជាវអាសនៈនេះពីថៃផង ដោយសារខ្មែរមិនទាន់មានធ្វើនៅប្រទេសរបស់ខ្លួន

នៅឡើយ។ កាលណាមានជាងខ្មែរធ្វើ ពុទ្ធសាសនិកជនខ្មែរនឹងជាវផលិតផលរបស់ជាតិខ្លួន រូបិយប័ណ្ណក៏មិនធ្លាក់ទៅប្រទេសគេ ខ្មែរមានការងារធ្វើបានមួយភាគតូចដែរ ហើយខ្មែរបានប្រើប្រាស់នូវសម្ភារៈពុទ្ធសាសនាដែលជាលក្ខណៈខ្មែរផង។ ក្រុមជាងគួរធ្វើឲ្យតូចល្មមសំរាប់ដំកល់ព្រះពុទ្ធរូបខ្នាតតូចនិងគ្រឿងសក្ការៈបូជា។ ឯសម្ភារៈដែលធ្វើគួរយកឈើប្រភេទណាដើម្បីឲ្យជាប់បានយូរ ព្រោះសម្ភារៈដែលថៃយកមកធ្វើអាសនៈនោះ ពុំល្អសោះឡើយ។

## ១៤- ការធ្វើសក្ការបូជាគួរប្រើទៀន និងផ្កា មិនគួរប្រើធូបទេ

ក្នុងធម៌នមស្សការដែលពុទ្ធបរិស័ទខ្មែរតែងសូត្រជាដំបូងថា ឥមេហិ ទីបធូបាទីសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ ដែលប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានទៀននិងធូបជាដើមនេះ។ល។ អត្ថបទនេះ ពុំមែនជាពាក្យរបស់ព្រះពុទ្ធសំដែងទេ គឺជាពាក្យរបស់អ្នកប្រាជ្ញព្រះពុទ្ធសាសនាខ្មែរតែងសម័យក្រោយ ប៉ុន្តែពុំអាចស្រាវជ្រាវឃើញឈ្មោះឬក្រុមអ្នកតែងអត្ថបទនេះទេ។ នៅសម័យពុទ្ធកាល ពុំឃើញមានប្រើពាក្យធូបទេ តែមានប្រើពាក្យប្រទីប (ពន្លឺ) និងបុប្ផា(ផ្កា) គឺគេបូជាចំពោះព្រះរតនត្រ័យមានព្រះពុទ្ធជាដើម ដោយពន្លឺនៃទៀននិងផ្កា ឬដោយគ្រឿងក្រអូបផ្សេងៗ ដូចជាគន្ធកុដិដែលព្រះពុទ្ធគង់នៅវត្តជេតពន នាងវិសាខាតែងដាក់គ្រឿងក្រអូបក្នុងកុដិព្រះអង្គ ដូច្នេះហើយបានជាមហាជនតែហៅកុដិព្រះអង្គថា គន្ធកុដិប្រែថាកុដិក្លិន គឺកុដិមានក្លិនក្រអូប។ ពាក្យធូបនេះ ចេញពីភាសាបាលី ប្រែថាផ្សែង ទំនងជាទាក់ទងនឹងសាសនាព្រាហ្មណ៍។ តាមសាសនាព្រាហ្មណ៍ ដើម្បីឲ្យព្រះឥន្ទនិងព្រះព្រហ្មប្រទានពរឲ្យពួកគេបានសុខ គេតែងបូជាយញ្ញមានចាប់សត្វដុតទាំង

រស់ មានពេលខ្លះចាប់មនុស្សដុតទាំងរស់ថែមទៀត។ ឯទូត ដែលឲ្យដំណឹងទៅព្រះឥន្ទនិងព្រះព្រហ្មថាខ្លួន (ពួកព្រាហ្ម-ណ៍) បូជានោះ គឺផ្សែង(ធូប)នេះឯង។ ដូច្នេះ ធូបនេះចេញពី សាសនាព្រាហ្មណ៍ ដែលប្រែថាផ្សែង គឺផ្សែងចេញពីការបូជា យញ្ញ ហុយឡើងទៅលើជាទូតឲ្យដំណឹងទៅព្រះអាទិទេព របស់គេ ពុំមែនជាធូបរបស់ខ្មែរធ្វើដូចសព្វថ្ងៃនេះទេ។ នៅ ប្រទេសភូមា ប្រទេសស្រីលង្កា ប្រទេសនេប៉ាល់ ដែលកាន់ ព្រះពុទ្ធសាសនាដូចខ្មែរ គេមិនប្រើធូបពេលធ្វើសក្ការៈបូជា ចំពោះព្រះរតនត្រ័យទេ គឺគេប្រើទៀននិងផ្កា។ ការប្រើធូប ក្រៅពីប្រទេសកម្ពុជា មានប្រទេសថៃ និងប្រទេសលាវប្រើ ធូបដូចប្រទេសខ្មែរដែរ។

ការអុជធូបបូជាព្រះរតនត្រ័យតាមទម្លាប់ពុទ្ធសាស និកជនខ្មែរ ហុចផលអាក្រក់ណាស់ដល់សុខភាពមនុស្ស ដែលដកស្រូបក្លិនធូប ព្រោះផ្សែងធូបមានជាតិពុល ដោយ ផ្សែងកាត់យកខ្យល់អុកស៊ីសែនដែលបន្សុតឈាមឲ្យថ្លា ស្អាត បំបាត់ជាតិពុលតាមរយៈការដកដង្ហើម។ ផលវិបាក អាក្រក់ម៉្យាងទៀត បើដុតធូបក្នុងកុដិក្នុងសាលាក្នុងព្រះវិហារ នាំឲ្យខ្មៅត្រង់បរិវេណកន្លែងដែលដុតនោះ ដោយសារផ្សែង ហុយទៅប៉ះជិតជាប់។ ការដុតធូបមានន័យថា ការបូជាផ្សែង ដល់ព្រះពុទ្ធជាម្ចាស់ តើមានប្រយោជន៍អ្វីក្នុងការបូជាផ្សែង ដែលជាគ្រឿងពុលនេះដល់ព្រះពុទ្ធ។ បើព្រះពុទ្ធគង់ព្រះជន្ម

នៅ ហើយគេដុតធូបបូជាចំពោះព្រះភ័ក្ត្រ តើព្រះអង្គសព្វព្រះទ័យឬទេ នៅពេលដែលព្រះអង្គស្រូបយកផ្សែងជាតិពុលនេះ។ ព្រះពុទ្ធនឹងហាមឃាត់ពុទ្ធបរិស័ទមិនឲ្យប្រើគ្រឿងបូជាខុសក្បួនអនាម័យបែបនេះពុំខាន។ ព្រះពុទ្ធសំដែងថា ការធ្វើសក្ការៈបូជាចំពោះព្រះរតនត្រ័យដោយចិត្តជ្រះថ្លា ថាបានផលបានអានិសង្សហើយ ប៉ុន្តែចំពោះគ្រឿងសក្ការៈបូជាដែលមិនប៉ះពាល់ដល់សុខភាព គឺមិននាំឲ្យមានជម្ងឺ។ បើបូជាចំពោះវត្ថុដូចជាផ្សែងធូបនេះ នាំឲ្យមានជម្ងឺ មិនត្រឹមតែមិនបានអានិសង្សទេ ថែមទាំងទទួលបាបថែមទៀត ព្រោះនាំឲ្យវិលមុខដល់អ្នកទៅធ្វើបុណ្យដោយសារស្រូបយកផ្សែងធូប។

ការបូជាដែលបានផលបានអានិសង្សច្រើន គឺប្រតិបត្តិបូជា ប្រែថា ការបូជាដោយប្រតិបត្តិតាមសីលសមាធិបញ្ញាប្រសើរជាងការបូជាដោយគ្រឿងសក្ការបូជាទាំងឡាយ មានបូជាផ្កាជាដើម។ បើនៅតែចង់បូជានូវគ្រឿងសក្ការបូជា គួរដកយកធូបចេញកុំបូជា គួរបូជាតែផ្កាឬពន្លឺដូចដុតទៀនជាដើមបានហើយ។ ក្នុងន័យនេះ បើនៅតែចង់សូត្រធម៌ ឥមេហិ នេះ គួរដកពាក្យ ធូបា ចេញ ហើយបញ្ចូលពាក្យ បុប្ផាវិញ គឺបញ្ចូលថា ឥមេហិ ទីបបុប្ផាទីសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ ប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយ គ្រឿងសក្ការបូជាទាំងឡាយមានទៀននិងផ្កាជាដើមនេះ។ ត្រង់នេះ គេអាច

កែបានព្រោះពុំមានជាពាក្យព្រះពុទ្ធដីកា ជាពាក្យរបស់ខ្មែរ ចងក្រងជំនាន់ក្រោយ ព្រោះសូម្បីតែថៃនិងលាវ ដែលប្រើការអុជធូបដែរនោះ ពុំមានធម៌ឥមេហិនេះទេ។ សូមកុំយល់ថា ទម្លាប់ដែលធ្លាប់ធ្វើមកហើយ បើមិនធ្វើនាំឲ្យមានទោសនោះឡើយ។ ទម្លាប់ខ្លះ គេអាចកែបានបើទម្លាប់នោះមិនល្អ ដោយកែទៅរកទម្លាប់ល្អ ឆ្ពោះទៅរកការជឿនលឿន ដូចធម៌ចាស់ធម៌ថ្មី គឺធម៌ចាស់ជាធម៌មិនបកប្រែ នៅសូត្រជាភាសាបាលី ឯធម៌ថ្មីគឺបកប្រែឲ្យស្ដាប់សេចក្ដីបាន វៀរលែងតែពាក្យព្រះពុទ្ធដីកា ដែលគេពុំអាចកែប្រែបាន។ បើថ្វាយបង្គំមិនបានអុជទៀនឬបូជាផ្កា ក៏មិនមែនទាស់ខុសអ្វីឡើយ គ្មានព្រះវិន័យណាចែងថា ថ្វាយបង្គំត្រូវតែអុជទៀនធូប ឬបូជាផ្កាឡើយ បើមានក៏បូជាទៅ។ ការថ្វាយបង្គំនេះ មានន័យជាពិសេសគឺនឹកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនេះឯង។ មានអ្នកខ្លះថា បើសូត្រ ឥមេហិ មិនបានអុជទៀនជាដើមទេ មិនហ៊ានសូត្រទេ ព្រោះកុហកព្រះ។ យល់ដូច្នេះក៏ត្រូវ មិនសូត្រក៏បាន ប៉ុន្តែបើទម្លាប់សូត្រទៅហើយ បើសូត្រទៅដោយតាំងចិត្តថា ទៀនផ្កានៅក្នុងចិត្តក៏គ្មានទាស់ខុសអ្វីដែរ ព្រោះបើមិនសូត្រឥមេហិ សូត្រសង្ខេប ក៏មានពាក្យថ្វាយគ្រឿងសក្ការបូជានៅក្នុងនោះដែរ។

ពេលភ្ជុំបិណ្ឌ ពេលចូលឆ្នាំ ពុទ្ធបរិស័ទអុជធូបហុយទ្រលោម សំបូងសំរូងប្រតិស្ឋអធិដ្ឋានសុំសេចក្ដីសុខនិង

ឧទ្ទិសកុសលដល់មាតាបិតាជីដូនជីតាញាតិកា៧សន្តាន។ ចុះបើមិនអុជធូបសំបូងសំរូងសំរូងមិនកើតឬ? តាមពិតការអធិដ្ឋានចិត្ត ពុំមែនស្ថិតនៅលើធូបទេ គឺស្ថិតនៅលើផ្លូវចិត្តវិញទេ។ ផលវិបាកអាក្រក់មួយទៀត ការអុជទៀនធូបដោយភ្លេចពន្លត់ ខ្យល់បក់មក ឬរលំទៅឆេះរបស់ផ្សេងៗរហូតខ្លះមានឆេះផ្ទះទៀតផង។ តាមសេចក្តីដូចបានពោលមកហើយនេះ គួរអ្នកទទួលខុសត្រូវខាងព្រះពុទ្ធសាសនានិងពុទ្ធបរិស័ទខ្មែរទូទៅយកទៅពិចារណា គួរឈប់ប្រើធូបក្នុងការធ្វើសក្ការបូជាចំពោះព្រះរតនត្រ័យ ដោយកែធម៌តមេហិត្រង់ធូបាមកជាបុប្ផាវិញ គឺបូជាព្រះទីបមានភ្លើងទៀនជាដើមនិងផ្កាគ្រឿងក្រអូបជាដើមវិញ ដើម្បីអនាម័យ ដូចប្រទេសភូមា ប្រទេសស្រីលង្កាជាដើម គេប្រើតែទៀននិងផ្កា គេមិនប្រើធូបឡើយ។ ទោះបីពុទ្ធបរិស័ទអុជធូបទៀនខាងក្រៅកុដិសាលាវិហារក៏ដោយ ក៏ពុំឃើញមានប្រយោជន៍ ដែលកើតអំពីការអុជធូបនេះឡើយ ឃើញតែចំណាយថវិកាក្នុងការជាវធូបមកអុជអស់ប្រាក់កាសប៉ុណ្ណោះ។

មួយទៀត យើងសង្កេតឃើញចិនដែលកាន់ព្រះពុទ្ធសាសនាមហាយាននិងលាយឡំដោយជំនឿផ្សេងៗទៀត មានប្រើធូបច្រើនណាស់ ក្នុងការបូជាចំពោះព្រះពុទ្ធនិងសែនដូនតា។ ចំណែកវៀតណាមដែលទទួលវប្បធម៌ពីចិនក៏ធ្វើដូចចិនដែរ។ ចំណែកខ្មែរទទួលវប្បធម៌ពីប្រទេសឥណ្ឌា

យើងសង្កេតឃើញជនជាតិឥណ្ឌាដែលកាន់សាសនាហិណ្ឌូ ទោះបីមានការបូជាយញ្ញដើម្បីសុំពរពីព្រះអាទិទេព ក៏គេមិនឃើញអុជធូបដូចខ្មែរឡើយ។ ដូច្នេះ ការអុជធូបនេះជាគំនិតរបស់ខ្មែរ ឬទទួលពីចិន ព្រោះវប្បធម៌តែងឆ្លងពីគ្នាទៅវិញទៅមក។ ក្នុងពិធីកម្មជាផ្លូវការឬផ្លូវរដ្ឋមិនគួរប្រើធូបទេ ព្រោះវាហុយនាំឲ្យរំលោនដល់ភ្ញៀវ គួរប្រើផ្កាទៀនឬពន្លឺអគ្គិសនីវិញ គ្មានទាស់ខុសនឹងព្រះពុទ្ធសាសនាឡើយ។

# ១៥- ផលិតផលព្រះពុទ្ធសាសនារបស់ថៃ ដែលគួរនិងមិនគួរនាំចូលមកប្រទេសកម្ពុជា

## ផលិតផលមិនគួរនាំចូល

ផលិតផលដែលមិនគួរនាំចូល គឺព្រះពុទ្ធរូប ព្រោះព្រះពុទ្ធរូបរបៀបថៃមានរចនាបថខុសគ្នាពីរចនាបថខ្មែរ។ សព្វថ្ងៃនេះ ខ្មែរមានសមត្ថភាពនិងមានលទ្ធភាពធ្វើខ្លួនឯងបានហើយបន្ទាប់ពីបញ្ចប់សង្គ្រាមក្នុងប្រទេស។ ការនិយមប្រើប្ញូជនីយវត្ថុគឺព្រះពុទ្ធរូបរបស់ជាតិខ្លួន ជាការលើកតម្លៃវប្បធម៌ជាតិឲ្យស្ថិតនៅជានិច្ចមិនឲ្យបាត់បង់ ឲ្យខ្មែរមានការងារធ្វើ ហើយរូបិយប័ណ្ណមិនធ្លាក់ទៅបរទេស។ ចំណែកស្បង់ចីពរបាត្រនិងសម្ភារៈផ្សេងទៀតសំរាប់ប្រើក្នុងព្រះពុទ្ធសាសនា ក៏គួរផលិតក្នុងប្រទេសកម្ពុជា មិនគួរនាំចូលមកឡើយ។ ការពុំនាំចូល នាំឲ្យខ្មែរក្នុងស្រុកខំប្រឹងប្រែងផលិតក្នុងប្រទេសរបស់ខ្លួន។ សៀវភៅសាសនពិធីរបៀបថៃដូចរបៀបធ្វើបុណ្យទានរបៀបសូត្រធម៌ជាដើម ដែលមានលក្ខណៈផ្សេងពីរបៀបខ្មែរ ក៏មិនគួរអនុញ្ញាតឲ្យនាំចូល ព្រោះកុំឲ្យពុទ្ធសាសនិកជនខ្មែរធ្វើតាមនាំឲ្យបាត់បង់របៀបខ្មែរ ប៉ុន្តែបើខ្មែរពង្រឹងទំនៀមទម្លាប់របស់ខ្លួនឲ្យរឹងមាំ ទោះបីនាំចូលក៏ខ្មែរមិនទទួលធ្វើតាមឡើយ។ មួយទៀត និកាយព្រះពុទ្ធសាសនាមួយរបស់ថៃឈ្មោះធម្មកាយដែលមានឥទ្ធិពលយ៉ាងខ្លាំងនៅប្រទេស

ថៃ មិនត្រូវអនុញ្ញាតឲ្យមកបង្កើតនៅប្រទេសកម្ពុជាឡើយ ព្រោះនាំឲ្យព្រះពុទ្ធសាសនាខ្មែរបែកជាគណៈនិកាយផ្សេង ទៀតដែលជាគណៈនិកាយរបស់បរទេស នាំឲ្យខ្មែរបែក សាមគ្គីគ្នាអំពីបញ្ហាព្រះពុទ្ធសាសនា។

## ផលិតផលដែលគួរនាំចូល

ផលិតផលដែលគួរឲ្យនាំចូល គឺអដ្ឋកថានៃព្រះត្រៃបិដករបស់ថៃ។ សូមបញ្ជាក់ថា អដ្ឋកថា គឺជាសេចក្ដីអធិប្បាយពន្យល់ពង្រីកសេចក្ដីពីពាក្យព្រះពុទ្ធដីការបស់ព្រះអរហន្ត។ ដូច្នេះ ប្រទេសកម្ពុជាមានកង្វះខាតអដ្ឋកថានេះ គួរនាំចូលមកប្រទេសកម្ពុជា ព្រោះអដ្ឋកថានេះពុំមែនជាគំនិតរបស់ថៃទេ គឺជាសេចក្ដីអធិប្បាយពន្យល់តាមព្រះពុទ្ធដីកាដោយពង្រីកសេចក្ដីឲ្យងាយយល់ គួរបកប្រែមកជាភាសាខ្មែរ ដើម្បីឲ្យខ្មែរសម្បូណ៌ឯកសារព្រះពុទ្ធសាសនា មិនប៉ះពាល់ដល់ទំនៀមទម្លាប់ខ្មែរឡើយ។ ចំណែក ព្រះសារីរិកធាតុនៃព្រះពុទ្ធវិញ ក៏គួរឲ្យនាំចូលមកប្រទេសកម្ពុជា មិនត្រូវហាមឃាត់ទេ។ អំពីរឿងថា តើព្រះសារីរិកធាតុនោះពិតឬមិនពិតនោះជាបញ្ហាផ្សេងដោយឡែក។ ពុទ្ធបរិស័ទខ្មែរមានសិទ្ធិកសាងបូជនីយដ្ឋានសំរាប់ដំកល់ព្រះសារីរិកធាតុនៅទីណាក៏បានក្នុងប្រទេសកម្ពុជា។ តាមពត៌មានថា ចិនកុម្មុយនិស្តបានគាស់ឃើញព្រះចង្កូមកែវរបស់ព្រះពុទ្ធ យើងពុំជឿនូវការរកឃើញ

នេះឡើយ ព្រោះតាមប្រវត្តិព្រះពុទ្ធសាសនា ពុំឃើញមាននិយាយថា មានព្រះចង្កូមកែវរបស់ព្រះពុទ្ធនៅប្រទេសចិនឡើយ នេះទំនងជាផ្លូវនយោបាយ។

## អំពីគន្ថធុរៈ និងវិបស្សនាធុរៈ

ធុរៈក្នុងព្រះពុទ្ធសាសនាមានពីរយ៉ាង គឺគន្ថធុរៈ បានដល់ការសិក្សាឲ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលសព្វថ្ងៃព្រះសង្ឃកំពុងសិក្សារៀនសូត្រ ដែលហៅថាពុទ្ធិកសិក្សា។ វិបស្សនាធុរៈ បានដល់ការប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ធុរៈទាំងពីរនេះហើយដែលពុទ្ធបរិស័ទជាពិសេសព្រះសង្ឃគប្បីអនុវត្ត។ បានសេចក្តីថា សិក្សាឲ្យយល់ផងប្រតិបត្តិតាមផង ទើបឈ្មោះថា អនុវត្តតាមព្រះពុទ្ធសាសនាបានពេញលេញក្នុងការរំដោះទុក្ខ។ ព្រះសង្ឃសមណសិស្សនិងសមណនិស្សិតដែលកំពុងសិក្សា ពុំមែនលោកពុំប្រតិបត្តិវិបស្សនាធុរៈទេ គឺលោកជាអ្នកមានសីលតាមលក្ខណៈជាសាមណេរនិងភិក្ខុហើយ ប៉ុន្តែលោកពុំទាន់បានប្រតិបត្តិសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋានឲ្យបានពេញលេញដោយជាប់ការសិក្សា។ អ្នកសិក្សាផ្នែកពុទ្ធិកសិក្សានិងផ្នែកធម្មវិន័យមានប្រយោជន៍ណាស់សំរាប់អភិវឌ្ឍន៍ព្រះពុទ្ធសាសនាឲ្យបានចំរើនលូតលាស់។ បើព្រះសង្ឃសមណសិស្សនិងសមណនិស្សិតមានការចេះដឹងច្រើនជាការបណ្តុះ

ធនធានមនុស្ស គឺព្រះសង្ឃអ្នកចេះដឹងអាចជួយពន្យល់បំភ្លឺស្មារតីខ្មែរឲ្យយល់អំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ និងជួយសង្គមជាតិក្នុងផ្នែកសីលធម៌និងសង្គមកិច្ច។ លោកមានសមត្ថភាពសរសេរសៀវភៅធម៌អាថ៌និងពាក្យរំលឹកទូន្មានផ្សេងៗ ដើម្បីឲ្យខ្មែរសម្បូណ៌ឯកសារផ្តល់ចំណេះចេះដឹងឲ្យខ្មែរតាមរយៈការអានសៀវភៅទាំងនោះ។ ចំណែក ព្រះសង្ឃមួយផ្នែកទៀត បានប្រតិបត្តិធម៌ជាសមាធិឬវិបស្សនានៅតាមអាស្រមនានាក្នុងប្រទេសកម្ពុជា ក៏ពុំគួរទៅរិះគន់ព្រះសង្ឃអ្នកសិក្សាដែរ ព្រោះដោយសារព្រះសង្ឃសិក្សាមានចំណេះចេះដឹងនេះហើយ បានជាសម្បូណ៌ក្បួនច្បាប់ព្រះពុទ្ធសាសនា ដែលអាចឲ្យអ្នកចំរើនវិបស្សនាយកមកអានដើម្បីជំនួយក្នុងការប្រតិបត្តិធម៌។

## បញ្ហាព្រះសង្ឃពាក់ទ្រនាប់ជើង

មានព្រះសង្ឃនៃអាស្រមដែលប្រតិបត្តិធម៌ខ្លះមិនពាក់ទ្រនាប់ជើង បើធ្វើបានដូច្នេះ ជាការប្រសើរហើយ ប៉ុន្តែកុំឲ្យនិយាយប៉ះពាល់ដល់ព្រះសង្ឃដែលមិនបានអនុវត្តដូច្នេះ។

រឿងពាក់ទ្រនាប់ជើងនេះ បើព្រះសង្ឃធ្វើធុតង្គដើរក្នុងព្រៃ ព្រះពុទ្ធមានពុទ្ធានុញ្ញាតឲ្យព្រះសង្ឃពាក់ទ្រនាប់ជើងពីរជាន់ទៅបួនជាន់ ព្រោះខ្លាចជាន់បន្លា កាលណាជាន់បន្លាមុតព្រះបាទនាំឲ្យមានជម្ងឺ កាលណាមានជម្ងឺឬមានអាពាធពុំអាច

ដើរធ្វើធុតង្គបានឡើយ។ ក្រៅពីនោះ ការពាក់ទ្រនាប់ជើង ដើរតាមផ្លូវធម្មតាថាត្រូវអាបត្តិទុក្កដជាអាបត្តិតូចបំផុត។ រឿងអាបត្តិទុក្កដនេះ មិនថាពាក់ទ្រនាប់ជើងទេ ដែលត្រូវអាបត្តិនេះ គឺគ្រាន់តែងាកខ្លួនមិនសមបន្តិចក៏ត្រូវអាបត្តិទុក្កដដែរ។ បើពាក់ទ្រនាប់ជើងមិនបានត្រូវអាបត្តិទុក្កដ ការជិះយន្តយានគ្រប់ប្រភេទ ដូចជាយន្តហោះ រទេះភ្លើង រថយន្ត ទូក កាណូត កប៉ាល់ ស៊ីក្លូ ម៉ូតូ រទេះសេះ រទេះគោជាដើមពុំអាចជិះបានឡើយ ព្រោះគ្មានវិន័យរបស់ព្រះពុទ្ធអនុញ្ញាតឲ្យជិះបានឡើយ។ ប៉ុន្តែអាចជិះបាន ដោយគ្រាន់តែសំដែងនូវភាពជាអ្នកមានជម្ងឺ គឺធ្វើដំណើរផ្លូវឆ្ងាយអាចហាត់ហេវមានជម្ងឺ កាលណាមានជម្ងឺពុំអាចប្រតិបត្តិធម៌បានឡើយ។ យ៉ាងណាមិញ ការពាក់ទ្រនាប់ជើងពុំមែនដើម្បីលំអទេ គឺដើម្បីការពារកុំឲ្យមានជម្ងឺនិងដើម្បីឲ្យមានអនាម័យកុំឲ្យកើតរោគ ដូចដើរតាមផ្លូវមានគ្រោះមានថ្មត្រូវមុតជើង កន្លែងចាក់កៅស៊ូត្រូវក្តៅព្រះបាទរលោកជើង កន្លែងមានភក់មានច្រំដើរទៅប្រឡាក់ព្រះបាទ។ បើពាក់ទ្រនាប់ជើងមិនបាន ការស្លៀកស្បង់គ្រោងចីពរក៏ពុំបានដែរ ក៏ដូចគ្នានឹងការគង់នៅក្នុងកុដិក៏ពុំបានដូចគ្នា ប៉ុន្តែអាចប្រើប្រាស់និងគង់នៅបាន បើពិចារណាតាមធម៌បច្ចវេក្ខណញ្ញាណថា ការប្រើប្រាស់ស្បង់ចីពរ និងនៅក្នុងកុដិ ដើម្បីបិទបាំងកេរ្តិ៍ខ្មាសការពារខ្យល់កំដៅថ្ងៃ សត្វតូចសត្វធំរាទិចឬខាំជាដើម។ បើតាមន័យនេះ ទ្រនាប់

ជើងអាចពាក់បាន បើសំដែងភាពជាអ្នកមានជម្ងឺនិងភាពមានអនាម័យដូចពោលមកហើយ។ បើពាក់ទ្រនាប់ជើងមិនបាន ការបាំងឆត្រដើម្បីការពារកំដៅថ្ងៃការពារភ្លៀងក៏ពុំបានដែរ។ ព្រះពុទ្ធបានត្រាស់ដឹងកន្លងទៅបានជាង២៥០០ឆ្នាំមកហើយ មកដល់ពេលនេះវិទ្យាសាស្រ្តបានលូតលាស់ចំរើនដែលសម្ភារៈខ្លះក្នុងសម័យពុទ្ធកាលពុំទាន់កើតមាន ដូចជាព្រះសង្ឃសម័យដើមលូតព្រះហស្តឆាន់ចង្ហាន់ក្នុងបាត្រ ឥឡូវនេះ ព្រះសង្ឃឆាន់ចង្ហាន់ដោយប្រើស្លាបព្រានិងសមជាដើម។ បើព្រះពុទ្ធគង់នៅរហូតមកដល់ពេលនេះហើយទត់ឃើញហេតុការណ៍ដូចពោលមកហើយនេះ ព្រះអង្គពិតជាអនុញ្ញាតក្នុងការពាក់ទ្រនាប់ជើងនេះពុំខាន។ បើពាក់ទ្រនាប់ជើងទៅមិនបាច់ឲ្យគេយកទឹកមកលាងព្រះបាទឲ្យពិបាកគេទេ ដោយដើរជាន់លើដីផ្ទាល់ គេមិនប្រគេនឲ្យជាន់លើអាសនៈមានដ៏ល្អរបស់គេទេ មុនពេលដែលលាងសំអាតព្រះបាទដ៏ក្រខ្វក់នោះឲ្យស្អាតសិន។ សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធ ពុំមែនស្ថិតនៅលើការពាក់ទ្រនាប់ជើងឬមិនពាក់នោះទេ គឺស្ថិតនៅលើការលះបង់អំពើអាក្រក់វិញទេ។ មួយទៀត ពុំមែនដូចអ្នកខ្លះយល់ថា អាបត្តិទុក្កដរួមគ្នាច្រើនទៅក្លាយជាអាបត្តិបារាជិកនោះទេ គ្មានវិន័យណានិយាយដូច្នេះឡើយ។ អាបត្តិទុក្កដនៅតែអាបត្តិទុក្កដពុំអាចទៅជាអាបត្តិអ្វីផ្សេងទៀតទេ ទោះបីរួមគ្នាច្រើនរាប់លានក៏ដោយ កុំយល់ជ្រុលខុសវិន័យឡើយ។

បើអ្នកមិនពាក់ទ្រនាប់ជើងប្រព្រឹត្តខុសចិត្តមិនបរិសុទ្ធ ក៏មិនគ្រាន់បើជាងគេពាក់ទ្រនាប់ជើងដែរ។ ដូច្នេះ បញ្ហាបន្តិចបន្តួចកុំឲ្យចែកជាបក្សជាពួកនាំឲ្យបែកបាក់សាមគ្គីក្នុងសង្គមអ្នកកាន់ព្រះពុទ្ធសាសនាឡើយ។ សូមកុំវាយតម្លៃជ្រុលថា អ្នកមិនពាក់ទ្រនាប់ជើងជាអ្នកបរិសុទ្ធឡើយ។

## បញ្ហាព្រះសង្ឃកាន់បច្ច័យ

អំពីបញ្ហាមិនឲ្យកាន់មាសប្រាក់ គុណសម្បត្តិរបស់ព្រះសង្ឃគឺជាអ្នកមិនលោភមានសេចក្ដីសន្តោស ការមានមាសប្រាក់នាំឲ្យមានសេចក្ដីលោភ ឲ្យត្រេកអរចំពោះតែបច្ច័យ៤គឺចីវរបច្ច័យ បិណ្ឌបាតបច្ច័យ សេនាសនបច្ច័យ និងគិលានភេសជ្ជបច្ច័យដែលជាទីអាស្រ័យរបស់អ្នកបួសខានមិនបាន។ បើមានអ្នកឧបត្ថម្ភហើយ ព្រះសង្ឃមិនបាច់កាន់បច្ច័យដែលហៅថាប្រាក់ក៏ល្អហើយដូចជាព្រះសង្ឃកន្លែងសមាធិនិងកន្លែងវិបស្សនាខ្លះ ប៉ុន្តែកុំឲ្យនិយាយប៉ះពាល់ដល់ព្រះសង្ឃដែលកាន់ប្រាក់នេះ។ អាបត្តិបាចិត្តិយៈធំជាងអាបត្តិ-ទុក្កដបន្តិចប៉ុណ្ណោះ ដែលព្រះពុទ្ធហាមព្រោះដើម្បីកុំឲ្យព្រះសង្ឃជាប់ចិត្តក្នុងន័យលោភ។ មិនថាតែមាសប្រាក់ទេ សូម្បីព្រះសង្ឃមានបច្ច័យ៤ដែលគេប្រគេនច្រើនហើយជាប់ចិត្តក៏មានលក្ខណៈដូចគ្នា។ អង្គរបស់មាសប្រាក់មាន៣គឺ ១.មាសប្រាក់ ២.ទុកដាក់ជារបស់ខ្លួន ៣.ត្រេកអរចំពោះ

មាសឬប្រាក់នោះ។ បើព្រះសង្ឃមិនកាន់ប្រាក់ទេ ឲ្យគេទុកដាក់ឲ្យតែត្រេកអរចំពោះមាសឬប្រាក់ដែលគេទុកដាក់ឲ្យនោះ ក៏មានលក្ខណៈដូចជាព្រះសង្ឃកាន់ផ្ទាល់ដែរ។ បើព្រះសង្ឃកាន់បច្ច័យសំរាប់កសាងមិនត្រូវអាបត្តិទេ ព្រោះខ្វះអង្គមួយ គឺទុកដាក់ជារបស់ខ្លួន។ ប្រាក់នេះជាតំណាងបច្ច័យ៤ ពេលដែលសម្តេចព្រះសង្ឃរាជ ជួន-ណាត គង់នៅបានមានថេរដីកាថា សម័យនេះជៀសពុំរួចពីការកាន់បច្ច័យទេ បើមិនដូច្នេះទេ ព្រះសង្ឃមិនអាចរស់នៅបានឡើយ ដូច្នេះបើព្រះសង្ឃណាមានមធ្យោបាយមិនកាន់បាន សូមកុំរិះគន់អ្នកកាន់កុំឲ្យបែកបាក់បក្សពួក ព្រោះព្រះសង្ឃបុថុជ្ជន គ្មានបរិសុទ្ធជាងគ្នាទេ។ ដូច្នេះហើយបានជា អាចារ្យដែលឈ្លាសវៃតែងបវរណានូវប្រាក់ដែលប្រគេននោះ ឲ្យលោកត្រេកអរជាបច្ច័យ៤។

# ១៦- អំពីអបិយជំនឿ ផ្ទុយពីព្រះពុទ្ធសាសនា

មានពុទ្ធបរិស័ទខ្មែរជាច្រើន ដែលចង់ដឹងការពិត អំពីការបង្កើតជំនឿផ្សេងៗរបស់ខ្មែរខ្លះនៅប្រទេសកម្ពុជា ដូចជា សម្តេច ជួន ណាតដឹងជាតិជាដើម តើត្រឹមត្រូវតាមការពិតរបស់ព្រះពុទ្ធសាសនាឬទេ?

ដោយចង់រក្សាតម្លៃរបស់ព្រះពុទ្ធសាសនា យើងសូមឆ្លើយទៅនឹងសំនួរខាងលើនេះ ដោយយោលទៅតាមព្រះពុទ្ធដីកានិងដោយចិត្តបរិសុទ្ធ គ្មានបំណងបំផ្លាញផលប្រយោជន៍របស់ជនណាឡើយ។

ជំនឿត្រឹមត្រូវរបស់ព្រះពុទ្ធសាសនា គឺជំនឿលើកម្មផល។ ជំនឿប្រាសចាកការពិតនាំឲ្យមានវិបត្តិឧបាសក ដូចជាវិបត្តិទីបីនៃវិបត្តិទាំងប្រាំគឺ កោតុហល មង្គលិកោ ហោតិ ប្រែថា ឧបាសកប្រកបដោយមង្គលភ្ញាក់ផ្អើល។ គឺមានជំនឿទៅលើហេតុការណ៍ណាមួយ ដែលប្រាសចាកការពិត ដែលគេប្រឌិតឡើងដើម្បីគោលដៅអ្វីមួយ មានដើម្បីលាភៈសក្កា-រៈ និងដើម្បីគោលដៅនយោបាយ ដោយមធ្យោបាយដែលយកមកប្រើស្របទៅតាមជំនឿរបស់ខ្មែរ។

ក្នុងកាលាមសូត្រ ព្រះពុទ្ធសំដែងកុំឲ្យជឿតាមអាការៈ ១០យ៉ាង មានមិនឲ្យប្រកាន់ជឿដោយឮតាមគ្នា ដោយការ

សន្និដ្ឋាន គឺដោយការចូលចិត្តតាមអាការៈខាងក្រៅជាដើមឡើយ។ ប៉ុន្តែមុននឹងជឿជាយ៉ាងណា ត្រូវពិនិត្យពិចារណា និងធ្វើការពិសោធន៍ឲ្យបានល្អិតល្អន់ជាមុនសិន។ យ៉ាងណាមិញ ពុទ្ធសាសនិកជនខ្មែរបើឮការឃោសនារឿងអ្វីមួយ កុំអាលជឿមុនពិចារណារកការពិត បើមិនទាន់ច្បាស់ខ្លួនឯងទេ គួររកជំនួយ ដោយសាកសួរអ្នកចេះដឹងព្រះពុទ្ធសាសនាច្បាស់លាស់ ព្រោះជំនឿខុសអនុវត្តខុស នាំឲ្យខូចប្រយោជន៍ មាននាំឲ្យខាតបង់ទ្រព្យសម្បត្តិជាដើម។ ពេលនេះ យើងលើកយកតែអបីយ៍ជំនឿខ្លះនាំឲ្យខូចប្រយោជន៍សាធារណជន និងនាំឲ្យខូចតម្លៃរបស់ព្រះពុទ្ធសាសនាមករៀបរាប់ដូចតទៅនេះ៖

មុននឹងលើកយកបញ្ហាសម្ដេចជួន-ណាតដឹងជាតិនៅទូលព្រះរាជា យើងសូមលើកយករឿងរ៉ាវជាអបីយ៍ជំនឿខ្លះដែលបានឡើង ហើយឥឡូវនេះបានបាត់បង់វិញហើយ។

គ្រួសារខ្មែរមួយនៅប្រទេសកម្ពុជា បានឃោសនាអំពីកូនគោរបស់ខ្លួនដែលទើបនឹងកើតថាជាព្រះគោ ដោយគោនោះកើតមកគ្មានដុះរោម។ អ្នកស្រុកខ្លះជឿបាននាំគ្នាទៅថ្វាយបង្គំសុំសេចក្ដីសុខ មានអ្នកខ្លះត្រងយកទឹកនោមកូនគោនោះទៅធ្វើជាថ្នាំ។ អ្នកម្ចាស់គោក៏បានលាភសក្ការៈខ្លះ។ សេចក្ដីពិត កូនគោដែលគ្មានរោមនោះជាគោមានកាយសម្បទាពុំគ្រប់គ្រាន់ ចាត់ជាគោអភ័ព្វ ជាគោពិការ ដែល

យូរៗមានម្តងជាការធម្មតាពុំមែនចម្លែកអ្វីឡើយ ពុំគួរជឿថាជាអ្នកមានបុណ្យឡើយ។

មួយទៀត ព្រះគោព្រះកែវ គឺជារឿងមួយដែលគេតែងក្នុងសម័យលង្វែក ពេលដែលសៀមចូលមកឈ្លានពានប្រទេសកម្ពុជា។ ព្រះគោជាតំណាងគម្ពីរក្បួនច្បាប់របស់ខ្មែរដែលសៀមប្រមូលយកទៅ។ ឯព្រះកែវ ជាតំណាងអ្នកប្រាជ្ញខ្មែរ ដែលសៀមនាំយកទៅ។ ព្រោះសៀមចង់បានគម្ពីរក្បួនច្បាប់និងអ្នកប្រាជ្ញខ្មែរ ដើម្បីយកទៅជួយអភិវឌ្ឍន៍ប្រទេសគេឲ្យលូតលាស់ចំរើន។ មិនយូរប៉ុន្មានជំនឿនេះបានសាបរលាបទៅវិញ ប៉ុន្តែអ្នកស្រុកខ្លះបានខាតបង់ទ្រព្យសម្បត្តិដោយផ្តល់ឲ្យអ្នកម្ចាស់កូនគោដោយសារជំនឿខុស។

រឿងលោកតាល្ងង់អាយុវែង ជារឿងមួយដែលលោកតាចាស់ម្នាក់នៅប្រទេសកម្ពុជា បានតាំងខ្លួនឯងថា តាល្ងង់អាយុវែង ហើយបើអ្នកណាជឿគាត់ អ្នកនោះនឹងបានសេចក្តីសុខ។ គាត់និយាយថា គាត់តែងតែទាក់ទងជាមួយព្រះឥន្ទ្របើគាត់ចង់ដឹងអ្វីមួយតែងតែសួរព្រះឥន្ទ្រ។ មានអ្នកជឿខ្លះនាំគ្នាទៅសុំសេចក្តីសុខពីគាត់ ដោយយកវត្ថុផ្សេងៗ និងប្រាក់ខ្លះទៅជូនគាត់ ឲ្យគាត់សូត្រធម៌ជូនពរ។ លាភសក្ការៈក៏ឡើងដល់គាត់យ៉ាងច្រើន រហូតគាត់ធ្វើបានប្រាសាទនិងផ្ទះជាច្រើនខ្នង។ ក្រោយមកបានត្រូវសាបទៅវិញ ប៉ុន្តែធ្វើឲ្យអ្នកជឿ ជាពិសេសអ្នកជឿច្រើននៅបរទេស ត្រូវចំណាយប្រាក់

ជាច្រើន។ សូមពិនិត្យមើលអ្នកជឿ គាត់បានប្រាប់ថាគាត់ជាមនុស្សល្ងង់ ហេតុអ្វីបានជាជឿមនុស្សល្ងង់ តើមនុស្សល្ងង់អាចជួយអ្វីបាន? ព្រះពុទ្ធសំដែងថា សេចក្តីសុខទុក្ខចំរើនវិនាសត្រូវស្ថិតនៅលើអំពើរបស់ខ្លួន បើចង់បានសេចក្តីសុខត្រូវសាងល្អ ពុំអាចសុំសេចក្តីសុខពីអ្នកដទៃ ដូចពីតាល្ងង់បានឡើយ។

មានបុរសម្នាក់តាំងខ្លួនជាតាបស នៅម្តុំច្បារអំពៅ បាននិយាយថា បើគេយកវត្ថុផ្សេងៗទៅកប់ក្នុងដីបានចំនួនពីរបីឆ្នាំ នឹងក្លាយជាមាស។ មានខ្មែរខ្លះ ជាពិសេសខ្មែរនៅបរទេស ដោយឃើញការឃោសនាតាមរយៈវីដេអូ ដោយចង់បានមាស ក៏យកវត្ថុផ្សេងៗតាមការតម្រូវរបស់គាត់ ទៅកប់ក្នុងដី។ លុះគ្រប់ឆ្នាំតាមការកំណត់ ក៏ទៅគាស់មើលមិនឃើញមាស ឃើញតែវត្ថុនោះក្លាយជាចំណីដី សូម្បីសារមន្ទីរដែលបុរសនោះបានឲ្យគេកសាងពីដី ក៏ត្រូវរបេះបាក់ស្រុតហើយរលំ។ ទំរាំតែដឹងថាខ្លួនជឿខុស បានត្រូវចំណាយអស់ប្រាក់ជាច្រើន ទីបំផុតបុរសតាំងខ្លួនជាតាបសនោះប្រមូលបានប្រាក់ជាច្រើន ហើយរត់គេចខ្លួនបាត់ទៅ។ នេះជាជំនឿខុស ដោយមិនបានពិចារណាថា តើវត្ថុផ្សេងៗដូចជាស្ពៅគ្រឿងធ្វើពីឈើជាដើម កប់ទៅ អាចក្លាយជាមាសបានឬទេ?

មានបុរសម្នាក់នៅកម្ពុជា តាំងខ្លួនថាព្រះពុទ្ធមកចូលរូប។ ក្នុងភទ្ទកប្បមានព្រះពុទ្ធត្រាស់៥ព្រះអង្គ គឺព្រះពុទ្ធព្រះ

នាមព្រះកក្កុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ ព្រះសមណគោតម និងព្រះសិអារ្យមេត្រីយ៍ ដែលនឹងបានត្រាស់ក្នុងពេលខាងមុខ។ នៅពេលបុរសនោះចូលរូបព្រះពុទ្ធព្រះនាមព្រះកក្កុសន្ធោបាននិយាយទៅកាន់ព្រះពុទ្ធត្រាស់ក្រោយមកទៀតថា លោកប្អូន ដូចហៅថាលោកប្អូនព្រះកោនាគមនោជាដើម។ ពុំអាចជាការពិតដូច្នេះឡើយ ព្រោះព្រះពុទ្ធបានរលត់ខន្ធបរិនិព្វានហើយ មិនត្រឡប់មកភពថ្មីទៀតទេ គឺពុំមានព្រះវិញ្ញាណមកសណ្ឋិត ឬមកចូលរូបដូចជាបិសាចដូច្នេះឡើយ។

## អំពីសម្តេច ជួន ណាត ដឹងជាតិ

បុរសម្នាក់ឈ្មោះ ផាន -វុទ្ធី អាយុ៣១ឆ្នាំក្នុងឆ្នាំ២០០៧ នេះបានកសាងវត្តទួលព្រះរាជា ឃុំពោបាន ស្រុកកោះធំ ខេត្តកណ្តាល ប្រទេសកម្ពុជា។ លោក ផាន-វុទ្ធី មិនបានបួសទេ នៅជាគ្រហស្ថ ស្លៀកពាក់ស ហើយទុកសក់ដូចគ្រហស្ថធម្មតា។ សព្វថ្ងៃនៅក្នុងវត្ត មានព្រះសង្ឃជាង២០អង្គ ដែលបំបួសដោយលោក ផាន -វុទ្ធី។ ដោយឆ្លើយតបទៅនឹងសំនួរដែលគេចង់ដឹងអំពីភាពខុសប្រក្រតី ដែលគ្រហស្ថបំបួសព្រះសង្ឃ លោកផាន-វុទ្ធីឆ្លើយថា គាត់ជាអ្នកមានបុណ្យ គាត់បានសំរេចធម៌ជាន់ខ្ពស់ គ្មានព្រះសង្ឃណាអាចធ្វើឧបជ្ឈាយ៍គាត់បានទេ គាត់អាចបំបួសព្រះសង្ឃបាន។ នេះជាសំដី

របស់អ្នកដែលគាំទ្រគាត់និយាយប្រាប់។ សូមពុទ្ធបរិស័ទទាំងឡាយពិចារណាមើល តើមានអ្នកជំនាញការខាងព្រះពុទ្ធសាសនា ឬគណៈកម្មការឯកទេសខាងព្រះពុទ្ធសាសនាឲ្យតម្លៃថា គាត់ជាអ្នកមានបុណ្យ បានសម្រេចធម៌ជាន់ខ្ពស់ពិតមែន ក្រៅពីការឲ្យតម្លៃតែខ្លួនគាត់។ មួយទៀត គ្រហស្ថជាហីនភេទ ពុំអាចបំបួសព្រះសង្ឃជាឧត្តមភេទបានឡើយ គឺផ្ទុយនឹងពុទ្ធប្បញ្ញត្តិ។

គ្រឿងអលង្ការមាសពេជ្រខ្លះ ជាកែវ មុនីជោតិ ដូចជាចិញ្ចៀនបន្តោងក កងដៃ និងគ្រឿងអលង្ការផ្សេងៗទៀតជាច្រើនបានយកមកលក់ពាសពេញនៅបរទេស។ អ្នកដែលយកមកលក់នេះអះអាងថា បានមកពីទូលព្រះរាជា។ គ្រឿងអលង្ការទាំងនោះមានតម្លៃរាប់រយដុល្លារ។ អ្នកលក់បានឃោសនាថា កែវមុនីជោតិនេះសក្តិសិទ្ធិណាស់ អ្នកណាជាវនឹងបានសុខចំរើន ព្រោះគ្រឿងទាំងនោះពុំមែនកើតឡើងដោយធម្មតាទេ គឺកើតឡើងដោយព្រះអង្គម្ចាស់ ធាន -វុទ្ធី យកមកពីភ្នំ។ សូមពុទ្ធបរិស័ទទាំងឡាយពិចារណា តើគ្រឿងអលង្ការទាំងនោះពិតជាបានមកពីភ្នំ ឬពួកទេវតា ប្រទានឲ្យគាត់ តើគួរជឿបានទេ? តើភ្នំឯណាដែលមានគ្រឿងអលង្ការទាំងនោះ ហេតុដូចម្តេចបានជាអ្នកដទៃទៀតមិនឃើញ? អ្នកជំនាញការខាងគ្រឿងអលង្ការអាចពិនិត្យមើល នឹងដឹងការពិតថា ជាគ្រឿងអលង្ការពិតមកពីភ្នំ ឬជាគ្រឿងអលង្ការគេក្រ

ឡើងថ្ងៃនៅភ្នំពេញ ឬនៅសហរដ្ឋអាមេរិក? ពាក្យឃោសនាថា ពាក់ទៅបានសុខចំរើន ជាពាក្យមិនស្របតាមន័យរបស់ព្រះពុទ្ធសាសនាឡើយ ព្រោះព្រះពុទ្ធពុំដែលសំដែងថាវត្ថុផ្សេងៗ មានគ្រឿងអលង្ការនេះជាដើម ថាឲ្យសុខដល់មនុស្ស ក្រៅពីអំពើល្អរបស់ខ្លួនឡើយ។ នេះជាការឃោសនានាំឲ្យពុទ្ធបរិស័ទខ្មែរភ័ន្តច្រឡំ។ ចំពោះបញ្ហាថា ប្រាក់ដែលបានមកពីការលក់ដូរ គឺយកទៅកសាងកុដិ ព្រះវិហារ និងព្រះពុទ្ធរូបយ៉ាងធំៗ ដើម្បីឲ្យព្រះពុទ្ធសាសនាលូតលាស់ចំរើនទេតើ។ គេឃើញមានការកសាងខ្លះដូច្នេះមែន ប៉ុន្តែចំនួនប្រាក់ផ្សេងពីនេះ ដែលមិនបានយកទៅកសាង គ្មានគណៈកម្មការណាពិនិត្យឲ្យដឹងការពិតឡើយ។

គេឃើញរូបលោក ធាន-វុទ្ធី ផ្តិតភ្ជាប់ជាមួយព្រះឆាយាលក្ខណ៍សម្តេចជួន-ណាត ដែលគេយកមកផ្សាយនៅបរទេស។ ត្រង់ថាគាត់ពីដើមជាសម្តេច ជួន-ណាត ឬពុំមែនការពិតទេនោះ គ្មានអ្នកជំនាញការខាងព្រះពុទ្ធសាសនាណាថាទេ ក្រៅពីខ្លួនគាត់ថាខ្លួនគាត់។ ឥឡូវនេះគេឃើញរូបមួយប្លែកទៀត គឺរូបលោក ធាវ-វុទ្ធី ដាក់ចំកណ្តាលព្រះពុទ្ធរូបទាំង៤ព្រះអង្គ ដែលជាសញ្ញាបញ្ជាក់ថា ខ្លួនគាត់ជាព្រះសិអារ្យមេត្រីយ៍។ សូមបញ្ជាក់ថា ក្នុងភទ្ទកប្បមានព្រះពុទ្ធត្រាស់៥ព្រះអង្គ ឥឡូវនេះបានត្រាស់៤ព្រះអង្គហើយ នៅសល់តែមួយព្រះអង្គទៀតនឹងត្រាស់នៅពេលខាងមុខ គឺព្រះ

សិអារ្យមេត្រីយ៍ ដែលគេដាក់រូបលោក ផាន-វុទ្ធី នៅចំកណ្តាលនេះឯង។ បើតាមរូបភាពដែលគេយកមកផ្សាយនៅបរទេសនេះបញ្ជាក់ថា ឆាកទីមួយ គឺលោក ផាន-វុទ្ធី ជាសម្តេចជួន-ណាត ឥឡូវឆាកនេះជិតសាបហើយ ក៏បង្កើតឆាកមួយទៀត គឺខ្លួនគាត់ជាព្រះសិអារ្យមេត្រីយ៍។

បើយោងតាមព្រះពុទ្ធសាសនាផ្នែកសមោធាន៨យ៉ាង ដែលអាចទៅជាព្រះពោធិសត្វបាន គឺក្នុងអត្តភាពបច្ចុប្បន្នអាចសំរេចជាព្រះអរហន្ត បានជួបនឹងព្រះពុទ្ធអង្គណាមួយ បានបួសក្នុងសាសនាព្រះពុទ្ធជាដើម ដូចជាព្រះសុមេធតាបស មានទំនាយពីព្រះពុទ្ធថា តាបសនេះនៅអនាគតនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមព្រះសមណគោតម។ ដូច្នេះលក្ខខណ្ឌនេះ ពុំមានក្នុងលោក ផាន -វុទ្ធីទៅទូលព្រះរាជាឡើយ។ ប៉ុន្តែមានលោកតាម្នាក់ដែលគាំទ្រទូលព្រះរាជាបានពោលថា លោកផាន -វុទ្ធី ពុំទាន់តាំងខ្លួនជាព្រះសិអារ្យមេ-ត្រីយ៍នៅឡើយទេ បើមានរូបភាពបែបនេះពុំមែនចេញពីគាត់ឡើយ។

អំពីការឃោសនាបុណ្យកឋិននៅបរទេសយកទៅទូលព្រះរាជា បើតាមអ្នកផ្សាយរកអ្នកដើមបុណ្យកឋិនឆ្នាំ២០០៧នេះនិយាយថា គេរកឲ្យបាន៥ពាក់ត្រៃទៅ១ម៉ឺនត្រៃក្នុង១ត្រៃ២០០ដុល្លារ។ អ្នកឃោសនាបាននិយាយថា បើបងប្អូនណាបានទទួលធ្វើបុណ្យកឋិន នឹងបានបុណ្យទាន់ហាន់

ហើយនឹងបានជួបព្រះសិអារ្យមេត្រីយ៍ ព្រោះលោកធាន-វុទ្ធី ជាតួអង្គព្រះសិអារ្យមេត្រីយ៍។ យើងពុំប្រឆាំងនឹងការធ្វើបុណ្យកឋិនទេ ប៉ុន្តែយើងមិនយល់ស្របចំពោះការឃោសនារបៀបនេះ ព្រោះជារឿងពុំពិត នាំឲ្យពុទ្ធបរិស័ទខ្មែរភ័ន្តច្រឡំខូចតម្លៃព្រះពុទ្ធសាសនា បើនិយាយបែបនេះមែន។

បញ្ហាមួយអំពីការក្រាលគ្រងបុណ្យកឋិននេះ បើគាត់ក្រាលគ្រងកឋិនដោយខ្លួនឯងក្តី ប្រគេនព្រះសង្ឃឲ្យក្រាលកឋិនក្តី មិនឡើងជាកឋិនឡើយ ព្រោះខុសពីវិន័យបញ្ញត្តិរបស់ព្រះពុទ្ធ។ តាមព្រះវិន័យ មិនថាគ្រហស្ថទេដែលមិនអាចក្រាលគ្រងកឋិន សូម្បីសាមណេរក៏មិនអាចក្រាលគ្រងកឋិនបានឡើយ។ មួយទៀត បើការបំបួសនោះមិនឡើងជាភិក្ខុ ព្រះសង្ឃទាំងនោះ ក៏មិនអាចក្រាលឲ្យឡើងជាកឋិនបានឡើយ។

បញ្ហាមួយទៀត គេមើលវីដេអូដែលថតមកពីទួលព្រះរាជា លោក ធាន -វុទ្ធីបានពោលថា ពលរដ្ឋខ្មែរមិនបាច់ព្រួយបារម្ភទេ បន្តិចទៀតអ្នកមានបុណ្យនឹងចេញមក ហើយរបស់ដែលបានបាត់បង់ទៅមានទឹកដីជាដើម នឹងបានមកខ្មែរវិញ។ បើពាក្យដែលគេប្រាប់នេះ គាត់ពោលពិតមែននោះគួរឲ្យស្តាយ ព្រោះផ្ទុយពីពាក្យរបស់ព្រះពុទ្ធ គឺព្រះពុទ្ធសំដែងថា សេចក្តីសំរេចគ្រប់យ៉ាងកើតមកពីសេចក្តីព្យាយាមមិនខ្ជិលច្រអូសដេកចាំសំណាង។ មិនថាតែដីដែលបាត់បង់

ទៅ ដែលមិនត្រូវបានមកខ្មែរវិញ សូម្បីតែទឹកដីក្នុងព្រំដែនបច្ចុប្បន្ននេះ ប្រទេសទាំងពីរកំពុងតែរំកិលចូលមកដីខ្មែរជាបន្តទៀត។

ចំពោះបញ្ហាទូលព្រះរាជានេះ ក្រសួងធម្មការនិងក្រសួងសង្ឃរាជគ្មានប្រតិកម្មអ្វីទាំងអស់។ យើងយល់ថា មានអ្នកធំជាន់ខ្ពស់នៅពីក្រោយ បើទោះបីគេដឹងថាមានការខុសឆ្គងខ្លះតាមផ្លូវព្រះពុទ្ធសាសនា ក៏គេត្រូវតែបិទភ្នែក ព្រោះវាមានប្រយោជន៍បែបណាមួយ។ ចំពោះយើងវិញ យើងចង់ឲ្យព្រះពុទ្ធសាសនាលូតលាស់ចំរើនក្នុងភាពបរិសុទ្ធ។ មួយទៀតយើងមិនយល់ស្របធ្វើសំណង់តាមព្រះឥន្ទប្រាប់ ឬតាមគំនិតខ្លួន ផ្ទុយពីពុទ្ធប្រវត្តិនិងរចនាបថខ្មែរ ដែលធ្វើឲ្យបច្ច័យដែលគេបូជា ទៅជាគ្មានន័យ។

## ១៧- ពាក្យសូមខមាទោស

អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តេសំ នោ ភន្តេ ភគវា អច្ចយំ អច្ចតោ បដិគណ្ហាតុ អាយតឹ សំវរាយ។

បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ទោសកំហុសដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយ នូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមព្រះករុណាទាំងឡាយ អត់ទោសនូវកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឲ្យល្អទៅខាងមុខនោះហោង។

# ពាក្យថ្វាយខ្លួន

មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ ឧបាសិកាយោ នោ ភគវា ធារេន្តុ អជ្ជតគ្គេ បាណុបេតេ បាណុបេតា សរណំ គតេ សរណំ គតា។

បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលបរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះករុណាទាំងឡាយជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសកឧបាសិកាបានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅហោង។

# ១៨- ទស្សនៈអំពីពាក្យកាព្យ តេជៈខ្ញុំសាង

ពាក្យកាព្យនេះ ទើបនឹងកើតឡើងមិនយូរប៉ុន្មាន ប៉ុន្តែមិនទាន់រកឃើញអ្នកនិពន្ធ។ កំណាព្យនេះ បានត្រូវពុទ្ធសាសនិកជនខ្មែរស្ទើរគ្រប់ទីកន្លែងយកទៅសូត្រក្នុងឱកាសបញ្ចប់ពិធីបុណ្យផ្សេងៗ។អត្ថបទនេះ មានន័យឲ្យតាំងចិត្តក្នុងពេលបុណ្យទាន ជាបទកាកគតិ មានអត្ថន័យល្អ ប៉ុន្តែបើកែពីរកន្លែង និងបន្ថែមខាងចុងមួយវគ្គទៀត នឹងរឹតតែល្អទៅទៀត។

១. មួយកន្លែងមានន័យពុំសូវល្អគឺកន្លែង «គំនិតខ្ញុំកើតកំណើតខ្ញុំមាន» គួរកែដូច្នេះវិញ «គំនិតយល់ត្រូវ តាមផ្លូវនិព្វាន» ។

២. មួយកន្លែងទៀត ខុសជើងកាព្យ គឺកន្លែង «គុណគ្រូឧប. ជ្ឈាយាចារ្យ» ត្រូវញែកបទសមាសនាម គុណឧបជ្ឈាយាចារ្យឲ្យដាច់ពីគ្នា គឺឧបជ្ឈាយ៍ និងអាចារ្យ។ ពាក្យគុណគ្រូឧប. ទៅភ្ជាប់ពាក្យខាងមុខ ជាជើងកាព្យមិនល្អទេ។ ឯពាក្យជ្ឈាយាចារ្យ បានតែបីពាក្យ ព្រោះបទកាកគតិមានពាក្យបួនៗ។ ត្រូវកែដូច្នេះវិញ គុណឧបជ្ឈាយ៍ គុណគ្រូអាចារ្យ។

៣. គួរបន្ថែមខាងចុងមួយវគ្គទៀត ត្រូវជា៥វគ្គគឺ

ខ្ញុំសូមប្រាថ្នា សច្ចាវាចា តទៅខាងមុខ
សូមមានប្រាជ្ញា ភ្លឺថ្លាមុះមុត សូមឆ្លងផុតទុក្ខ

ដល់និព្វានហោង។

បន្ទាប់ពីកែរួច មានរូបរាងដូចខាងក្រោមនេះ

## តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន។
គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតយល់ត្រូវ តាមផ្លូវនិព្វាន មគ្គផលជាស្ពាន
ដល់ឋានថ្លៃថ្លា។
សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណឧបជ្ឈាយ៍ គុណគ្រូអាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
សូមជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ឋានផុតទុក្ខ។
ខ្ញុំសូមប្រាថ្នា សច្ចវាចា តទៅខាងមុខ
សូមមានប្រាជ្ញា ភ្លឺថ្លាមុះមុត សូមឆ្លងផុតទុក្ខ
ដល់និព្វានហោង។